ក្រសួងអធិការកិច្ច
Ministry of Inspection

# យុទ្ធសាស្ត្រ ៣៤៥៤





## អារម្ភកថា

តាមរយៈការលះបង់យ៉ាងធំធេងរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អគ្គមគ្គុទេសក៍ឯក និងជាប្រតិបត្តិករនយោបាយឈ្នះ-ឈ្នះ **អតីតនាយក-រដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** និងការអនុវត្តប្រកបដោយភាពជោគជ័យរបស់រាជរដ្ឋាភិបាល នូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំងបួនដំណាក់កាល ប្រទេសកម្ពុជាមានសុខសន្តិភាព ឯកភាពជាតិពេញលេញ ស្ថិរភាពនយោបាយ និងមានការអភិវឌ្ឍលើគ្រប់វិស័យ។ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ម៉ឺងម៉ាត់ និងប្រកបដោយចក្ខុវិស័យវែងឆ្ងាយប្រាកដនិយមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បី**កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** ដោយបន្តផ្តោតជាសំខាន់លើរបៀបវារៈជាតិ **"ប្រសិទ្ធភាពសមិទ្ធកម្ម"** ដែលកំណត់សូចនាករ និងក្របខ័ណ្ឌច្បាស់លាស់ តាមរយៈការបន្តអភិវឌ្ឍ**អភិក្រមទាំង៥ "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"** និង**អភិក្រម "ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ"** ព្រមទាំងកំណត់យក**អាទិភាពគន្លឹះ៥ មនុស្ស ផ្លូវ ភ្លើង ទឹក និងបច្ចេកវិទ្យា** និងបានកំណត់គោលដៅជាយុទ្ធសាស្ត្រនៃអភិបាលកិច្ចគឺការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ព្រមទាំងយកចិត្តទុកដាក់លើអត្ថប្រយោជន៍ប្រជាជនជាស្នូល ការកសាងជាតិ និងការពង្រឹងនីតិរដ្ឋ សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និងចីរភាព។ ស្របទៅនឹងឆន្ទៈមោះមុតឥតងាករេ និងចក្ខុវិស័យវែងឆ្ងាយ ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ពាក់ព័ន្ធនឹង **ការកែទម្រង់ ការពង្រឹងអភិបាលកិច្ច និងការលើកកម្ពស់និងពង្រឹងភាពស្អាតស្អំ នៅក្នុងរដ្ឋបាលសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច** ត្រូវបានប្តូរឈ្មោះមកជា **ក្រសួងអធិការកិច្ច** ដើម្បីដឹកនាំ និងគ្រប់គ្រងវិស័យអធិការកិច្ចនៃព្រះរាជា-ណាចក្រកម្ពុជា សំដៅបង្ការទប់ស្កាត់ កែលម្អ ប្រឆាំងការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា។

វិស័យអធិការកិច្ចកម្ពុជាបានឆ្លងកាត់ការវិវត្តជាច្រើនដំណាក់កាល ចាប់តាំងពីសម័យសង្គមរាស្ត្រនិយមរហូតមកដល់ពេលបច្ចុប្បន្ន ដែលក្រសួងអធិការកិច្ចជាអធិការកិច្ចរាជរដ្ឋាភិបាលមានសមត្ថកិច្ចធ្វើអធិការកិច្ចលើគ្រប់វិស័យ ដូចមានចែងក្នុងអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច ដោយមានមុខងារស្នូលចំនួន៤ រួមមាន៖ ១)**ការងារអធិការកិច្ច** ២)**ការងារដោះស្រាយបណ្តឹង** ៣)**ការងារតាមដានការអនុវត្តច្បាប់** និង៤)**ការងារអប់រំផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ**។ ដើម្បីសម្រេចបាននូវបេសកកម្មរបស់ក្រសួងក្នុងការដឹកនាំនិងគ្រប់គ្រងវិស័យអធិការកិច្ច តាមរយៈការអនុវត្តនូវមុខងារស្នូលទាំង៤នេះ ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់ សំដៅចូលរួមពង្រឹងអភិបាលកិច្ច លើកកម្ពស់ប្រសិទ្ធភាព និងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ ក្រសួងអធិការកិច្ចបានសម្រេចដាក់ចេញនូវយុទ្ធសាស្ត្រ «ពសជ៥» ដែលជាយុទ្ធសាស្ត្រមានចក្ខុវិស័យវែងឆ្ងាយ ក្នុងការចូលរួមជំរុញឱ្យសង្គមកម្ពុជាមានភាពធន់ និងភាពប្រកួតប្រជែង ព្រមទាំងធ្វើឱ្យស្ថាប័នសាធារណៈមានប្រសិទ្ធភាព គណនេយ្យភាព បរិយាបន្ន ព្រមទាំងធានាបាននូវយុត្តិធម៌ តម្លាភាព និងអភិបាលកិច្ចល្អ តាមរយៈបេសកកម្មច្បាស់លាស់ និងមុតស្រួច ក្នុងការពង្រឹងនិងលើកកម្ពស់ ទំនុកចិត្តលើស្ថាប័ន

សាធារណៈ។ «ព៤» **គឺពង្រឹងការងារស្នូលចំនួន៤ រួមមាន** (១)ពង្រឹងការងារអធិការកិច្ច, (២)ពង្រឹងការងារដោះស្រាយបណ្ដឹង, (៣)ពង្រឹងការងារតាមដានការអនុវត្តច្បាប់ និង(៤)ពង្រឹងការងារផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ **និង**«ជ៤» **គឺជំរុញការងារគាំទ្រចំនួន៤ រួមមាន** (១)ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត, (២) ជំរុញនិងបង្កើនសមត្ថភាពស្ថាប័ន, (៣)ជំរុញកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូ និង(៤)ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

យុទ្ធសាស្ត្រ «ព៤ជ៤» នេះ ត្រូវបានរៀបចំឡើង តាមរយៈការសិក្សា ស្រាវជ្រាវ វិភាគ ដោយផ្អែកលើមូលដ្ឋានច្បាស់លាស់ ដែលបានកំណត់នៅក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ព្រមទាំងស្របតាមអនុសាសន៍តម្រង់ទិសដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** សម្រាប់ដាក់ឱ្យអនុវត្តឆ្នាំ ២០២៥-២០២៨ របស់ក្រសួងអធិការកិច្ច។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធ នឹងបន្តចូលរួមសហការក្នុងស្មារតីគាំទ្រការអនុវត្តយុទ្ធសាស្ត្រ «ព៤ជ៤» ឱ្យសម្រេចបានជោគជ័យប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីពង្រឹងនិងលើកកម្ពស់ការដឹកនាំ និងគ្រប់គ្រងវិស័យអធិការកិច្ច នៃព្រះរាជាណាចក្រកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងអធិការកិច្ច ដែលបានលះបង់កម្លាំងកាយ ពេលវេលា និងប្រាជ្ញាស្មារតី ក្នុងការសហការៀបចំតាក់តែងនូវឯកសារយុទ្ធសាស្ត្រ «ព៤ជ៤» នេះឡើង ប្រកបដោយសាមគ្គីភាព និងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីចូលរួមចំណែកពង្រឹងអភិបាលកិច្ច និងទំនុកចិត្តសាធារណៈ ក្នុងគោលដៅកសាងសង្គមដែលមានភាពធន់ តាមរយៈការលើកកម្ពស់គុណភាពស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅធានាបាននូវ យុត្តិធម៌ តម្លាភាព និងអភិបាលកិច្ចល្អ ជូនប្រជាជន។

ថ្ងៃ ពុធ ៤រោច ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ២០២៥
**រដ្ឋមន្ត្រីក្រសួងអធិការកិច្ច**

**សុខ សូកេន**

# មាតិកា

**ជំពូកទី១៖** សេចក្តីផ្តើម ........ ១

**ជំពូកទី២៖** ចក្ខុវិស័យ គោលបំណង គោលដៅ និងវិសាលភាព ........ ២

**ជំពូកទី៣៖** សាវតារ វឌ្ឍនភាព និងបញ្ហាប្រឈម ........ ៣

**ផ្នែកទី១៖** សាវតារ ........ ៣

**ផ្នែកទី២៖** វឌ្ឍនភាព ........ ៦

**ផ្នែកទី៣៖** បញ្ហាប្រឈម ........ ៣៣

**ជំពូកទី៤៖** យន្តការ និងវិធានការដោះស្រាយជាយុទ្ធសាស្ត្រ ........ ៣៧

**យុទ្ធសាស្ត្រ៖** ពង្រឹងការងារអធិការកិច្ច ........ ៣៨

**យុទ្ធសាស្ត្រ៖** ពង្រឹងការងារដោះស្រាយបណ្តឹង ........ ៤១

**យុទ្ធសាស្ត្រ៖** ពង្រឹងការងារតាមដានការអនុវត្តច្បាប់ ........ ៤២

**យុទ្ធសាស្ត្រ៖** ពង្រឹងការងារផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ ........ ៤៤

**យុទ្ធសាស្ត្រ៖** ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត ........ ៤៦

**យុទ្ធសាស្ត្រ៖** ជំរុញ និងបង្កើនសមត្ថភាពស្ថាប័ន ........ ៥១

**យុទ្ធសាស្ត្រ៖** ជំរុញកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូ ........ ៥៤

**យុទ្ធសាស្ត្រ៖** ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ........ ៥៥

**ជំពូកទី៥៖** ផែនការសកម្មភាពឆ្នាំ២០២៥-២០២៨ ........ ៥៨

**ជំពូកទី៦៖** សេចក្តីសន្និដ្ឋាន ........ ១០០

## ការប្តេជ្ញាចិត្ត

កសាងទំនុកចិត្ត និងគណនេយ្យភាពតាមរយៈ

យុទ្ធសាស្ត្រ ៣៤៥៤

## ចក្ខុវិស័យ

ក្រសួងអធិការកិច្ចជាសេនាធិការរបស់រាជរដ្ឋាភិបាលដែលទទួលស្គាល់ថាយ៉ាងសកម្ម ដល់ការសម្រេចបាននៃបរិវត្តកម្មរបស់កម្ពុជា ដោយរួមចំណែកពង្រឹងអភិបាលកិច្ច និងទំនុកចិត្តសាធារណៈ ដើម្បីកសាងសង្គមដែលមានភាពធន់ ភាពប្រកួតប្រជែង និងចីរភាព តាមរយៈការលើកកម្ពស់គុណភាពស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ន សំដៅឆ្ពោះទៅសមិទ្ធផលធម៌ តម្លាភាព និងអភិបាលកិច្ចល្អ ជូនប្រជាជន

**៣៤ - ពង្រឹង៤** | **៣៤៥៤** | **៥៤ - ជំរុញ៤**

### ៣១ ពង្រឹងការងារអធិការកិច្ច

ពង្រឹងការត្រួតពិនិត្យ និងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងស្ថាប័នរដ្ឋាភិបាល

### ៣២ ពង្រឹងការងារដោះស្រាយបណ្តឹង

ធានាការដោះស្រាយបណ្តឹងដោយរលូនប្រកបដោយប្រសិទ្ធភាព និងការការពារសិទ្ធិប្រជាពលរដ្ឋ

### ៣៣ ពង្រឹងការងារតាមដានការអនុវត្តច្បាប់

ធានានូវតម្លាភាព និងការគោរពច្បាប់នៅក្នុងវិស័យសាធារណៈ និងឯកជន

### ៣៤ ពង្រឹងការងារអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ

កម្មវិធីអប់រំប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធស្តីពីអភិបាលកិច្ច និងបញ្ហាច្បាប់

- **៥១. ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត** — កែលម្អច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីអភិបាលកិច្ចល្អ
- **៥២. ជំរុញ និងបង្កើនសមត្ថភាពស្ថាប័ន** — ពង្រឹងស្ថាប័នរដ្ឋាភិបាល និងអង្គភាពអធិការកិច្ច
- **៥៣. ជំរុញកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ** — សហការជាមួយភាគីពាក់ព័ន្ធដើម្បីការកែលម្អគោលនយោបាយ និងអភិបាលកិច្ច
- **៥៤. ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល** — ទំនើបកម្មប្រតិបត្តិការតាមរយៈបច្ចេកវិទ្យា និងការត្រួតពិនិត្យដែលផ្អែកលើទិន្នន័យ

**សុចរិតភាព** | **វិជ្ជាជីវៈ** | **ភាពច្បាស់លាស់** | **គណនេយ្យភាព** | **ភាពជាដៃគូ**

# ជំពូកទី១
# សេចក្តីផ្តើម

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** តាមរយៈការអនុវត្តប្រកបដោយភាពជោគជ័យរបស់រាជរដ្ឋាភិបាល នូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំងបួនដំណាក់កាលជាពិសេស នយោបាយឈ្នះ-ឈ្នះ បានធ្វើឱ្យប្រទេសកម្ពុជា ទទួលបានសុខសន្តិភាពនិងឯកភាពជាតិពេញលេញ មានស្ថិរភាពនយោបាយ និងមានការអភិវឌ្ឍលើគ្រប់វិស័យ។

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងប្រាកដនិយមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដែលជាក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ជាតិ ផែនការអភិវឌ្ឍន៍តាមវិស័យ និងផែនការពាក់ព័ន្ធផ្សេងទៀត ដែលមានកំណត់សូចនាករ និងក្របខ័ណ្ឌច្បាស់លាស់ ជាពិសេស ការពង្រឹងអភិបាលកិច្ចសំដៅ ធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ធានានិរន្តរភាពនៃតួនាទី និងដំណើរការរដ្ឋបាលសាធារណៈ ព្រមទាំងយកចិត្តទុកដាក់លើអត្ថប្រយោជន៍ប្រជាជនជាស្នូល ការកសាងជាតិ និងការពង្រឹងនីតិរដ្ឋ សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និងចីរភាព។

ឈរលើមូលដ្ឋានដឹកនាំដ៏ត្រឹមត្រូវ និងការដាក់ចេញនូវគោលនយោបាយច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងរយៈពេល២៦ឆ្នាំ ចាប់ពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ហើយត្រូវបានប្តូរឈ្មោះមកជាក្រសួងអធិការកិច្ច នៅក្នុងនីតិកាលទី៧ នៃរដ្ឋសភា ក្រសួងបានបំពេញនូវបេសកកម្មរបស់ខ្លួនតាមការប្រគល់ភារកិច្ចរបស់រាជរដ្ឋាភិបាលលើមុខងារស្នូលចំនួន៤គឺ ការងារអធិការកិច្ច ការងារដោះស្រាយបណ្តឹង ការងារតាមដានការអនុវត្តច្បាប់ និងការងារអប់រំផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ ដែលសម្រេចបានលទ្ធផលគួរជាទីមោទនៈ ដើម្បីចូលរួមលើកស្ទួយការគោរព និងអនុវត្តច្បាប់ ទប់ស្កាត់ការរំលោភច្បាប់ លើកកម្ពស់ភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ លើកតម្កើងយុត្តិធម៌សង្គម បង្កើតបាននូវវប្បធម៌សន្តិភាព អហិង្សា និងពង្រឹងនីតិរដ្ឋ សំដៅបង្កើនជំនឿទុកចិត្តលើការដឹកនាំរបស់រាជរដ្ឋាភិបាល។

ទន្ទឹមនឹងលទ្ធផលជោគជ័យជាច្រើន ក៏នៅមានបញ្ហាខ្វះខាត និងបញ្ហាប្រឈមមួយចំនួនរួមមាន ការពង្រឹងយន្តការស្ថាប័ន ការកសាងសមត្ថភាពមន្ត្រី ការកសាងលិខិតបទដ្ឋានគតិយុត្ត កង្វះការគាំទ្រនិងកិច្ចសហការពីក្រសួង ស្ថាប័ន កង្វះកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ អន្តរជាតិ កង្វះធនធាន សម្ភារៈ និងមធ្យោបាយសម្រាប់ដំណើរការការងារស្នូលទាំង៤ កង្វះការលើកទឹកចិត្ត និងសុខដុមនីយកម្មលើវិស័យអធិការកិច្ច។

ដើម្បីចូលរួមអនុវត្តនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១របស់រាជរដ្ឋាភិបាល និងដោះស្រាយបញ្ហាខាងលើ ក្រសួងអធិការកិច្ចក្រោមការដឹកនាំរបស់ **ឯកឧត្តម សុខ សូកេន រដ្ឋមន្ត្រីក្រសួងអធិការកិច្ច** បានដាក់ចេញនូវយុទ្ធសាស្ត្រ «ព៤ជ៤» ដែល «ព៤» សំដៅការពង្រឹងការងារស្នូលចំនួន ៤ គឺ (១)

ពង្រឹងការងារអធិការកិច្ច, (២)ពង្រឹងការងារដោះស្រាយបណ្ដឹង, (៣)ពង្រឹងការងារតាមដានការអនុវត្តច្បាប់ និង (៤)ពង្រឹងការងារផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ និង «ជ៤» សំដៅជំរុញការងារគាំទ្រចំនួន៤គឺ (១)ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត, (២)ជំរុញនិងបង្កើនសមត្ថភាពស្ថាប័ន, (៣)ជំរុញកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូ និង(៤)ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

ក្រសួងអធិការកិច្ចប្ដេជ្ញាក្នុងការអនុវត្តយុទ្ធសាស្ត្រ «ព៤ជ៤» នេះ ដោយសហការយ៉ាងជិតស្និទ្ធជាមួយគ្រប់ភាគីពាក់ព័ន្ធ សំដៅរួមចំណែកក្នុងការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ លើកកម្ពស់នូវយុត្តិធម៌ និងធានាអភិបាលកិច្ចប្រកបដោយបរិយាបន្ន និងចីរភាព សំដៅចូលរួមសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។

យុទ្ធសាស្ត្រ «ព៤ជ៤» ត្រូវបានចូលរួមរៀបចំឡើងដោយថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ប្រកបដោយការគិតគូរនិងវិភាគគ្រប់ជ្រុងជ្រោយ ផ្អែកលើមូលដ្ឋានច្បាស់លាស់ដែលបានកំណត់នៅក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ អនុសាសន៍តម្រង់ទិសដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** លិខិតបទដ្ឋានគតិយុត្តនានា ឯកសារស្រាវជ្រាវពាក់ព័ន្ធ និងបទពិសោធដែលទទួលបានកន្លងមក ដើម្បីលើកជាយុទ្ធសាស្ត្រសម្រាប់អនុវត្តឆ្នាំ២០២៥-២០២៨របស់ក្រសួងអធិការកិច្ច។ សរុបជារួមមក យុទ្ធសាស្ត្រ «ព៤ជ៤» នេះរៀបចំឡើង ដើម្បីបង្កើនប្រសិទ្ធភាពនៃការដឹកនាំ និងគ្រប់គ្រងវិស័យអធិការកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ចក្ខុវិស័យ គោលបំណង គោលដៅ និងវិសាលភាព

### ១. ចក្ខុវិស័យ

ក្រសួងអធិការកិច្ច ជាសេនាធិការរបស់រាជរដ្ឋាភិបាល ដែលចូលរួមស្ដាបនាយ៉ាងសកម្ម ដល់ភាពរស់រវើក នៃបរិវត្តកម្មរបស់កម្ពុជា ដោយរួមចំណែកពង្រឹងអភិបាលកិច្ច និងទំនុកចិត្តសាធារណៈ ដើម្បីកសាងសង្គមដែលមានភាពធន់ ភាពប្រកួតប្រជែង និងចីរភាព តាមរយៈការលើកកម្ពស់គុណភាពស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ន សំដៅធានាបាននូវយុត្តិធម៌ តម្លាភាព និងអភិបាលកិច្ចល្អជូនប្រជាជន។

### ២. គោលបំណង

យុទ្ធសាស្ត្រ«ព៤ជ៤»មានគោលបំណងចូលរួមពង្រឹងភាពស្អាតស្អំ និងអភិបាលកិច្ចរបស់ស្ថាប័នសាធារណៈ ធានាឱ្យបាននូវប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ ធានាយុត្តិធម៌ក្នុងការដោះស្រាយវិវាទ និងការការពារសិទ្ធិប្រជាពលរដ្ឋ ការអប់រំផ្សព្វផ្សាយច្បាប់ អនុវត្តច្បាប់យ៉ាងម៉ឺងម៉ាត់ យុត្តិធម៌ និងស្មើភាពគ្នា ប្រកបដោយតម្លាភាព គណនេយ្យភាព សុចរិតភាព វិជ្ជាជីវៈ ភាពច្បាស់លាស់ និងការទទួលខុសត្រូវ សំដៅកសាងទំនុកចិត្តពីសាធារណជន រួមចំណែកពង្រឹងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព សហប្រតិបត្តិការល្អ និងលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ការវិនិយោគ ពាណិជ្ជកម្ម និងសាធារណជន។

## ៣. គោលដៅ

ដើម្បីសម្រេចបាននូវចក្ខុវិស័យនិងគោលបំណងខាងលើ ក្រសួងអធិការកិច្ច បានដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រ ដូចខាងក្រោម៖

១- ពង្រឹង និងលើកកម្ពស់គុណភាពស្ថាប័នសាធារណៈ ដោយផ្តោតអាទិភាពលើការពង្រឹងយន្តការគ្រប់គ្រង និងផ្តល់សេវាសាធារណៈ ព្រមទាំងមានវិធានការច្បាប់ចំពោះមន្ត្រីសាធារណៈដែលបំពានក្រមសីលធម៌វិជ្ជាជីវៈ បំពានអំណាច និងប្រព្រឹត្តអំពើអសកម្មនានាក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន។

២- ពង្រឹង និងលើកកម្ពស់តម្លាភាព គណនេយ្យភាព សុចរិតភាព ភាពស្អាតស្អំ ក្នុងស្ថាប័នសាធារណៈ យុត្តិធម៌សង្គម តាមរយៈការដោះស្រាយបណ្តឹងប្រកបដោយប្រសិទ្ធភាព។

៣- ពង្រឹង និងលើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទបញ្ជា អនុសាសន៍ និងសេចក្តីសម្រេចផ្សេងៗរបស់ប្រមុខរាជរដ្ឋាភិបាល។

៤- ពង្រឹង និងលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងវិស័យច្បាប់និងអភិបាលកិច្ច តាមរយៈការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ ដើម្បីចូលរួមក្នុងការកសាងនីតិរដ្ឋ ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងការពារផលប្រយោជន៍សាធារណៈ។

៥- ជំរុញ និងពង្រឹងយន្តការសិក្សា ស្រាវជ្រាវ និងរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត នីតិវិធី វិធាននិងបទដ្ឋានផ្សេងទៀត សម្រាប់គាំទ្រដល់បេសកកម្មរបស់ក្រសួងអធិការកិច្ច ឱ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយ ព្រមទាំងពង្រឹងប្រព័ន្ធការងារគ្រប់ផ្នែក គ្រប់ថ្នាក់ ឈរលើមូលដ្ឋានសកម្ម បុរេសកម្ម និងអន្តរសកម្ម។

៦- បង្កើនសមត្ថភាពវិជ្ជាជីវៈមន្ត្រីគ្រប់ផ្នែក គ្រប់ថ្នាក់ តាមរយៈការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព និងពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ ការទទួលខុសត្រូវ ភាពថ្លៃថ្នូរ ប្រកបដោយសុចរិតភាព និងមានមនសិការចំពោះជាតិ និងប្រជាជន។

៧- ជំរុញ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិនិងអន្តរជាតិ តាមរយៈការគាំទ្រហិរញ្ញវត្ថុ និងសម្ភារៈ ការផ្លាស់ប្តូរបទពិសោធ និងទស្សនកិច្ចសិក្សា ជាដើម។

៨- ជំរុញ និងពង្រឹងប្រសិទ្ធភាពការធ្វើទំនើបកម្មស្ថាប័ន និងការគាំទ្រដល់វិស័យអធិការកិច្ចតាមរយៈការងារឌីជីថល។

## ៤. វិសាលភាព

យុទ្ធសាស្ត្រ «៣៤ជ៤» មានវិសាលភាពអនុវត្តក្នុងក្របខ័ណ្ឌក្រសួងអធិការកិច្ច និងវិស័យអធិការកិច្ច នៃព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី៣
# សាវតារ វឌ្ឍនភាព និងបញ្ហាប្រឈម

វិស័យអធិការកិច្ចបានឆ្លងកាត់ការវិវត្តជាច្រើនដំណាក់កាល តាំងពីសម័យសង្គមរាស្ត្រនិយមកន្លងមក ដោយបានអនុវត្តតួនាទីភារកិច្ចអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានតាមដំណាក់កាលនីមួយៗ។ វិស័យអធិការកិច្ចក៏បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់

អភិបាលកិច្ចល្អ និងពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ តាមរយៈវឌ្ឍនភាពការងារសំខាន់ៗនាពេលកន្លងមក។ ទន្ទឹមនឹងនេះ វិស័យអធិការកិច្ចបាននិងកំពុងជួបបញ្ហាប្រឈមមួយចំនួនគួរឱ្យកត់សម្គាល់ ដែលទាមទារនូវដំណោះស្រាយជាយុទ្ធសាស្ត្រ ដើម្បីអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងវិស័យអធិការកិច្ច។

## ផ្នែកទី១៖ សាវតារ

សម័យសង្គមរាស្ត្រនិយម បានបង្កើតស្ថាប័នអធិការកិច្ចមានឈ្មោះថា គណៈកម្មាធិការជាតិនៃការបោសសម្អាតទូទៅ តាមព្រះរាជក្រឹត្យលេខ៤១៧/៦៩-ប.រ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៦៩ ដែលមាន សម្តេចថៅហ្វាវាំង ប៉ែន នុត នាយករដ្ឋមន្ត្រី ជាប្រធាន ដោយមានសមាជិកគណៈរដ្ឋមន្ត្រី និងអនុរដ្ឋលេខាធិការ ជាសមាជិក។ បេសកកម្មរបស់គណៈកម្មាធិការនេះ ត្រូវបានកំណត់ឱ្យពិនិត្យនូវសំណុំរឿងមន្ត្រី និងភ្នាក់ងាររាជការស៊ីវិល ឬទាហាន ភ្នាក់ងាររបស់អង្គការ ឬសហគ្រាសសាធារណៈ ឬអឌ្ឍសាធារណៈ ដែលចូលជាកម្មវត្ថុនៃវិធានការបោសសម្អាត និងដាក់ទណ្ឌកម្មទាំងឡាយតាមកំហុសនៃមន្ត្រី និងភ្នាក់ងារទាំងនោះ។ នៅសម័យសាធារណរដ្ឋខ្មែរ ដែលដឹកនាំដោយសេនាប្រមុខ លន់ នល់ (១៩៧០-១៩៧៥) ការងារអធិការកិច្ច មានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ មាត្រា១១១ ថា «អភិបាលរដ្ឋ មានមុខងារត្រួតពិនិត្យ និងធ្វើអង្កេតលើបុគ្គលិកនៃអង្គការសាធារណៈ និងឯកជន ដែលជាប់ទាក់ទិនក្នុងរឿងស៊ីសំណូក រឿងពុករលួយ រឿងប្រើអំណាចដោយរំលោភ រឿងរត់គយ រឿងស្តុកទំនិញខុសច្បាប់ រឿងតម្លើងថ្លៃខុសច្បាប់ រឿងប្រដេញប្រដែងដោយវៀចវេរ និងរឿងចងការប្រាក់យកលើសកម្រិតច្បាប់»។ សម័យកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ដែលដឹកនាំដោយ ប៉ុល ពត ពុំមានស្ថាប័នអធិការកិច្ច និងគ្មានលិខិតបទដ្ឋានចែងអំពីការងារអធិការកិច្ចទេ ប៉ុន្តែអង្គការ កម្មាភិបាល និងសន្តិបាលក្នុងរបបនោះ ដើរតួនាទីជាអ្នកឃ្លាំមើល តាមដាន លួចស្តាប់ ដើម្បីរកកំហុស ដាក់ទោស និងសម្លាប់ដោយគ្មាន តុលាការកាត់ទោស ពោលគឺមន្ត្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យគ្រប់រូបមានតួនាទីជាមន្ត្រីអធិការកិច្ច និងជាតុលាការ។ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា-រដ្ឋកម្ពុជា នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាបានបង្កើតរដ្ឋធម្មនុញ្ញថ្មី ហើយបានប្តូរឈ្មោះក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ទៅជា «ក្រុមប្រឹក្សារដ្ឋមន្ត្រី» ដែលជាស្ថាប័នកំពូលនៃអង្គនីតិប្រតិបត្តិ និងមានក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ ជាស្ថាប័នមួយរបស់រដ្ឋាភិបាល ចំណុះក្រុមប្រឹក្សារដ្ឋមន្ត្រីផងដែរ។ ដើម្បីឱ្យក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ អនុវត្តសកម្មភាពរបស់ខ្លួនលើការងារ ត្រួតពិនិត្យពីមជ្ឈិមដល់មូលដ្ឋានមានប្រសិទ្ធភាពខ្ពស់ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានចេញនូវលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តបន្តបន្ទាប់គឺ សេចក្តីសម្រេចលេខ១៥ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៨១ របស់ក្រុមប្រឹក្សារដ្ឋ ស្តីពីការកំណត់អំពីមុខងារសិទ្ធិអំណាច ភារកិច្ចនៃក្រសួងត្រួតពិនិត្យរបស់រដ្ឋាភិបាល ក្រឹត្យលេខ០៣ ក្រ.ច ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២ របស់ក្រុមប្រឹក្សារដ្ឋ ប្រកាសឱ្យប្រើច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលត្រង់មាត្រា៤២ បានចែងច្បាស់អំពីភារកិច្ចទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ អនុក្រឹត្យលេខ០២ អនក្រ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៨២ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការប្រកាសឱ្យប្រើលក្ខន្តិកៈនៃការចាត់តាំង និងសកម្មភាពរបស់ក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ អនុក្រឹត្យលេខ៧៣ អនក្រ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៨៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការចាត់តាំងបណ្តាញត្រួតពិនិត្យតាមក្រសួង ខេត្ត-ក្រុង ជុំវិញមជ្ឈិម។ នៅសម័យប្រជុំលើកទី៣ នីតិកាលទី១ នាថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៨២ រដ្ឋសភា បានអនុម័តច្បាប់ស្តីពីការការពារទ្រព្យសម្បត្តិរដ្ឋ និងច្បាប់ស្តីពីការពិនិត្យ និងដោះស្រាយ បណ្តឹងតវ៉ានិងបណ្តឹងបរិហារ

របស់ពលរដ្ឋ ហើយក្រុមប្រឹក្សារដ្ឋបានប្រកាសឱ្យប្រើតាមក្រឹត្យលេខ១០ក្រ និងលេខ១១ក្រ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៨២ សារាចរណែនាំបន្ថែមលេខ០៣ សរណ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៨៤ ស្តីពីការអនុវត្តច្បាប់ស្តីពីការពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ានិងបណ្តឹងបរិហាររបស់ពលរដ្ឋ ឱ្យបានត្រឹមត្រូវ និងកាន់តែប្រសើរឡើង។ បន្ថែមលើនេះ មានក្រឹត្យ-ច្បាប់លេខ៣១ ក្រ.ច ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៨៧ ស្តីពីការបង្កើតទីស្តីការក្រសួងត្រួតពិនិត្យ (ប្តូរឈ្មោះពីក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋទៅជាក្រសួងត្រួតពិនិត្យវិញ) អនុក្រឹត្យលេខ១៥ អនក្រ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៨៧ ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ (នៅតាម ទីស្តីការរដ្ឋមន្ត្រី រួមទាំងទីស្តីការរដ្ឋមន្ត្រីក្រសួងការពារប្រទេស និងក្រសួងមហាផ្ទៃ ស្ថាប័នថ្នាក់ប្រហាក់ប្រហែល ទីស្តីការរដ្ឋមន្ត្រី ខេត្ត-ក្រុងចំណុះមជ្ឈិម ទីរួមខេត្ត ខណ្ឌ ស្រុក ស្រុកជាយក្រុង) អនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៨៧ ស្តីពីការចាត់តាំងគណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជននៅតាមមូលដ្ឋាន ឃុំ សង្កាត់សហគ្រាសផលិតកម្ម អាជីវកម្ម មន្ទីរពេទ្យ សាលារៀន...ណាដែលចាំបាច់និងមានលទ្ធភាពឱ្យឈ្មោះថា «គណៈកម្មាធិការ ត្រួតពិនិត្យរបស់ប្រជាជន» អនុក្រឹត្យលេខ១៧ អនក្រ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៨៧ ស្តីពីការចាត់តាំង និងសកម្មភាពរបស់ទីស្តីការរដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ។ ក្រសួងត្រួតពិនិត្យមានមុខងារត្រួតពិនិត្យការអនុវត្ត គោលនយោបាយ ផែនការរបស់រដ្ឋ សំដៅបង្កើននូវវិន័យ លើកកម្ពស់ស្មារតីទទួលខុសត្រូវ រួមចំណែកកែលម្អ ការចាត់តាំង និងរបៀបរបបធ្វើការងាររបស់ស្ថាប័ន និងអង្គការរដ្ឋពីមជ្ឈិមរហូតដល់មូលដ្ឋាន។ ចំពោះតួនាទី ភារកិច្ច ទំនាក់ទំនង និងរបៀបរបបធ្វើការដាក់ស្តែងរបស់មន្ទីរ បណ្តានាយកដ្ឋាន សាលាមុខជំនាញត្រួតពិនិត្យ និងការិយាល័យ ចាត់តាំងកម្មាភិបាល អាស្រ័យលើរដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ កំណត់ សម្រេច និងដាក់ចេញឱ្យអនុវត្ត។

នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៤ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៣០ អនក្រ.បក ស្តីពីការកំណត់ភារកិច្ច និងសមត្ថកិច្ច របស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអធិការកិច្ច និងអនុក្រឹត្យលេខ៤៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋានអធិការកិច្ចរបស់រាជរដ្ឋាភិបាល ដែលមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធ្វើជាសេនាធិការឱ្យទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច ហើយយោងតាមអនុក្រឹត្យខាងលើ អង្គភាពអធិការកិច្ច រាជរដ្ឋាភិបាលបានចេញប្រកាសលេខ១៣២ ប្រក.អធក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកំណត់អំពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់អង្គភាពអធិការកិច្ចរាជរដ្ឋាភិបាល និងក្រុមអធិការកិច្ចជំនួយការ។

ដើមអាណត្តិទី២ ឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៨០ អនក្រ-បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការផ្ទេររដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា និងអគ្គលេខាធិការដ្ឋានអធិការកិច្ចរបស់រាជរដ្ឋាភិបាល ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច។ នៅសម័យប្រជុំលើកទី២ នីតិកាលទី២ នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៩៩ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ហើយព្រះមហាក្សត្របានចេញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់នេះ។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃ០៣ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។ ក្នុងនីតិកាលទី៤ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយ

រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជំនួសអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៩ ដោយបានកែសម្រួលតួនាទីនិងភារកិច្ច និងរចនាសម្ព័ន្ធ ក្នុងនោះ ការបង្កើតវិទ្យាស្ថានជាតិអធិការកិច្ច ដើម្បីផ្ដល់ការបណ្ដុះបណ្ដាល វិក្រឹតការ សុក្រឹតការថ្នាក់បឋម មធ្យម និងឧត្ដម ជូនដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងនិស្សិតក្នុងវិស័យអធិការកិច្ច និងវិស័យពាក់ព័ន្ធ។

ក្នុងនីតិកាលទី៧ នៃរដ្ឋសភា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចត្រូវបានប្ដូរឈ្មោះទៅជាក្រសួងអធិការកិច្ច តាមរយៈព្រះរាជក្រមលេខ នស/រកម/១០២៣/០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអធិការកិច្ច ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣ ហើយលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងវិស័យអធិការកិច្ចត្រូវបាននិងកំពុងរៀបចំបង្កើតថ្មី ឬកែសម្រួលឡើងវិញជាបន្តបន្ទាប់។ ក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងអធិការកិច្ចបានបញ្ចប់ការងារវិភាគមុខងារ និងការពិនិត្យ ឡើងវិញនូវរចនាសម្ព័ន្ធ នៅដំណាក់កាលទី១ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។ មុខងារនិងភារកិច្ច និងរចនាសម្ព័នរបស់ក្រសួងត្រូវបានកែសម្រួលឡើងវិញ ដូចមានកំណត់ក្នុងអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច។

## ផ្នែកទី២៖ វឌ្ឍនភាព

### I. ការងារអធិការកិច្ច

ការងារអធិការកិច្ច ដែលជាការងារស្នូលមួយ ក្នុងចំណោមការងារស្នូលទាំង៤របស់ក្រសួងអធិការកិច្ច បានចូលរួមលើកកម្ពស់អភិបាលកិច្ចល្អ និងគុណភាពស្ថាប័នសាធារណៈ ដើម្បីបង្កើនប្រសិទ្ធភាព ភាពស្អាតស្អំ ពង្រឹងយុត្តិធម៌សង្គម និងការអភិវឌ្ឍជាតិ។

#### ក- រចនាសម្ព័ន្ធ

ផ្អែកតាមអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រចនាសម្ព័ន្ធលើមុខងារអធិការកិច្ច មានត្រឹមមួយនាយកដ្ឋានប៉ុណ្ណោះ និងត្រូវបានសម្រួលជាបីនាយកដ្ឋានរួមមាន (១)នាយកដ្ឋានអធិការកិច្ចទី១ (អតីតនាយកដ្ឋានអធិការកិច្ច) ធ្វើអធិការកិច្ចលើវិស័យសេដ្ឋកិច្ច សន្តិសុខ និងការពារជាតិ នៅតាមក្រសួង ស្ថាប័ន និងមន្ទីរអង្គភាពនៅរាជធានី ខេត្ត (២)នាយកដ្ឋានអធិការកិច្ចទី២ (អតីតនាយកដ្ឋានទំនាក់ទំនងជាមួយអធិការកិច្ចតាមបណ្ដាស្ថាប័ន) ធ្វើអធិការកិច្ចលើវិស័យរដ្ឋបាល នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត (៣)នាយកដ្ឋានអធិការកិច្ចទី៣ (អតីតនាយកដ្ឋានវិវាទកម្ម) ធ្វើអធិការកិច្ចលើវិស័យសង្គមកិច្ច នៅតាមក្រសួង ស្ថាប័ន និងមន្ទីរអង្គភាពនៅរាជធានីខេត្ត តាមរយៈអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

ក្នុងនីតិកាលទី៧ នៃរដ្ឋសភានេះ រចនាសម្ព័ន្ធមុខងារអធិការកិច្ច ត្រូវបានកែសម្រួលឈ្មោះទៅជា (១)នាយកដ្ឋានអធិការកិច្ចលើវិស័យសេដ្ឋកិច្ច សន្តិសុខ និងការពារជាតិ (២)នាយកដ្ឋានអធិការកិច្ចលើវិស័យរដ្ឋបាល

(៣)នាយកដ្ឋានអធិការកិច្ចលើវិស័យសង្គមកិច្ច តាមរយៈអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច។

## ខ- មុខងារអធិការកិច្ច

ស្របតាមច្បាប់ស្តីពីការបង្កើតក្រសួង និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ចាប់តាំងពីបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចនៅឆ្នាំ១៩៩៨ រាជរដ្ឋាភិបាល បានប្រគល់បេសកកម្មឱ្យដឹកនាំ គ្រប់គ្រង និងធ្វើការងារអធិការកិច្ចលើគ្រប់វិស័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅបង្ការ ទប់ស្កាត់ កែលម្អ និងមានវិធានការ ដើម្បីប្រឆាំងនឹងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា។ ការចុះធ្វើអធិការកិច្ចរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចក្នុងរូបភាព តាមផែនការ តាមបណ្តឹង និងតាមចៃដន្យ។ ទន្ទឹមនឹងនេះ ដោយសារមានការវិវត្តន៍ក្នុងការងារត្រួតពិនិត្យក្នុងដែនសមត្ថកិច្ចរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គភាពត្រួតពិនិត្យ មានផ្សេងទៀត។ ដោយសារបទប្បញ្ញត្តិគតិយុត្តមិនទាន់គ្រប់គ្រាន់ ការបំពេញតួនាទីភារកិច្ចរបស់ស្ថាប័ន និងអង្គភាពត្រួតពិនិត្យទាំងអស់ មិនទាន់ត្រូវបានបែងចែកច្បាស់លាស់។ ក្នុងគោលបំណងដោះស្រាយបញ្ហាស្ទួនមុខងារចុះធ្វើអធិការកិច្ចរបស់ស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដោយបានកំណត់មុខងារអធិការកិច្ចរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ធ្វើអធិការកិច្ចលើគ្រប់វិស័យស្របតាមអនុក្រឹត្យលេខ០៣ អនក្រ.បក និងដោយផ្អែកលើអភិក្រមដូចខាងក្រោម៖

- តាមបណ្តឹងតវ៉ា និងបណ្តឹងបរិហារពីនីតិបុគ្គល រូបវន្តបុគ្គល និងគ្រប់មជ្ឈដ្ឋាន
- តាមបណ្តឹងរបស់ស្ថាប័នវេងអធិការកិច្ចលើលទ្ធផលអធិការកិច្ចរបស់ក្រសួង ស្ថាប័ន
- ផ្អែកលើហានិភ័យ បណ្តឹងតវ៉ា ឬភាពចាំបាច់ក្នុងការផ្ទៀងផ្ទាត់ព័ត៌មាន ឬរបាយការណ៍ពាក់ព័ន្ធ
- តាមសំណើរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- មានភាពមិនប្រក្រតីលើរបាយការណ៍លទ្ធផលអធិការកិច្ច
- តាមដាននូវរាល់វិធានការដែលអធិការកិច្ចបានដាក់ចេញដល់ស្ថាប័នវេងអធិការកិច្ច និង
- តាមបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល។

អនុក្រឹត្យនេះ បានបំពេញបន្ថែមនូវមុខងារអធិការកិច្ចមួយចំនួន ដែលពុំបានចែងនៅក្នុងអនុក្រឹត្យលេខ០៣ អនក្រ.បក ដែលធ្វើឱ្យមុខងារអធិការកិច្ចរបស់ក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច កាន់តែទូលំទូលាយ។

ចាប់ពីការប្តូរឈ្មោះក្រសួង មកជាក្រសួងអធិការកិច្ច និងអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច មុខងារអធិការកិច្ច ត្រូវបានរក្សាដដែលតាមស្មារតីនៃអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ដោយគ្រាន់តែមានការកែសម្រួលពាក់ព័ន្ធការធ្វើអធិការកិច្ចក្នុងវិស័យសន្តិសុខ និងការពារជាតិ ដែលបានកំណត់ថា ការធ្វើអធិការកិច្ច

និងតាមដានការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យនេះ អនុវត្តតាមបញ្ញាប្ញការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល។

### គ- អនុសាសន៍តម្រង់ទិសរបស់សម្តេចធិបតី

ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍តម្រង់ទិសដ៏ខ្ពង់ខ្ពស់លើការងារដឹកនាំ និងគ្រប់គ្រងវិស័យអធិការកិច្ច ដូចខាងក្រោម៖

ទី១. ក្រសួងអធិការកិច្ច ត្រូវដើរតួនាទីគន្លឹះសំខាន់ជួយរាជរដ្ឋាភិបាលក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ក្នុងការលើកកម្ពស់ និងការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ ដោយផ្តោតអាទិភាពលើការពង្រឹងយន្តការគ្រប់គ្រង និងផ្តល់សេវាសាធារណៈ ការផ្តល់ការលើកទឹកចិត្តផ្អែកលើគុណាធិបតេយ្យ និងការចាត់វិធានការម៉ឺងម៉ាត់តាមច្បាប់ក្នុងការដាក់ទណ្ឌកម្មវិន័យ និងវិធានការច្បាប់ចំពោះមន្ត្រីសាធារណៈដែលប្រព្រឹត្តបំពានក្រមសីលធម៌វិជ្ជាជីវៈ បំពានអំណាចក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន។

ទី២. ក្រសួងអធិការកិច្ច ត្រូវផ្តួចផ្តើម និងនាំមុខក្នុងការរៀបចំយន្តការត្រួតពិនិត្យប្រកបដោយគុណភាព ប្រសិទ្ធភាព ព្រមទាំងសុខដុមនីយកម្មនៃមុខងារអធិការកិច្ចនៅក្នុងរដ្ឋបាលសាធារណៈ។ លើសពីនេះ ក្រសួងអធិការកិច្ច ត្រូវយកចិត្តទុកដាក់នូវកិច្ចការមួយចំនួនដូចខាងក្រោម៖

១) ពង្រឹងទំនាក់ទំនង និងកិច្ចសហការល្អជាមួយអង្គភាពអធិការកិច្ចចំណុះក្រសួង ស្ថាប័ន តាមរយៈការណែនាំឱ្យបានស៊ីជម្រៅលើការងារជំនាញ ការរៀបចំនីតិវិធី និងស្តង់ដាជាតិអធិការកិច្ច ព្រមទាំងជួយបណ្តុះបណ្តាលជំនាញអធិការកិច្ចឱ្យបានទូលំទូលាយ

២) រួមគ្នាដោះស្រាយបញ្ហាប្រឈមនានា ដែលបានកើតមានក្នុងវិស័យអធិការកិច្ច ដោយមានការចូលរួមពីក្រសួង ស្ថាប័ន និងអង្គភាពរងអធិការកិច្ច

៣) គោរពតាមឋានានុក្រមនៃការងារអធិការកិច្ច មានន័យថា ក្រសួងអធិការកិច្ច ជាអធិការកិច្ចថ្នាក់រាជរដ្ឋាភិបាល ដែលធ្វើអធិការកិច្ចលើគ្រប់វិស័យ នៅគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទី៣. ក្រសួងអធិការកិច្ច ត្រូវបន្តលើកកម្ពស់ និងពង្រឹងស្ថាប័នបន្ថែមទៀត ដោយផ្តោតលើ៖

១) ការកសាងមូលធនមនុស្សដោយពង្រឹងសមត្ថភាពមន្ត្រីប្រកបដោយមនសិការ និងក្រមសីលធម៌វិជ្ជាជីវៈ

២) ពង្រឹងការអនុវត្តតួនាទីអធិការកិច្ចឱ្យបានទូលំទូលាយ ស្មើភាព និងមិនរើសអើង ប្រកបដោយភាពម៉ឺងម៉ាត់ គោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។

ទី៤. ក្នុងទស្សនៈ «អធិការកិច្ចដើម្បីទាំងអស់គ្នា ទាំងអស់គ្នាឆ្ពោះទៅកាន់អភិបាលកិច្ចល្អ» ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពសាធារណៈទាំងអស់ ត្រូវចូលរួមសហការឱ្យបានល្អក្នុងការងារអធិការកិច្ចដ៏មានសារៈសំខាន់នេះ ដោយប្រែក្លាយពាក្យស្លោករបស់សម្តេចតេជោ «អធិការកិច្ចជាភ្នែក ជាត្រចៀករបស់ថ្នាក់លើ

និងជាមិត្តដ៏ជិតស្និទ្ធរបស់ថ្នាក់ក្រោម» ជាបេសកកម្មរបស់ក្រសួងអធិការកិច្ច ក៏ដូចជាបេសកកម្មរបស់អង្គភាពអធិការកិច្ចគ្រប់ជាន់ថ្នាក់។

ទី៥. ពង្រឹងយន្តការ របៀបរបបការងារ គោលការណ៍ប្រតិបត្តិស្តង់ដា ប្រព័ន្ធការងារក្នុងវិស័យអធិការកិច្ចឱ្យបានច្បាស់លាស់ និងសម្របសម្រួលយន្តការដែលមានស្រាប់ ចៀសវាងការត្រួតស៊ីគ្នា ដោយធ្វើយ៉ាងណាឱ្យការងារអធិការកិច្ច សវនកម្ម និងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្ម មានសង្គតិភាព ភាពប្រទាក់ក្រឡាភាពធន់ ប្រសិទ្ធភាព និងនិរន្តរភាពការងារ។

ទី៦. ការងារអធិការកិច្ច គឺជាកិច្ចការងារសំខាន់ ដែលបានជួយដល់អភិក្រមចំនួន៤ ក្នុងចំណោមអភិក្រមទាំង៥របស់សម្តេចតេជោ និងស្នើឱ្យក្រសួង ស្ថាប័នទាំងអស់ កុំចាត់ទុកការងារអធិការកិច្ចគឺជាការចាប់កំហុស ផ្ទុយទៅវិញគឺជាការតាមដានត្រួតពិនិត្យ និងជួយដល់ការពង្រឹងប្រសិទ្ធភាពការងាររបស់ស្ថាប័ន។ ក្នុងន័យនេះ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធាននៅតាមបណ្តាស្ថាប័ន អង្គភាពនានា និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវផ្តល់កិច្ចសហការល្អជាមួយមន្ត្រីអធិការកិច្ច និងយករបាយការណ៍លទ្ធផលអធិការកិច្ចជាមូលដ្ឋានក្នុងការកែតម្រូវនូវចំណុចខ្វះខាត ឬជាមូលដ្ឋាននៃការលើកសរសើរ។

ទី៧. ក្រសួងអធិការកិច្ច ដែលមានវិទ្យាស្ថានជាតិអធិការកិច្ចជាសេនាធិការ ត្រូវពង្រឹងការអភិវឌ្ឍសមត្ថភាពមន្ត្រីអធិការកិច្ច ដើម្បីបំពេញតួនាទី ភារកិច្ចអធិការកិច្ចឱ្យមានប្រសិទ្ធភាព។

ទី៨. ក្រសួងអធិការកិច្ច ត្រូវសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការពង្រឹងការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការរបស់ខ្លួន ជាពិសេសលើផ្នែកអក្ខរកម្មឌីជីថល ដើម្បីជំរុញការធ្វើបរិវត្តកម្មឌីជីថលអធិការកិច្ច ក្នុងបរិបទឌីជីថល និងធ្វើទំនើបកម្មស្ថាប័ន សំដៅឈានដល់ការសម្រេចអធិការកិច្ចដោយប្រើបច្ចេកវិទ្យាឌីជីថល។

## ឃ- សកម្មភាព និងលទ្ធផលអធិការកិច្ច

### ១- សកម្មភាព

ដើម្បីឆ្លើយតបនឹងការកែទម្រង់របស់រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួងអធិការកិច្ចដាក់ចេញនូវផែនការ និងធ្វើសកម្មភាពសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- បានបង្កើតក្រុមការងាររៀបចំបទបញ្ជាផ្ទៃក្នុងសម្រាប់គណៈប្រតិភូអធិការកិច្ច និងតាមដានការអនុវត្តច្បាប់ក្រមសីលធម៌មន្ត្រីរាជការអធិការកិច្ច គំរូផែនការប្រតិបត្តិនិងសេចក្តីព្រាងវិធាននិងនីតិវិធីអធិការកិច្ចសម្រាប់អនុវត្តផ្ទៃក្នុងក្រសួងអធិការកិច្ច
- បានប្រជុំពិភាក្សា ពិនិត្យ និងកែសម្រួលលើបទបញ្ជាផ្ទៃក្នុងសម្រាប់គណៈប្រតិភូអធិការកិច្ចនិងតាមដានការអនុវត្តច្បាប់ និងក្រមសីលធម៌មន្ត្រីរាជការអធិការកិច្ច
- បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីវិធាន និងនីតិវិធីអធិការកិច្ច ក្នុងនោះបានរៀបចំទម្រង់ផែនការប្រតិបត្តិ កំណត់ហេតុអធិការកិច្ច របាយការណ៍ស្តីពីការបូកសរុបលទ្ធផលអធិការកិច្ច និងគំរូសេចក្តីជូនដំណឹងស្តីពីការជំរុញការកែលម្អចំណុចខ្វះខាតដែលគណៈប្រតិភូបានពិនិត្យឃើញ
- បានបង្កើតក្រុមការងារតាមដានព័ត៌មាននៅលើគ្រប់បណ្តាញព័ត៌មាន
- បានស្រង់ព័ត៌មាននៅលើគ្រប់បណ្តាញព័ត៌មាននិងបណ្តាញសង្គម

- បានប្រជុំពិភាក្សាស្តីពីវឌ្ឍនភាពការងារអធិការកិច្ចជាមួយអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន
- បានចូលរួមសិក្ខាសាលា ពិគ្រោះយោបល់ស្តីពីគោលការណ៍ណែនាំរួមសម្រាប់ធ្វើអធិការកិច្ច។

ក្រសួងអធិការកិច្ចបានធ្វើប្រតិបត្តិការអធិការកិច្ចតាម៣រូបភាព ដូចខាងក្រោម៖

**រូបភាពទី១ ៖** ចូលរួមជាមួយគណៈកម្មការចម្រុះអន្តរក្រសួង ដែលសម្រេចដោយប្រមុខរាជរដ្ឋាភិបាល។ រូបភាពនេះ ធ្វើឡើងចំពោះតែបញ្ហាណាដែលមានសារៈសំខាន់ជាអាទិភាព និងមានលក្ខណៈស្មុគស្មាញ។ ក្រសួងបានចូលរួមជាមួយគណៈកម្មការចម្រុះអន្តរក្រសួងជាច្រើនករណីដូចជា គណៈកម្មាធិការទប់ស្កាត់និងបង្ក្រាបការទន្ទ្រានដីព្រៃលិចទឹកនៅតំបន់បឹងទន្លេសាប និង គណៈកម្មការចំពោះកិច្ចត្រួតពិនិត្យនិងដោះស្រាយបញ្ហាដំណើរចេញចូលរបស់ពលករខ្មែរ តាមព្រំដែននៃព្រះរាជាណាចក្រកម្ពុជាជាដើម។

**រូបភាពទី២ ៖** ចាត់តាំងមន្ត្រីអធិការកិច្ចចូលរួមការងារជាមួយក្រសួង ស្ថាប័ននានា ឬស្នើសុំមន្ត្រីជំនាញសហការជាមួយក្រសួងអធិការកិច្ចដូចជា ការចូលរួមជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ករណីបង្ក្រាបបទល្មើសជលផល អញ្ជើញមន្ត្រីជំនាញក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចូលរួមករណីវិវាទដីធ្លី អញ្ជើញថ្នាក់ដឹកនាំក្រសួងពាក់ព័ន្ធចូលដោះស្រាយករណីធ្វើឱ្យប៉ះពាល់តំបន់ធម្មជាតិភ្នំ១៥០០ជាដើម។

**រូបភាពទី៣ ៖** ចាត់តាំងគណៈប្រតិភូដែលចេញលិខិតបញ្ជាបេសកកម្មដោយក្រសួងអធិការកិច្ច។

## ២-លទ្ធផល

តាមសកម្មភាពអធិការកិច្ចខាងលើ ក្រសួងបានរកឃើញចំណុចខ្វះខាត ហើយបានស្នើឱ្យកែលម្អនិងចាត់វិធានការមួយចំនួនដូចខាងក្រោម៖

- បានដាក់វិន័យរដ្ឋបាលដល់មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ និងចាត់បញ្ជូនទៅតុលាការចំពោះបទល្មើសធ្ងន់ធ្ងរ ដូចជាករណីប្រព្រឹត្តបទល្មើសព្រៃឈើ បទល្មើសជលផល ការបំផ្លិចបំផ្លាញធនធានរ៉ែជាដើម
- បង្ខំឱ្យសង និងបង់ចូលថវិការដ្ឋវិញ ដូចជាករណីកិបកេងទ្រព្យសម្បត្តិរដ្ឋ ចំណូលថវិការបស់រដ្ឋ និងការបញ្ជាចំណាយខុសគោលដៅជាដើម
- បង្ខំឱ្យម្ចាស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចអនុវត្តកាតព្វកិច្ចបង់ថវិកាចូលរដ្ឋតាមកិច្ចសន្យា
- ណែនាំឱ្យបំពេញតួនាទី ភារកិច្ច តាមសមត្ថកិច្ចរបស់ខ្លួនឱ្យបានល្អ
- ណែនាំឱ្យគ្រប់គ្រង និងចាត់ចែងថវិការដ្ឋសមស្របតាមគោលការណ៍ហិរញ្ញវត្ថុ
- ណែនាំឱ្យខិតខំប្រមូលចំណូលមិនមែនសារពើពន្ធ និងចំណូលសារពើពន្ធឱ្យអស់លទ្ធភាព
- ណែនាំឱ្យក្រសួង ស្ថាប័ន និងអង្គភាពមួយចំនួនចាត់វិធានការតឹងទារបំណុលពុំរ៉ែដែលអតិថិជនបានជំពាក់
- ណែនាំឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ

- ណែនាំឱ្យស្ថាប័នរដ្ឋបង្កើនការគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិរដ្ឋឱ្យបានល្អតាមការណែនាំរបស់រាជរដ្ឋាភិបាល
- បានធ្វើសេចក្តីជូនដំណឹងដល់ប្រធានស្ថាប័ន ឱ្យជួយជំរុញដល់អង្គភាពក្រោមឱវាទកែលម្អនូវចំណុចខ្វះខាតតាមវិធានការអធិការកិច្ចដែលបានរកឃើញ។

ជារួម ក្រសួង ស្ថាប័ន និងអង្គភាពដែលរងអធិការកិច្ចបានយកចិត្តទុកដាក់អនុវត្តតួនាទី ភារកិច្ច ស្របតាមច្បាប់ លិខិតបទដ្ឋានគិតយុត្តពាក់ព័ន្ធ បានចាត់វិធានការចំពោះអង្គភាពក្រោមអាណាព្យាបាល ឱ្យពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ, បានកែលម្អនីតិវិធីនៃការផ្តល់សេវាសាធារណៈ និងបានពង្រឹងប្រសិទ្ធភាពការងារមន្ទីរ-អង្គភាព លើការងារសាងសង់ ថែទាំ ជួសជុលផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ ទំនប់ទន្លេ ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងមានគុណភាព។ ក្រៅពីការជំរុញអភិបាលកិច្ចល្អ ភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ ការធ្វើអធិការកិច្ចក៏បានចូលរួមក្នុងការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាជាតិ និងបង្កើនចំណូលថវិកាជាតិផងដែរ។

## II. ការងារទទួលពិនិត្យនិងដោះស្រាយបណ្តឹង

### ក- រចនាសម្ព័ន្ធ

ផ្អែកតាមអនុក្រឹត្យលេខ២៦៧ អនក្រ.បក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៩ និងអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រចនាសម្ព័ន្ធលើមុខងារទទួលនិងដោះស្រាយបណ្តឹង មានកំណត់នៅក្នុងនាយកដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ចំណុះអគ្គនាយកដ្ឋានអធិការកិច្ច ដែលមានភារកិច្ច (១)ទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ និងពីមជ្ឈដ្ឋាននានា រួមទាំងពិនិត្យបាតុភាពអសកម្មផ្សេងៗទៀត តាមរយៈប្រព័ន្ធព័ត៌មាន ដើម្បីចុះអង្កេតស្រាវជ្រាវ ឬបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ច (២)អង្កេតស្រាវជ្រាវបណ្តឹងតវ៉ា បណ្តឹងបរិហារដែលស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល (៣)អង្កេតស្រាវជ្រាវឡើងវិញនូវលទ្ធផលដោះស្រាយបណ្តឹងរបស់ថ្នាក់ក្រោមដែលមានការតវ៉ាថាមិនត្រឹមត្រូវ (៤)រៀបចំសំណុំរឿងពាក់ព័ន្ធនឹងការងារអង្កេតស្រាវជ្រាវ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលអនុវត្តខុសតួនាទី ឬរំលោភអំណាច ធ្វើឱ្យប៉ះពាល់ដល់នយោបាយ សេដ្ឋកិច្ច ឬថវិកាជាតិ (៥)តាមដានការដោះស្រាយបណ្តឹង និងគៀនទារលទ្ធផលនៃការដោះស្រាយបណ្តឹងដែលបានបញ្ជូនឱ្យសមត្ថកិច្ចពាក់ព័ន្ធពិនិត្យដោះស្រាយ (៦)តាមដានការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងលទ្ធផលនៃការដោះស្រាយបណ្តឹង។

ក្នុងនីតិកាលទី៧ នៃរដ្ឋសភានេះ ដោយមើលឃើញពីភាពចាំបាច់នៃការងារបណ្តឹង រាជរដ្ឋាភិបាលបានសម្រេចសម្រួលរចនាសម្ព័ន្ធនិងមុខងារភារកិច្ចរបស់នាយកដ្ឋានទទួលពាក្យបណ្តឹងនិងអង្កេតស្រាវជ្រាវ ទៅជាអគ្គនាយកដ្ឋានដោះស្រាយបណ្តឹង។ អគ្គនាយកដ្ឋានដោះស្រាយបណ្តឹង មានមុខងារនិងភារកិច្ច ទទួលពាក្យបណ្តឹងតវ៉ានិងបណ្តឹងបរិហារ អំពីនីតិបុគ្គលនិងរូបវន្តបុគ្គលសាធារណៈក្នុងក្របខ័ណ្ឌដែនសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល

ពីគ្រប់មជ្ឈដ្ឋានទាំងអស់ រួមទាំងពិនិត្យបាតុភាពអសកម្មផ្សេងៗពីមជ្ឈដ្ឋាននានា តាមរយៈការទទួលបណ្តឹងដោយផ្ទាល់ ប្រព័ន្ធសារព័ត៌មាន ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន បណ្តឹងអនាមិក និងគ្រប់មធ្យោបាយ ដើម្បីចុះអង្កេតស្រាវជ្រាវ ដោះស្រាយ ឬបញ្ជូនទៅក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេង។

### ខ- លទ្ធផល

ពីឆ្នាំ១៩៩៩ដល់បច្ចុប្បន្ន ក្រសួងបានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ដោយបានទទួលពាក្យបណ្តឹងសរុបចំនួន២០៤២បណ្តឹង (ថ្នាក់កណ្តាលចំនួន១០១១បណ្តឹង និងថ្នាក់រាជធានី ខេត្តចំនួន១០៣១បណ្តឹង) ក្នុងនោះពាក្យបណ្តឹងដែលបានតម្កល់ទុកមិនចាត់ការចំនួន១៩៨បណ្តឹង (ថ្នាក់កណ្តាលចំនួន១៣០បណ្តឹង និងថ្នាក់រាជធានី ខេត្តចំនួន៦៨បណ្តឹង) ពាក្យបណ្តឹងដែលបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយមានចំនួន៦៣១ (ថ្នាក់កណ្តាលចំនួន៤១២បណ្តឹង និងថ្នាក់រាជធានី ខេត្តចំនួន២១៩បណ្តឹង) ពាក្យបណ្តឹងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួងចំនួន១៥៦បណ្តឹង (ថ្នាក់កណ្តាលចំនួន២បណ្តឹង និងថ្នាក់រាជធានី ខេត្តចំនួន១៥៤បណ្តឹង) និងពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួងមានចំនួន១២១១បណ្តឹង (ថ្នាក់កណ្តាលចំនួន៤៦៧បណ្តឹង និងថ្នាក់រាជធានី ខេត្តចំនួន៧៤៤បណ្តឹង) ក្នុងនោះក្រសួងអធិការកិច្ចបានដោះស្រាយបញ្ចប់មានចំនួន៦៨០បណ្តឹង (ថ្នាក់កណ្តាលចំនួន១៨១បណ្តឹង និងថ្នាក់រាជធានី ខេត្តចំនួន៤៩៩បណ្តឹង) ជាពាក្យបណ្តឹងមានភាពសាំញ៉ាំ ស្មុគស្មាញ រ៉ាំរ៉ៃ និងម្ចាស់បណ្តឹងបានដាក់ពាក្យបណ្តឹងទៅស្ថាប័នជាច្រើន ប៉ុន្តែមិនអាចដោះស្រាយបញ្ចប់បាន និងបណ្តឹងមួយចំនួនមានចរិតលក្ខណៈជាននយោបាយ និងបង្កភាពញុះញង់ដល់សង្គមជាតិ។

លទ្ធផលនៃការទទួលពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ានិងបណ្តឹងបរិហាររបស់ក្រសួងអធិការកិច្ច បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបង្ការ ទប់ស្កាត់ កែលម្អ និងប្រឆាំងនឹងការរំលោភអំណាច និងបាតុភាពអសកម្មនានាក្នុងសង្គម ដើម្បីពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ តម្លាភាព គណនេយ្យភាព អភិបាលកិច្ចល្អ និងយុត្តិធម៌សង្គម តាមរយៈការដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព ជាពិសេសការសម្រុះសម្រួល បញ្ចប់វិវាទដោយសន្តិវិធីស្របតាមយុទ្ធសាស្ត្រ និងនយោបាយឈ្នះ-ឈ្នះ។ ជាក់ស្តែង ក្រសួងបានដោះស្រាយបណ្តឹងប្រកបដោយប្រសិទ្ធភាពនិងទទួលបានភាពជោគជ័យ ទោះបីជាបណ្តឹងនោះមានភាពស្មុគស្មាញ រាំរ៉ៃជាច្រើនឆ្នាំ និងបានឆ្លងកាត់ការដោះស្រាយទាំងក្នុងប្រព័ន្ធតុលាការ និងយន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការផ្សេងទៀតក៏ដោយ។

## III. ការតាមដានការអនុវត្តច្បាប់

ក្រសួងមានមុខងារចូលរួមតាមដានការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទបញ្ជា អនុសាសន៍ និងសេចក្តីសម្រេចផ្សេងៗរបស់ប្រមុខរាជរដ្ឋាភិបាល នៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការតាមដានការអនុវត្តច្បាប់ក្នុងឆ្នាំ២០២៤កន្លងមក បានដំណើរការត្រួតពិនិត្យលើការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារ អន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធចំនួន៦ខេត្ត រួមមាន៖ ខេត្តកណ្តាល ខេត្តស្វាយរៀង ខេត្តព្រះសីហនុ ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តត្បូងឃ្មុំ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- មានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនមួយចំនួនត្រូវបានបង្កើតថ្មី ក្រោយពេលមានអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១

- ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនមួយចំនួន ដែលមានចែងក្នុងអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ត្រូវបានផ្អាកដំណើរការ
- លិខិតបទដ្ឋានគតិយុត្តថ្មីៗមួយចំនួន មានខ្លឹមសារផ្ទុយពីក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១។ អនុក្រឹត្យលេខ៦៤ នេះបានចូលជរមានជាង២៣ឆ្នាំមកហើយ។ ដើម្បីឆ្លើយទៅនឹងការវិវត្តជាបន្តបន្ទាប់នៃកត្តាសង្គម កត្តាសេដ្ឋកិច្ច និងកត្តាប្រជាសាស្ត្រ ដែលធ្វើឱ្យការអនុវត្តអនុក្រឹត្យនេះ មានភាពប្រែប្រួល តម្រូវឱ្យមានការសិក្សា និងកែសម្រួលឡើងវិញ។

ទន្ទឹមនេះ ក្រសួងអធិការកិច្ចបានតាមដានត្រួតពិនិត្យលើការផ្តល់សម្បទានដីសេដ្ឋកិច្ច និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តកំពង់ធំ និងខេត្តមណ្ឌលគិរី សរុបចំនួន១៣៨ទីតាំង។ ជាលទ្ធផល ក្រុមហ៊ុនទទួលបានដីសម្បទានសេដ្ឋកិច្ចមួយចំនួនបានអនុវត្តស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ទន្ទឹមនឹងនោះក៏មានក្រុមហ៊ុនដែលទទួលបានដីសម្បទានសេដ្ឋកិច្ចមួយចំនួននៅមិនទាន់ (១)ទទួលបានអនុបយោគដីពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ (២)បានធ្វើការចុះបញ្ជីដីឯកជនរបស់រដ្ឋឱ្យបានរួចរាល់ (៣)បានធ្វើកិច្ចសន្យាកែតម្រូវរយៈពេលវិនិយោគមកនៅត្រឹមរយៈពេល៥០ឆ្នាំ (៤)បានធ្វើផែនការមេកែសម្រួលថ្មីឱ្យបានរួចរាល់ (៥)បានរៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ (៦)បានបង់ថ្លៃសម្បទានឬថ្លៃឈ្នួលដីប្រចាំឆ្នាំ (៧)បានរៀបចំស្លាកដាក់តាំងនៅជាប់ផ្លូវជាតិ ឬផ្លូវចូលទៅកាន់ទីតាំងស្នាក់ការរបស់សម្បទានដីសេដ្ឋកិច្ចនូវព័ត៌មានសំខាន់ៗរបស់ក្រុមហ៊ុន (៨)បានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៩)រៀបចំផែនការអនុវត្តប្រចាំឆ្នាំនៃគម្រោងវិនិយោគរួចដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ដោយឡែក ចំពោះការអនុវត្តគម្រោងខ្លះ មានការយឺតយ៉ាវ និងគម្រោងខ្លះទៀតគ្មានសកម្មភាព នៅលើដីដែលទទួលបានសិទ្ធិវិនិយោគ។

តាមដានការអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ "បញ្ជាឱ្យអភិបាលរាជធានី ខេត្តទាំងអស់ ត្រួតពិនិត្យជាបន្ទាន់លើទីតាំងល្បែងផ្សងសំណាង ក្នុងករណីមានបន្តបើកថ្មីទៀត សូមចាត់វិធានការបិទជាបន្ទាន់ និងរាយការណ៍ផ្ទាល់ជូនសម្តេច"។ ករណីនេះ ក្រសួងអធិការកិច្ច បានធ្វើការតាមដានការអនុវត្តអនុសាសន៍ដូចខាងលើ នៅខេត្តព្រះសីហនុ ខេត្តស្វាយរៀង និងខេត្តកំពង់ស្ពឺ ដោយបានធ្វើការជាមួយមុខសញ្ញាសរុបចំនួន២៩ទីតាំង។ ជាលទ្ធផល គណៈបញ្ជាការឯកភាពខេត្តទាំង៣ បានចេញបទបញ្ជាដល់បណ្តាគណៈបញ្ជាការឯកភាពក្រុង-ស្រុក សហការជាមួយកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ បង្ក្រាប និងធ្វើកិច្ចសន្យាជាមួយមុខសញ្ញាដែលជាម្ចាស់ទីតាំងអាជីវកម្មល្បែងទាំងនោះឱ្យបិទទាំងស្រុងជាស្ថាពរ និងបន្តតាមដានត្រួតពិនិត្យជាប្រចាំនៅតាមមូលដ្ឋានទាំងនោះ។

ជាលទ្ធផល ក្រសួងបានរកឃើញថា មន្ត្រីជំនាញនៅតាមទីស្នាក់ការត្រួតពិនិត្យច្រកលើសចំនួនកំណត់ និងពុំបានត្រួតពិនិត្យរួមគ្នាចំពោះទំនិញ និងអ្នកដំណើរឆ្លងកាត់រវាងសមត្ថកិច្ចនគរបាលជាតិ និងសមត្ថកិច្ចគយ។ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនៅតាមខេត្តខ្លះ នៅមានចំណុចខ្វះខាតមួយចំនួនដែលមិនបានអនុវត្តឱ្យបានពេញលេញស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ បន្ទាប់ពីចុះតាមដានការអនុវត្តច្បាប់ ក្រសួងអធិការកិច្ចបានធ្វើសេចក្តីជូនដំណឹង និងណែនាំទៅដល់ស្ថាប័នពាក់ព័ន្ធឱ្យកែលម្អនូវចំណុចខ្វះខាត ដែលបានរកឃើញ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## IV. ការងារអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ

ការងារអប់រំផ្សព្វផ្សាយច្បាប់ ជាផ្នែកមួយនៃការចូលរួមរបស់ក្រសួងអធិការកិច្ចក្នុងការកសាងអភិវឌ្ឍធនធានមនុស្ស ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ដោយសហការ ជាមួយបណ្ដាដៃគូសំខាន់ៗរួមមាន ក្រសួង ស្ថាប័ន អាជ្ញាធរនានានៃរាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អង្គការជាតិ អន្តរជាតិ។ សកម្មភាពនេះជំរុញបង្កើនការយល់ដឹងផ្នែកច្បាប់ និងអភិបាលកិច្ចដល់ប្រជាពលរដ្ឋ មន្ត្រីរាជការ មន្ត្រីនៃអាជ្ញាធរមូលដ្ឋាន និងមន្ត្រីជំនាញពាក់ព័ន្ធ ដើម្បីលើកកម្ពស់ ប្រសិទ្ធភាព នៃការអនុវត្តច្បាប់។

ជាមួយគ្នានេះ ក្រសួងបានរៀបចំវេទិកាសាធារណៈដើម្បីសិក្សាស្វែងយល់ពីកង្វល់ និងទទួលសំណូមពរពីប្រជាពលរដ្ឋនៅតាមបណ្ដាមូលដ្ឋានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ វេទិកានេះផ្សារភ្ជាប់ទៅនឹងការដោះស្រាយបណ្ដឹងតវ៉ា និងបណ្ដឹងបរិហារ ចំពោះនីតិបុគ្គលនិងរូបវន្តបុគ្គលសាធារណៈ ក្នុងក្របខ័ណ្ឌដែនសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលពីគ្រប់មជ្ឈដ្ឋានទាំងអស់។

### ក- អនុសាសន៍តម្រង់ទិសរបស់សម្ដេចធិបតី

ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានផ្ដល់អនុសាសន៍តម្រង់ទិសដ៏ខ្ពង់ខ្ពស់លើការងារអប់រំផ្សព្វផ្សាយច្បាប់ «បន្តការងារផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយ សំដៅលើកកម្ពស់ការគោរព និងការអនុវត្តច្បាប់ ការកាត់បន្ថយអំពើពុករលួយ និងការរំលោភបំពានច្បាប់ លើកតម្កើងយុត្តិធម៌សង្គម ព្រមទាំងបង្កើតបាននូវវប្បធម៌សន្តិភាព អហិង្សា និងនីតិរដ្ឋ»។

### ខ- លទ្ធផលការងារ

### ១. ការងារអប់រំផ្សព្វផ្សាយច្បាប់តាមរយៈវេទិកាសាធារណៈនៅមូលដ្ឋាន

ចាប់ពីឆ្នាំ២០១៩ដល់ឆ្នាំ២០២៤ ក្រសួងបានផ្សព្វផ្សាយច្បាប់ចំនួន៧៨៣លើក ដែលមានប្រជាពលរដ្ឋ ព្រះសង្ឃ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត យុវជនចូលរួមសរុបចំនួន ២៣៤,៥៤៤នាក់ ស្រី១១៨,៦៥១នាក់ ក្នុងនោះ ឆ្នាំ២០១៩មានចំនួន៧៤,៨៨៧នាក់ ស្រី៤១,០០០នាក់ ឆ្នាំ២០២០មានចំនួន៣៨,៤៥៦នាក់ ស្រី១៧,០៣៣នាក់ ឆ្នាំ២០២១មានចំនួន២៣,៣៦១នាក់ ស្រី១០,២៤៣នាក់ ឆ្នាំ២០២២មានចំនួន៣៨,៤០៧នាក់ ស្រី២០,៤៦១នាក់ ឆ្នាំ២០២៣មានចំនួន១៧,១៤៣នាក់ ស្រី៩,៤៣៩នាក់ ឆ្នាំ២០២៤មានចំនួន៤២,២៩០នាក់ ស្រី២០,៤៧៥នាក់ ព្រមទាំងទទួលនិងឆ្លើយតបសំណួរបានចំនួន២៣,៧៦០សំណួរ។



## ២. ការផលិតវីដេអូខ្លី សំណួរ ចម្លើយ អំពីច្បាប់

ក្រសួងអធិការកិច្ចបានផលិតវីដេអូខ្លី សំណួរ ចម្លើយ អំពីច្បាប់ ដើម្បីចាក់ផ្សាយតាមទូរទស្សន៍ និងបណ្តាញសង្គមនូវច្បាប់ និងប្រធានបទចំនួន២៣ និងមានអ្នកចូលទស្សនាសរុបចំនួន៤៣,១៦៩នាក់ ដូចខាងក្រោម៖

- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ មានអ្នកចូលទស្សនាចំនួន ១,៤៤៧នាក់
- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានអ្នកចូលទស្សនាចំនួន២,៨៧៣នាក់
- ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក មានអ្នកចូលទស្សនាចំនួន២,៣០៣នាក់
- អនុក្រឹត្យស្តីពីការគ្រប់គ្រងជីវជ្ជ មានអ្នកចូលទស្សនាចំនួន២,២៤៦នាក់
- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ មានអ្នកចូលទស្សនាចំនួន៦១៨នាក់
- ច្បាប់ភូមិបាល (ប្រធានបទ កម្មសិទ្ធិឯកជន) មានអ្នកចូលទស្សនាចំនួន៦៨នាក់
- ច្បាប់ភូមិបាល (ប្រធានបទ សម្បទានដីសង្គមកិច្ច) មានអ្នកចូលទស្សនាចំនួន២០៨នាក់
- ច្បាប់ភូមិបាល (ប្រធានបទ លទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ) មានអ្នកចូលទស្សនាចំនួន២,០២៦នាក់
- ច្បាប់ស្តីពីការគ្រប់គ្រងឱសថ មានអ្នកចូលទស្សនាចំនួន៦៤៣នាក់
- ច្បាប់ស្តីពីអស្សាមិករណ៍ មានអ្នកចូលទស្សនាចំនួន៧១១នាក់
- ក្រមរដ្ឋប្បវេណី (ប្រធានបទ កំជាប់ពាក្យ) មានអ្នកចូលទស្សនាចំនួន៤៣៦នាក់
- ក្រមរដ្ឋប្បវេណី (ប្រធានបទ អាពាហ៍ពិពាហ៍) មានអ្នកចូលទស្សនាចំនួន៤៤៦នាក់
- ក្រមរដ្ឋប្បវេណី (ប្រធានបទ ការលែងលះគ្នា) មានអ្នកចូលទស្សនាចំនួន៥៦៣នាក់
- ក្រមរដ្ឋប្បវេណី (ប្រធានបទ អានុភាពនៃការលែងលះគ្នា) មានអ្នកចូលទស្សនាចំនួន៣,០០៥នាក់
- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ មានអ្នកចូលទស្សនាចំនួន៥៣៦នាក់
- ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗទៀត មានអ្នកចូលទស្សនាចំនួន២៨៣នាក់
- ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ មានអ្នកចូលទស្សនាចំនួន៣៦១នាក់
- ច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ (ប្រធានបទ ផលប៉ះពាល់ និងវិធានការទប់ស្កាត់ចំពោះការប្រើប្រាស់ផលិតផលថ្នាំជក់) មានអ្នកចូលទស្សនាចំនួន២៩២នាក់
- អនុក្រឹត្យស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ (ប្រធានបទ សិទ្ធិនិងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិ) មានអ្នកចូលទស្សនាចំនួន៤៨១នាក់
- ច្បាប់ស្តីពីការរំលូតកូន (ប្រធានបទ បែបបទ និងលក្ខខណ្ឌនៃការរំលូតកូន) មានអ្នកចូលទស្សនាចំនួន ៤១២នាក់
- ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជន នៃអគារសហកម្មសិទ្ធិរបស់ជនបរទេស (ប្រធានបទ លទ្ធកម្មកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ) មានអ្នកចូលទស្សនាចំនួន៤១៦នាក់

- ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក (ប្រធានបទ ការមិនគោរពសញ្ញាចរាចរណ៍) មានអ្នកចូលទស្សនាចំនួន ១៩,៩៧៦នាក់
- ក្រមព្រហ្មទណ្ឌ (ប្រធានបទ ការប៉ះពាល់ដល់ជីវិតមនុស្ស) មានអ្នកចូលទស្សនាចំនួន២,៨១៨នាក់។

### ៣. ការស្ទង់មតិយល់ដឹងអំពីច្បាប់

ក្នុងឆ្នាំ២០២៤ ក្រសួងអធិការកិច្ចបានចុះវិភាគស្ថានភាព និងវាយតម្លៃការយល់ដឹងរបស់ប្រជាពលរដ្ឋមុនពេលផ្សព្វផ្សាយច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន៤កន្លែង ដែលមានប្រជាពលរដ្ឋសរុបចំនួន ២២២នាក់ ស្រី៨៩នាក់ និងក្រោយពេលផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន៤កន្លែង ដែលមានប្រជាពលរដ្ឋសរុបចំនួន២០០នាក់ ស្រី១២៧នាក់ ជាលទ្ធផលនៃការវាយតម្លៃ អំពីការយល់ដឹងរបស់ប្រជាពលរដ្ឋលើច្បាប់ទាំងពីរនេះ បានបង្ហាញដូចខាងក្រោម៖

➢ **ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក**

- សញ្ញាចរាចរណ៍ មុនពេលផ្សព្វផ្សាយយល់ដឹង៣២% ក្រោយពេលផ្សព្វផ្សាយយល់ដឹង៦២%
- អ្នកបើកបរយានជំនិះ មុនពេលផ្សព្វផ្សាយយល់ដឹង១២% ក្រោយពេលផ្សព្វផ្សាយយល់ដឹង៣៩%
- ការប្រើប្រាស់ភ្លើងនិងសូរសព្ទយានជំនិះ មុនពេលផ្សព្វផ្សាយយល់ដឹង១៣% ក្រោយពេលផ្សព្វផ្សាយយល់ដឹង៤១%
- ករណីមានគ្រោះថ្នាក់ចរាចរណ៍ មុនពេលផ្សព្វផ្សាយយល់ដឹង៤% ក្រោយពេលផ្សព្វផ្សាយយល់ដឹង៣៦%
- ទោសប្បញ្ញត្តិ មុនពេលផ្សព្វផ្សាយយល់ដឹង៣% ក្រោយពេលផ្សព្វផ្សាយយល់ដឹង៤៣%។

➢ **ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**

- ផលប៉ះពាល់នៃគ្រឿងញៀន មុនពេលផ្សព្វផ្សាយយល់ដឹង៣០% ក្រោយពេលផ្សព្វផ្សាយយល់ដឹង៥៩%
- បទល្មើសនៃគ្រឿងញៀន មុនពេលផ្សព្វផ្សាយយល់ដឹង១៣% ក្រោយពេលផ្សព្វផ្សាយយល់ដឹង៤៣%
- ចំណាត់ថ្នាក់គ្រឿងញៀន មុនពេលផ្សព្វផ្សាយយល់ដឹង១% ក្រោយពេលផ្សព្វផ្សាយយល់ដឹង២៨%
- បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរ មុនពេលផ្សព្វផ្សាយយល់ដឹង១៤% ក្រោយពេលផ្សព្វផ្សាយយល់ដឹង៤៦%
- វិធានការព្យាបាល និងស្តារនីតិសម្បទា មុនពេលផ្សព្វផ្សាយយល់ដឹង១% ក្រោយពេលផ្សព្វផ្សាយយល់ដឹង៣២%។

ទន្ទឹមគ្នានេះដែរ នៅឆ្នាំ២០២៤ ក្រសួងក៏បានស្ទង់មតិនៃការពេញចិត្តឬមិនពេញចិត្តរបស់ប្រជាពលរដ្ឋមកលើការរៀបចំអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ ជាលទ្ធផលបានបង្ហាញថា ការអប់រំផ្សព្វផ្សាយច្បាប់ចំនួន ១៥លើក មានការចូលរួមពីប្រជាពលរដ្ឋសរុបចំនួន៥,៦០៣នាក់ មានការពេញចិត្តរហូតដល់៩៨%។ រីឯវេទិកាសាធារណៈចំនួន១២លើក ប្រជាពលរដ្ឋចូលរួមសរុបចំនួន២,៣៨៤នាក់ មានការពេញចិត្ត៩៥%។

### គ- ការទទួលសំណូមពរពីប្រជាពលរដ្ឋតាមរយៈវេទិកាសាធារណៈ

ក្នុងវេទិកាសាធារណៈ ក្រសួងបានទទួលសំណូមពរសរុបចំនួន២,៦៣៤ ពីប្រជាពលរដ្ឋនៅតាមបណ្តាក្រុង ស្រុក ខណ្ឌ នៃរាជធានី-ខេត្តទាំង២៥ សរុបចំនួន២៥១លើក និងមានអ្នកចូលរួមសរុប៥៧,៤៨៦នាក់ ស្រី២៧,៨៥០នាក់ ក្នុង

នោះឆ្នាំ២០១៩មានអ្នកចូលរួមចំនួន១៥,៦៧៦នាក់ ស្រី៧,៥៦០នាក់ ឆ្នាំ២០២០មានអ្នកចូលរួមចំនួន៩,០០៩នាក់ ស្រី៤,៨៤៧នាក់ ឆ្នាំ២០២១មានអ្នកចូលរួមចំនួន៩,៤៩៩នាក់ ស្រី៤,៨៥៩នាក់ ឆ្នាំ២០២២មានអ្នកចូលរួមចំនួន១០,០៨១នាក់ ស្រី៤,៥៧៨នាក់ ឆ្នាំ២០២៣មានអ្នកចូលរួមចំនួន១០,៨៦២នាក់ ស្រី៥,០៤៤នាក់ និងឆ្នាំ២០២៤មានអ្នកចូលរួមចំនួន២,៣៥៩នាក់ ស្រី៩៦២នាក់។




ជារួម ការងារអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈដែលក្រសួងអធិការកិច្ចបានអនុវត្តនាពេលកន្លងមកបានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការជំរុញ និងបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋនៅតាមតំបន់ងាយរងគ្រោះ ឱ្យយល់ដឹងអំពីច្បាប់ស្តីពីអភិបាលកិច្ច ព្រមទាំងកម្មវិធីនិងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ សំដៅកាត់បន្ថយ និងលុបបំបាត់អំពើហិង្សា ការរំលោភបំពានលើសិទ្ធិមនុស្ស និងចូលរួមដោះស្រាយរាល់បញ្ហាប្រឈមផ្នែកច្បាប់ ដែលកើតមាននៅក្នុងជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

## V. ការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

### ក- លិខិតបទដ្ឋានគតិយុត្តនៃវិស័យអធិការកិច្ចនៅកម្ពុជា

#### ១- ឆ្នាំ១៩៦៩-១៩៩៣

ដូចបានលើកឡើងខាងលើ ក្រសួងអធិការកិច្ចមានសាវតាតាំងពីសម័យសង្គមរាស្ត្រនិយម ដែលនៅឆ្នាំ១៩៦៩ ស្ថាប័នអធិការកិច្ចបានបង្កើតឡើងដែលមានឈ្មោះថា «គណៈកម្មាធិការជាតិនៃការបោសសម្អាតទូទៅ» មានបេសកកម្មពិនិត្យនូវសំណុំរឿងមន្ត្រី និងភ្នាក់ងាររាជការស៊ីវិល ឬទាហាន ភ្នាក់ងាររបស់អង្គការ ឬសហគ្រាសសាធារណៈ ឬអង្គសាធារណៈ ដែលចូលជាកម្មវត្ថុនៃវិធានការបោសសម្អាត និងដាក់ទណ្ឌកម្មទាំងឡាយតាមកំហុសនៃមន្ត្រី និងភ្នាក់ងារទាំងនោះ។ ចន្លោះ**ឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៥** ការងារអធិការកិច្ច មានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ មាត្រា១១១ «អភិបាលរដ្ឋ មានមុខងារត្រួតពិនិត្យ និងធ្វើអង្កេតលើបុគ្គលិកនៃ

អង្គការសាធារណៈ និងឯកជនទាំងអស់ ដែលជាប់ទាក់ទិនក្នុងរឿងស៊ីសំណូក រឿងពុករលួយ រឿងប្រើអំណាចដោយរំលោភ រឿងរត់គយ រឿងស្តុកទំនិញខុសច្បាប់ រឿងតម្លើងថ្លៃខុសច្បាប់ រឿងប្រដេញប្រជែងដោយវៀចវេរ និងរឿងចងការប្រាក់យកលើសកម្រិតច្បាប់»។ ដោយឡែក ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម គ្មានលិខិតបទដ្ឋានចែងអំពីការងារអធិការកិច្ចទេ។

សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា-រដ្ឋកម្ពុជា នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា បានបង្កើតរដ្ឋធម្មនុញ្ញថ្មី ហើយបានប្តូរឈ្មោះ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ទៅជា «ក្រុមប្រឹក្សារដ្ឋមន្ត្រី» ដែលជាស្ថាប័នកំពូលនៃអង្គនីតិប្រតិបត្តិ និងមានក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ ជាស្ថាប័នមួយរបស់រដ្ឋាភិបាលចំណុះក្រុមប្រឹក្សារដ្ឋមន្ត្រីផងដែរ។ ដើម្បីឱ្យក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ អនុវត្តសកម្មភាពរបស់ខ្លួនលើការងារត្រួតពិនិត្យពីមជ្ឈិមដល់មូលដ្ឋានមានប្រសិទ្ធភាពខ្ពស់ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានចេញនូវលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តបន្តបន្ទាប់ ដោយផ្តោតលើការកំណត់មុខងារ ភារកិច្ច សិទ្ធិអំណាច និងអង្គការចាត់តាំង ដូចខាងក្រោម៖

- សេចក្តីសម្រេចលេខ១៥ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៨១ របស់ក្រុមប្រឹក្សារដ្ឋ ស្តីពីការកំណត់អំពីមុខងារ សិទ្ធិអំណាច ភារកិច្ចនៃក្រសួងត្រួតពិនិត្យរបស់រដ្ឋាភិបាល
- ក្រឹត្យលេខ០៣ ក្រ.ច ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២ របស់ក្រុមប្រឹក្សារដ្ឋ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលត្រង់មាត្រា៤២ បានចែងច្បាស់អំពីភារកិច្ចទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ
- អនុក្រឹត្យលេខ០២ អនក្រ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៨២ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការប្រកាសឱ្យប្រើលក្ខន្តិកៈនៃការចាត់តាំង និងសកម្មភាពរបស់ក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ
- អនុក្រឹត្យលេខ៧៣ អនក្រ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៨៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការចាត់តាំងបណ្តាញត្រួតពិនិត្យតាមក្រសួង ខេត្ត-ក្រុង ជុំវិញមជ្ឈិម
- នៅសម័យប្រជុំលើកទី៣ នីតិកាលទី១ នាថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៨២ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការការពារទ្រព្យសម្បត្តិរដ្ឋ និងច្បាប់ស្តីពីការពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ ហើយក្រុមប្រឹក្សារដ្ឋ បានប្រកាសឱ្យប្រើតាមក្រឹត្យលេខ១០ ក្រ និងលេខ១១ ក្រ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៨២
- សារាចរណែនាំបន្ថែមលេខ០៣ សរណ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៨៤ ស្តីពីការអនុវត្តច្បាប់ស្តីពីការពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ ឱ្យបានត្រឹមត្រូវ និងកាន់តែប្រសើរឡើង
- ក្រឹត្យ-ច្បាប់ លេខ៣១ ក្រ.ច ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៨៧ ស្តីពីការបង្កើតទីស្តីការក្រសួងត្រួតពិនិត្យ (ប្តូរឈ្មោះពី ក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ ទៅជា ក្រសួងត្រួតពិនិត្យ វិញ)
- អនុក្រឹត្យលេខ១៥ អនក្រ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៨៧ ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ (នៅតាមទីស្តីការរដ្ឋមន្ត្រី រួមទាំងទីស្តីការរដ្ឋមន្ត្រីក្រសួងការពារប្រទេស និងក្រសួងមហាផ្ទៃ

ស្ថាប័នថ្នាក់ប្រហាក់ប្រហែលទីស្តីការរដ្ឋមន្ត្រី ខេត្ត-ក្រុង ចំណុះមជ្ឈិម ទីរួមខេត្ត ខណ្ឌ ស្រុក ស្រុកជាយក្រុង)

- អនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៨៧ ស្តីពីការចាត់តាំងគណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជននៅតាមមូលដ្ឋាន ឃុំ សង្កាត់ សហគ្រាសផលិតកម្ម អាជីវកម្ម មន្ទីរពេទ្យ សាលារៀនណា ដែលចាំបាច់ និងមានលទ្ធភាព ឱ្យឈ្មោះថា «គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជន»
- អនុក្រឹត្យលេខ១៧ អនក្រ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៨៧ ស្តីពីការចាត់តាំង និងសកម្មភាពរបស់ទីស្តីការរដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ។

ក្រសួងត្រួតពិនិត្យ មានមុខងារត្រួតពិនិត្យការអនុវត្តគោលនយោបាយ ផែនការរបស់រដ្ឋ សំដៅបង្កើននូវវិន័យ លើកកម្ពស់ស្មារតីទទួលខុសត្រូវ រួមចំណែកកែលម្អការចាត់តាំង និងរបៀបរបបធ្វើការងាររបស់ស្ថាប័ន និងអង្គការរដ្ឋពីមជ្ឈិមរហូតដល់មូលដ្ឋាន។ ចំពោះតួនាទី ភារកិច្ច ទំនាក់ទំនង និងរបៀបរបបធ្វើការជាក់ស្តែងរបស់មន្ទីរ បណ្តានាយកដ្ឋាន សាលាមុខជំនាញត្រួតពិនិត្យ និងការិយាល័យចាត់តាំងកម្មាភិបាល អាស្រ័យលើរដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ កំណត់ សម្រេច និងដាក់ចេញឱ្យអនុវត្ត។

## ២- ឆ្នាំ១៩៩៣-បច្ចុប្បន្ន

នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៤ រាជរដ្ឋាភិបាល បានចេញអនុក្រឹត្យលេខ៣០ អនក្រ.បក ស្តីពីការកំណត់ភារកិច្ច និងសមត្ថកិច្ចរបស់ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការអធិការកិច្ច។ ក្រោយមក រាជរដ្ឋាភិបាលក៏បានចេញអនុក្រឹត្យលេខ៤៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋានអធិការកិច្ចរបស់រាជរដ្ឋាភិបាល ដែលមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធ្វើជាសេនាធិការឱ្យទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច។

យោងតាមអនុក្រឹត្យខាងលើ អង្គភាពអធិការកិច្ចរាជរដ្ឋាភិបាល បានចេញប្រកាសលេខ៨៩ ប្រក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានអធិការកិច្ច នៃរាជរដ្ឋាភិបាល និងប្រកាសលេខ១៣២ ប្រក.អធក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកំណត់អំពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់អង្គភាពអធិការកិច្ច រាជរដ្ឋាភិបាល និងក្រុមអធិការកិច្ចជំនួយការ។

ក្រោយការបោះឆ្នោតជាសកល អាណត្តិទី២ ឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៨០ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការផ្ទេររដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា និងអគ្គលេខាធិការដ្ឋានអធិការកិច្ចរបស់រាជរដ្ឋាភិបាល ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច។ នៅសម័យប្រជុំលើកទី២ នីតិកាលទី២ នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៩៩ រដ្ឋសភាបានអនុម័ត ច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ហើយត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើច្បាប់នេះ តាមរយៈព្រះរាជក្រមលេខ នស/ រកម /០៦៩៩/០៥ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃ០៣ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។ ក្រសួងបានចេញ

ប្រកាសលេខ០២៤/០១ ទ.រ.ព.អ.ប្រក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០១ ស្តីពីការកំណត់តួនាទី ភារកិច្ច របស់ការិយាល័យចំណុះនាយកដ្ឋាននៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានចេញប្រកាសលេខ០៤៤/០៥ ទ.រ.ព.អ.ប្រក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកំណត់តួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រាជធានី ខេត្ត, ប្រកាសលេខ០៨១/០៧ ទ.រ.ព.អ.ប្រក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងប្រកាសលេខ០៧៨/០៨ ទ.រ.ព.អ.ប្រក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីក្រមសីលធម៌មន្ត្រីរាជការអធិការកិច្ច នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។ នៅក្នុងនីតិកាលនេះ ក្រសួងបានបង្កើតក្រុមការងារដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច។

នៅក្នុងនីតិកាលទី៤ នៃរដ្ឋសភា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានចេញសេចក្តីសម្រេចបង្កើតក្រុមការងារកន្សោមអាទិភាព ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច។

នៅក្នុងនីតិកាលទី៥ នៃរដ្ឋសភា ដើម្បីឱ្យតួនាទីភារកិច្ចរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បន្តដំណើរការ និងទទួលបានលទ្ធផលល្អប្រសើរ ប្រកបដោយប្រសិទ្ធភាពខ្ពស់ស្របតាមការវិវត្តន៍របស់សង្គមជាតិដែលកំពុងមានការរីកចម្រើនលើគ្រប់វិស័យ ពិសេសស្របតាមកំណែទម្រង់ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹងអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ លេខ០៣ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជំនួសអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៩។ ក្រសួងបានចេញសេចក្តីសម្រេចបង្កើតក្រុមការងារតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដោយបានសម្រេចនូវលទ្ធផលមួយចំនួនដូចខាងក្រោម៖

- បទបញ្ជាផ្ទៃក្នុងសម្រាប់គណៈប្រតិភូអធិការកិច្ច និងតាមដានការអនុវត្តច្បាប់ លេខ៥៩៦/១៤ទ.រ.ព.អ.រប ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤
- ប្រកាសលេខ០៦៩/១៥ ទ.រ.ព.អ.ប្រក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលឈ្មោះនាយកដ្ឋានចំណុះអគ្គនាយកដ្ឋានអធិការកិច្ច និងការកំណត់វិស័យក្នុងការធ្វើអធិការកិច្ច នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ប្រកាសលេខ០៧៣/១៥ ទ.រ.ព.អ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- ប្រកាសលេខ០៧៤/១៥ ទ.រ.ព.អ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី ខេត្ត
- ប្រកាសលេខ០៨៣/១៧ ទ.រ.ព.អ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានជាតិអធិការកិច្ច នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

- ប្រកាសលេខ០៧០/១៨ ទ.រ.ព.អ.ប្រក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ ស្តីពីការប្រើប្រាស់ត្រា និងនិមិត្តសញ្ញារបស់វិទ្យាស្ថានជាតិអធិការកិច្ច នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

ដើម្បីដោះស្រាយបញ្ហាស្ទួនមុខងារចុះធ្វើអធិការកិច្ចរបស់ស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យ រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា បានចេញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដោយបានកំណត់មុខងារអធិការកិច្ចរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ធ្វើអធិការកិច្ចលើគ្រប់វិស័យស្របតាមអនុក្រឹត្យលេខ០៣ អនក្រ.បក និងដោយផ្អែកលើអភិក្រម៧ចំណុច។

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បាន អនុញ្ញាតដាក់បញ្ចូលសេចក្តីព្រាង ច្បាប់ស្តីពីការបង្កើតក្រសួងអធិការកិច្ច ក្នុងរបៀបវារៈនៃកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១របស់ខ្លួន សម្រាប់នីតិកាលទី៧នៃរដ្ឋសភា ពិនិត្យ និងសម្រេច ដើម្បីរាជរដ្ឋាភិបាលអាចបញ្ជូនសេចក្តីព្រាងច្បាប់នេះទៅរដ្ឋសភាដោយចាត់ទុកជាការប្រញាប់។ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ត្រូវបានប្តូរឈ្មោះមកជា ក្រសួងអធិការកិច្ច តាមព្រះរាជក្រមលេខ នស/រកម/ ១០២៣/០១៩ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអធិការកិច្ច។

បន្ទាប់ពីការបង្កើតក្រសួងអធិការកិច្ច លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការប្រព្រឹត្តទៅរបស់ក្រសួង ព្រមទាំងវិស័យអធិការកិច្ចត្រូវបានសម្រេចរៀបចំ កំពុងរៀបចំបង្កើតថ្មី ឬកែសម្រួលឡើងវិញជាបន្តបន្ទាប់ ដូចជា៖

- អនុក្រឹត្យលេខ៣១៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ ស្តីពីរូបសញ្ញា និងត្រារបស់ក្រសួងអធិការកិច្ច
- អនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច
- សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតមន្ទីរអធិការកិច្ចរាជធានី ខេត្ត
- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរអធិការកិច្ចរាជធានី ខេត្ត
- សេចក្តីព្រាងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះអង្គភាពក្រោមឱវាទក្រសួងអធិការកិច្ច
- សេចក្តីព្រាងប្រកាសស្តីពីការបែងចែកក្រសួង ស្ថាប័ន តាមវិស័យក្នុងការធ្វើអធិការកិច្ច និងការកំណត់សមត្ថកិច្ចរបស់នាយកដ្ឋានតាមដានការអនុវត្តច្បាប់ចំណុះអគ្គនាយកដ្ឋានអធិការកិច្ច
- សេចក្តីព្រាងប្រកាសស្តីពីរូបសញ្ញានិងត្រារបស់វិទ្យាស្ថានជាតិអធិការកិច្ច
- សេចក្តីព្រាងសេចក្តីណែនាំស្តីពីការប្រើប្រាស់ត្រានិងរូបសញ្ញារបស់មន្ទីរអធិការកិច្ចរាជធានី ខេត្ត ជាបណ្តោះអាសន្ន
- សេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងសម្រាប់គណៈប្រតិភូអធិការកិច្ច និងតាមដានការអនុវត្តច្បាប់
- សេចក្តីព្រាងប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីអធិការកិច្ច

- សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីអធិការកិច្ច និងតាមដានការអនុវត្តច្បាប់
- សេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច។

### ខ- អនុសាសន៍តម្រង់ទិសរបស់សម្តេចធិបតី

ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**បានផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់តម្រង់ទិសលើការកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអធិការកិច្ច ដូចខាងក្រោម៖

- ក្រសួងអធិការកិច្ច ត្រូវរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ សម្រាប់បម្រើឱ្យវិស័យអធិការកិច្ចឱ្យបានគ្រប់គ្រាន់ ជាពិសេសត្រូវពន្លឿនការតាក់តែងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច និងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចឱ្យបានឆាប់រហ័សដែលជាច្បាប់គោលរួមឱ្យរួចរាល់នៅឆ្នាំ២០២៤នេះ
- ក្រសួងអធិការកិច្ច ត្រូវសិក្សាលទ្ធភាពធ្វើវិសោធនកម្មច្បាប់ស្តីពីបណ្តឹងតវ៉ា និងច្បាប់ស្តីពីបណ្តឹងបរិហារ ឬក៏ត្រូវតាក់តែងថ្មី
- ក្រសួងយុត្តិធម៌ និងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងស្ថាប័នពាក់ព័ន្ធ ផ្តល់ការសហការ រៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងអធិការកិច្ចឱ្យបានឆាប់រហ័ស ដោយឈរលើផលប្រយោជន៍រួម សំដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សង្គមជាតិ។

## VI. ការងារពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស

ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍តម្រង់ទិសដ៏ខ្ពង់ខ្ពស់លើការពង្រឹងស្ថាប័នបន្ថែមទៀត ដោយផ្តោតលើ ការកសាងមូលធនមនុស្ស ដោយពង្រឹងសមត្ថភាពមន្ត្រីប្រកបដោយមនសិការនិងក្រមសីលធម៌វិជ្ជាជីវៈ និងពង្រឹងការអនុវត្តតួនាទីអធិការកិច្ចឱ្យបានទូលំទូលាយ ស្មើភាព និងមិនរើសអើង ប្រកបដោយភាពម៉ឺងម៉ាត់ គោរពច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។

អំឡុងខែមិថុនា ឆ្នាំ២០២៤ ក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងអធិការកិច្ចបានបញ្ចប់ការងារវិភាគមុខងារ និងការពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធ នៅដំណាក់កាលទី១។ យោងតាមច្បាប់ស្តីពីការបង្កើតក្រសួងអធិការកិច្ច និងផ្អែកតាមលទ្ធផលនៃការវិភាគមុខងារ ព្រមទាំងភាពចាំបាច់នៃការកែទម្រង់ស៊ីជម្រៅ រាជរដ្ឋាភិបាលបានសម្រេចសម្រួលមុខងារភារកិច្ច និងរចនាសម្ព័ន្ធក្រសួងអធិការកិច្ច ពីអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ទៅជាអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច។ រចនាសម្ព័ន្ធក្រសួងអធិការកិច្ចក៏មានការសម្រួលមួយចំនួនផងដែរ ក្នុងនោះនៅថ្នាក់កណ្តាលមានចំនួន៣អគ្គនាយកដ្ឋាន ១៥នាយកដ្ឋាន និងវិទ្យាស្ថានជាតិអធិការកិច្ច និងមានថ្នាក់ក្រោមជាតិមានមន្ទីរអធិការកិច្ចរាជធានី ខេត្តទាំង២៥។

ឆ្នាំ២០១៥មន្ត្រីរាជការក្រសួងអធិការកិច្ចមានសរុបចំនួន ៧៦៥រូប (ស្រី២១៦រូប ស្មើនឹង២៨.២៣%) ក្នុងនោះថ្នាក់កណ្តាលចំនួន ៤២១រូប (ស្រី ១២២រូប ស្មើនឹង២៩%) និងថ្នាក់រាជធានី ខេត្តចំនួន៣៤៤ រូប (ស្រី ៩៤រូប ស្មើនឹង២៧.៣២%)។ ត្រឹមខែមិថុនា ឆ្នាំ២០២៤ ក្រសួងអធិការកិច្ចមានមន្ត្រីរាជការសរុបចំនួន ៨១០រូប (ស្រី ២៦៧រូប ស្មើនឹង៣២.៨៤%) ក្នុងនោះថ្នាក់កណ្តាលចំនួន ៤៦៤រូប (ស្រី ១៥១រូប ស្មើនឹង៣២.៥៤%) ក្នុងនោះមន្ត្រីរាជការក្របខ័ណ្ឌ"ក"ចំនួន ៤៣១រូប ក្របខ័ណ្ឌ"ខ"ចំនួន ២៤រូប ក្របខ័ណ្ឌ"គ"ចំនួន៩រូប និងថ្នាក់រាជធានី ខេត្តចំនួន ៣៤៦រូប (ស្រី ១១៦រូប ស្មើនឹង៣៣.៥២%) ក្នុងនោះមន្ត្រីរាជការក្របខ័ណ្ឌ"ក"ចំនួន ២៣៩រូប ក្របខ័ណ្ឌ"ខ" ចំនួន ៥៨រូប ក្របខ័ណ្ឌ"គ"ចំនួន៤៩រូប។ ក្នុងរយៈពេលប្រមាណ១០ឆ្នាំ មន្ត្រីរាជការក្រសួងអធិការកិច្ចមានកំណើនចំនួន៤៥រូប ស្មើនឹង៥.៨៨% ដោយក្នុងរង្វង់៥ឆ្នាំចុងក្រោយនេះ ក្រសួងមិនបានបញ្ចូលក្របខ័ណ្ឌថ្មីទេ។






ថ្នាក់ដឹកនាំកម្រិតនយោបាយ និងមន្ត្រីរាជការកម្រិតបច្ចេកទេសរបស់ក្រសួងអធិការកិច្ច មានវ័យចន្លោះពី ៣១ឆ្នាំទៅ៥០ឆ្នាំ ដែលជាវ័យពោរពេញថាមពលនិងចំណេះដឹង។




កម្រិតសញ្ញាបត្ររបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិករបស់ក្រសួងអធិការកិច្ច មានការប្រែប្រួលជាវិជ្ជមានតាមរយៈការអភិវឌ្ឍសមត្ថភាពដូចភ្លៀងរលឹម។ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការថ្នាក់កណ្តាលដែលមានកម្រិតសញ្ញាបត្របណ្ឌិតចំនួន២.២% បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៤១.១% និងបរិញ្ញាបត្រចំនួន៥២.៨%។ មន្ត្រីរាជការ និងបុគ្គលិកចំនួន៣.៩% ប៉ុណ្ណោះដែលមានកម្រិតក្រោមបរិញ្ញាបត្រ។ មន្ត្រីរាជការថ្នាក់មន្ទីរាជធានី ខេត្ត ដែលមានកម្រិតសញ្ញាបត្របណ្ឌិតចំនួន០.៤% បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២០.៤% និងបរិញ្ញាបត្រចំនួន៦៩.៤%។ មានតែមន្ត្រីរាជការ និងបុគ្គលិកចំនួន៩.៨% ប៉ុណ្ណោះដែលមានកម្រិតក្រោមបរិញ្ញាបត្រ។






ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិករបស់ក្រសួងអធិការកិច្ច ថ្នាក់កណ្ដាល សរុបចំនួន ៤៣០នាក់ មានជំនាញដូចជា៖ ១-នីតិសាស្ត្រ ចំនួន៨៤នាក់(១៩.៥%) ២-រដ្ឋបាលសាធារណៈ ចំនួន៤២នាក់(៩.៨%) ៣-គ្រប់គ្រងពាណិជ្ជកម្ម ចំនួន១០៧នាក់(២៥%) ៤-ធនាគារនិងហិរញ្ញវត្ថុ ចំនួន៣២នាក់(៧.៥%) ៥-គណនេយ្យនិងហិរញ្ញវត្ថុ ចំនួន៣៦នាក់(៨.៤%) ៦-វិទ្យាសាស្ត្រកុំព្យូទ័រ ចំនួន១៣នាក់(៣%) ៧-សេដ្ឋកិច្ច ចំនួន១៣នាក់(៤%) ៨-អក្សរសាស្ត្រអង់គ្លេស ចំនួន១០នាក់(២%) ៩-សវនកម្ម ចំនួន៤នាក់(០.៩%) ១០-វិស្វករ ចំនួន១៤នាក់ (៣.៣%) និងចំនួន៧១នាក់ទៀត ចាត់ចូលក្នុងក្រុមជំនាញផ្សេងៗរួមមាន អក្សរសាស្ត្រខ្មែរ ចិត្តវិទ្យា សង្គមវិទ្យា សង្គមសាស្ត្រ និងមនុស្សសាស្ត្រ គណិតវិទ្យា គ្រប់គ្រងធនធានមនុស្ស ជីវវិទ្យា ទស្សនវិជ្ជា ទេសចរណ៍ រូបវិទ្យា វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រ វេជ្ជបណ្ឌិត ម៉ាឃីតធីង វិទ្យាសាស្ត្រ(សុរិយោដី) វិទ្យាសាស្ត្រ(សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍជនបទ) វិទ្យាសាស្ត្រអប់រំ សហគ្រិនភាព សេដ្ឋកិច្ចអភិវឌ្ឍន៍ ស្ថាបត្យកម្មរចនាផ្ទៃក្នុង វិទ្យាសាស្ត្រនយោបាយ វិទ្យាសាស្ត្រសង្គម និងនីតិសាស្ត្រ ប្លង់និងរចនា គ្រប់គ្រងហានិភ័យ គ្រប់គ្រងហិរញ្ញវត្ថុ ច្បាប់សាធារណៈ ទេសចរណ៍ និងបដិសណ្ឋារកិច្ច ទំនាក់ទំនងសាធារណៈ រដ្ឋបាលដឹកនាំអប់រំ វិទ្យាសាស្ត្រសំណង់ស៊ីវិល វិស្វករសេដ្ឋកិច្ច ស្ថិតិសេដ្ឋកិច្ច ឧក្រិដ្ឋកម្មវិទ្យា និងប្រព័ន្ធយុត្តិធម៌ អក្សរសាស្ត្រខ្មែរ អប់រំផែនការនិងគ្រប់គ្រងអប់រំ អភិវឌ្ឍនិងសហប្រតិបត្តិការ អភិវឌ្ឍសង្គមបច្ចេកទេសអគ្គិសនី អក្សរសាស្ត្រចិន ប្រវត្តិវិទ្យា និងទស្សនវិទ្យា។

មន្ត្រីរាជការ និងបុគ្គលិករបស់ក្រសួងអធិការកិច្ច ថ្នាក់មន្ទីររាជធានី ខេត្ត សរុបចំនួន ១៧៤នាក់ មានជំនាញដូចជា៖ ១-នីតិសាស្ត្រ ចំនួន៣១នាក់(១៧.៨%) ២-រដ្ឋបាលសាធារណៈ ចំនួន៣២នាក់(៧.៥%) ៣-គ្រប់គ្រងពាណិជ្ជកម្ម ចំនួន៥៣នាក់(៣០.៥%) ៤-ធនាគារ និងហិរញ្ញវត្ថុ ចំនួន៨នាក់(៤.៦%) ៥-គណនេយ្យចំនួន៣៤នាក់(១៩.៥%) ៦-វិទ្យាសាស្ត្រកុំព្យូទ័រ ចំនួន៣នាក់(១.៧%) និង មន្ត្រី ចំនួន៣២នាក់ទៀត ចាត់ចូលក្នុងក្រុមជំនាញផ្សេងៗ មានដូចជា៖ ក្សេត្រសាស្ត្រ គណិតវិទ្យា ចិត្តវិទ្យា ទស្សនវិជ្ជាពុទ្ធសាសនា បច្ចេកវិទ្យា និងគ្រប់គ្រងកសិកម្ម ប្រវត្តិវិទ្យា ភាសាអង់គ្លេស វិទ្យាសាស្ត្រកុំព្យូទ័រ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រសង្គម វិទ្យាសាស្ត្រ

សេដ្ឋកិច្ច វិទ្យាសាស្ត្រអប់រំ សាកវប្បកម្ម សេដ្ឋកិច្ចកសិកម្ម ស្ថាបត្យកម្ម អក្សរសាស្ត្រខ្មែរ អភិវឌ្ឍជនបទគ្រប់គ្រងធនធានមនុស្ស សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។







ក្រៅពីចំណេះដឹងមូលដ្ឋាន មន្ត្រីរាជការនិងបុគ្គលិកក្រសួងអធិការកិច្ច បានទទួលនូវការយកចិត្តទុកដាក់ខ្ពស់ពីថ្នាក់ដឹកនាំ ក្នុងការជំរុញ និងពង្រឹងការអភិវឌ្ឍធនធានមនុស្សរបស់ក្រសួង តាមរយៈការបញ្ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិក គ្រប់លំដាប់ថ្នាក់ ទៅទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធ ចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេស និងកម្មវិធីផ្សេងៗជាច្រើន។ ជាក់ស្តែង នៅឆ្នាំ២០២៤កន្លងមក ថ្នាក់ដឹកនាំ មន្ត្រីរាជការនិងបុគ្គលិកសរុបចំនួន២៩១រូប បានទទួលការបណ្តុះបណ្តាលលើជំនាញនៅក្នុងប្រទេសរួមមាន វគ្គវិក្រឹតការ វគ្គបណ្តុះបណ្តាលតម្រង់ទិសដំបូង ភាពជាអ្នកដឹកនាំនិងនវានុវត្តន៍ ការតាក់តែងលិខិតរដ្ឋបាលនិង

លិខិតគតិយុត្ត ភាពជាអ្នកដឹកនាំបរិវត្តកម្មឌីជីថល ជំនាញឌីជីថល បច្ចេកទេសឌីជីថល អក្ខរកម្មព័ត៌មាន ទិន្នន័យ និងសន្តិសុខសាយប័រ ជំនាញភាសាអង់គ្លេសនិងទំនាក់ទំនងកម្រិតមូលដ្ឋាន ជំនាញបកប្រែ ជំនាញទំនាក់ទំនងជាដើម។ សម្រាប់ដើមឆ្នាំ២០២៥នេះ មន្ត្រីរាជការនិងបុគ្គលិកសរុបចំនួន៥៦រូបបានទទួលការបណ្តុះបណ្តាលលើជំនាញនៅក្នុងប្រទេសរួមមានភាសាចិនកម្រិត HSK2 ជំនាញភាសាអង់គ្លេស និងទំនាក់ទំនង និងជំនាញឌីជីថលចាំបាច់បន្ថែមទៀត។

ជាមួយគ្នានេះដែរ វិទ្យាស្ថានជាតិអធិការកិច្ចក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលជំនាញអធិការកិច្ច និងជំនាញពាក់ព័ន្ធជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការនិងបុគ្គលិកក្រសួង និងអង្គភាពអធិការកិច្ចតាមក្រសួងស្ថាប័នដែលជាបណ្តាញរបស់ក្រសួងអធិការកិច្ច។ គិតចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៤ វិទ្យាស្ថានជាតិអធិការកិច្ចបានបើកវគ្គបណ្តុះបណ្តាលចំនួន៣១វគ្គ ដែលមានសិក្ខាកាមចូលរួមចំនួន៩០៦រូប(ស្រីចំនួន២១៧រូប) មកពីក្រសួងអធិការកិច្ចទាំងថ្នាក់កណ្តាលនិងថ្នាក់រាជធានី ខេត្តចំនួន៦២៣រូប ២៨ក្រសួងស្ថាប័នចំនួន២០៥រូប សាលារាជធានីភ្នំពេញនិងខណ្ឌទាំង១៤ ចំនួន៥០រូប និងខេត្តចំនួន១៤ ចំនួន២៨រូប លើមុខជំនាញវិជ្ជាជីវៈអធិការកិច្ចបឋម ជំនាញស្តីពីគណនេយ្យ-ហិរញ្ញវត្ថុ ជំនាញស្តីពីការគ្រប់គ្រងរដ្ឋបាល ជំនាញស្តីពីសវនកម្ម ជំនាញវិធីសាស្ត្រអង្កេតស្រាវជ្រាវ និងដោះស្រាយវិវាទដីធ្លី ប្រធានបទដែលបានបណ្តុះបណ្តាលមានជាអាទិ៍ ប្រព័ន្ធនយោបាយ ប្រព័ន្ធគ្រប់គ្រងរដ្ឋ និងយុទ្ធសាស្ត្របញ្ចកោណ, ប្រព័ន្ធច្បាប់សកលនិងកម្ពុជា, ទស្សនៈទូទៅនៃការងារអធិការកិច្ច, ការទទួល និងដោះស្រាយបណ្តឹង, ស្ថាប័ននិងមន្ត្រីអធិការកិច្ច, ផែនការ កំណត់ហេតុ របាយការណ៍ និងវិធីសាស្ត្រអធិការកិច្ច។

ចាប់ពីឆ្នាំ២០០៤មកដល់ឆ្នាំ២០២៤ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការចំនួន៤១០រូប បានចូលរួមទស្សនកិច្ចសិក្សា ផ្លាស់ប្តូរបទពិសោធ និងបណ្តុះបណ្តាល នៅបណ្តាប្រទេសមួយចំនួនរួមមាន សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមការសម្របសម្រួលរបស់នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ។

## VII. កិច្ចសហប្រតិបត្តិការអន្តរជាតិ

### ក- អនុសាសន៍តម្រង់ទិសរបស់សម្តេចធិបតី

ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ តម្រង់ទិសដ៏ខ្ពង់ខ្ពស់ថា «ក្រសួងអធិការកិច្ចត្រូវ សហប្រតិបត្តិការអន្តរជាតិជាមួយ បណ្តាប្រទេស ដើម្បីលើកកម្ពស់មូលធនមនុស្ស ការផ្លាស់ប្តូរបទពិសោធល្អៗ និងឧត្តមានុវត្តន៍ជាក់ស្តែងពីគ្នា ទៅវិញទៅមក»។

### ខ- សហប្រតិបត្តិការជាមួយស្ថានទូតនានា

ក្នុងឆ្នាំ២០២៤ ថ្នាក់ដឹកនាំក្រសួងអធិការកិច្ចបានទទួលជួបសវនាការការងារ និងពិភាក្សាការងារ ជាបន្តបន្ទាប់ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយឯកឧត្តម លោកជំទាវ ឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូត និងភ្ញៀវអន្តរជាតិចំនួន៣៨លើក នៅទីស្តីការក្រសួង។

## គ- សហប្រតិបត្តិការជាមួយវៀតណាម

ក្រសួងបានចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងអធិការកិច្ចកម្ពុជា ជាមួយអគ្គអធិការកិច្ចរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមចំនួន៥លើករួមមាន លើកទី១ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៥ លើកទី២ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ លើកទី៣ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ លើកទី៤ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ និងលើកទី៥ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤។

ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០២៤ ភាគីកម្ពុជាបានធ្វើទស្សនកិច្ចទៅសាធារណរដ្ឋសង្គមនិយមវៀតណាមចំនួន១៤លើក និងបានរៀបចំទទួលដំណើរទស្សនកិច្ចរបស់ភាគីវៀតណាមនៅកម្ពុជាចំនួន១១លើក ព្រមទាំងបានចូលរួមប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាម(JC)លើកទី១៦ ទី១៧ នៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា និងលើកទី១៨ នៅទីក្រុងហាណូយនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

ក្រសួងអធិការកិច្ចបានបញ្ជូនសិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាល នៅសាធារណរដ្ឋសង្គមនិយមវៀតណាមសរុបចំនួន២៦៣នាក់ ក្នុងនោះ ចំនួន២៣៥នាក់បានទទួលការបណ្តុះបណ្តាលរយៈពេលខ្លី(ចាប់ពី១៥ថ្ងៃ ដល់១ខែ) ចំនួន១២វគ្គ ពីឆ្នាំ២០០៦ដល់ឆ្នាំ២០២៣ និងចំនួន២៨នាក់ បានទទួលការបណ្តុះបណ្តាលរយៈពេលវែង(ចាប់ពី៣ខែដល់៦ខែ)ចំនួន៥វគ្គ ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៣។

## ឃ- សហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន

អតីតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងត្រួតពិនិត្យនៃសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យអធិការកិច្ច។ បច្ចុប្បន្ន ក្រសួងកំពុងសម្របសម្រួល និងរៀបចំខ្លឹមសារអនុស្សរណៈនៃការយោគយល់គ្នាជាថ្មី ដើម្បីចុះហត្ថលេខាជាមួយគណៈកម្មាធិការជាតិត្រួតពិនិត្យ។

ក្រសួងមានកិច្ចសហប្រតិបត្តិការជាមួយក្រសួងត្រួតពិនិត្យនៃសាធារណរដ្ឋប្រជាមានិតចិន និងគណៈកម្មាធិការអធិការកិច្ចវិន័យមជ្ឈិមបក្សកុម្មុយនីស្តចិន ក្នុងបណ្តាឆ្នាំកន្លងមកបានសម្រេចផ្លែផ្កាគួរជាទីមោទនៈ ក្នុងនោះ (១)ការផ្លាស់ប្តូរគណៈប្រតិភូជាន់ខ្ពស់ទៅវិញទៅមកទាំងកម្រិតថ្នាក់ដឹកនាំ និងកម្រិតបច្ចេកទេស ដើម្បីបានដកស្រង់បទពិសោធការងារគ្នាទៅវិញទៅមក (២)ភាគីចិនបានផ្តល់វគ្គបណ្តុះបណ្តាលការងារអធិការកិច្ច និងត្រួតពិនិត្យដល់មន្ត្រីជាន់ខ្ពស់ក្រសួង សម្រាប់រយៈពេល៣ឆ្នាំចាប់ពីឆ្នាំ២០១៣ដល់ឆ្នាំ២០១៥ សរុបចំនួន១៥នាក់ (៣)ភាគីចិនបានផ្តល់ជំនួយដល់ក្រសួងចំនួន២លើក តាមរយៈស្ថានទូតចិនប្រចាំនៅកម្ពុជា ដែលលើកទី១នៅឆ្នាំ២០០៥ បានផ្តល់ជំនួយជាសម្ភារៈការិយាល័យមានតម្លៃប្រមាណ៧៩,៩៩៩ដុល្លារអាមេរិក និងលើកទី២នៅឆ្នាំ២០០៨ បានផ្តល់ជំនួយជាសម្ភារៈការិយាល័យ និងមធ្យោបាយធ្វើដំណើរ ដែលមានតម្លៃសរុបជាទឹកប្រាក់ប្រមាណ ៥០០,០០០យ័ន (៤)ភាគីកម្ពុជាបានទៅចូលរួមសន្និសីទអន្តរជាតិនានាដែលរៀបចំនៅសាធារណរដ្ឋប្រជាមានិតចិនតាមការអញ្ជើញរបស់ភាគីចិន។ គណៈប្រតិភូជាន់ខ្ពស់ចំនួន១០រូប ដឹកនាំដោយ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីកម្ពុជា** បានធ្វើទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិនចាប់ថ្ងៃទី២៤-២៨ ខែកញ្ញា ឆ្នាំ២០១៧។ ក្នុងពេលនោះ គណៈប្រតិភូបានជួបប្រជុំជាមួយឯកឧត្តម វ៉ាង ឈីសាន (Wang Qishan) លេខា (ឬប្រធាន) គណៈកម្មាធិការអធិការកិច្ចវិន័យមជ្ឈិមបក្ស នៃគណៈកម្មាធិការ មជ្ឈិមបក្ស

កុម្មុយនិស្តចិន (Central Committee for Discipline Inspection, CCDI) និងឯកឧត្តម ហ្សាវ ហុងជូ (Zhao Hongzhu) លេខានៃលេខាធិការដ្ឋាន និងជាលេខាធិការរងនៃCCDI ។

### ង- សហប្រតិបត្តិការជាមួយឥណ្ឌា

ក្រសួងបានស្នើទៅរដ្ឋាភិបាលឥណ្ឌាតាមរយៈស្ថានទូតឥណ្ឌាប្រចាំកម្ពុជា ដើម្បីបញ្ជូនមន្ត្រីអធិការកិច្ចទៅចូលរួមវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានដ៏ល្បីល្បាញរបស់រដ្ឋាភិបាលឥណ្ឌា ក្នុងកម្មវិធីសហប្រតិបត្តិការបច្ចេកទេស និងសេដ្ឋកិច្ចឥណ្ឌា (Indian Technical and Economic Cooperation, ITEC)។ ជាលទ្ធផលក្រសួងបានបញ្ជូនមន្ត្រីរាជការក្រសួងចំនួន៤០នាក់ចូលរួមវគ្គបណ្តុះបណ្តាលនៅសាធារណរដ្ឋឥណ្ឌាចំនួន២វគ្គគឺ (១)គោលនយោបាយសាធារណៈ និងអភិបាលកិច្ចសម្រាប់បុគ្គលិករដ្ឋ Public Policy and Governance for Civil Servants (នៅខែមេសា ឆ្នាំ២០២៤) ចំនួន២០នាក់ និង(២)សវនកម្មសមិទ្ធផល Performance Audit (ខែឧសភា ឆ្នាំ២០២៤) ចំនួន២០នាក់។

### ច- សហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ

ក្រសួងបានធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិមួយចំនួន រួមមាន៖

- មន្ត្រីរាជការក្រសួងមួយចំនួនបានសិក្សាភាសាអង់គ្លេសពីវិទ្យាស្ថានសន្ទនាមេគង្គ
- មន្ត្រីរាជការក្រសួងចំនួន៦៩រូបបានរៀនភាសាចិន ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការជាមួយវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិតសភាកម្ពុជា ថ្នាក់បឋមចំនួន១២រូប និងថ្នាក់មូលដ្ឋានគ្រឹះចំនួន៥៧រូប។
- អង្គការមូលនិធិអាស៊ីប្រចាំកម្ពុជាបានបើកវគ្គបណ្តុះបណ្តាលជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងចំនួន២លើក ដែលមានទឹកប្រាក់សរុបចំនួន១៥០០០ដុល្លារសហរដ្ឋអាមេរិក សម្រាប់វគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យ និងការវាយតម្លៃ
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីនៃការដាក់ពាក្យស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការអេឡិចត្រូនិចថ្មី (E passport) និងជំនាញការទូត និងទំនាក់ទំនងអន្តរជាតិ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងតាមប្រព័ន្ធអនឡាញ(ZOOM) សិក្ខាសាលាស្តីពីការចែករំលែកព័ត៌មាន បទពិសោធ និងនីតិវិធីគន្លឹះៗ ក្នុងការទទួលបានអាហារូបករណ៍ទៅប្រទេសអូស្ត្រាលី
- បានប្រជុំពិភាក្សាជាមួយអង្គការកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ចំនួន២លើក ដើម្បីពិនិត្យលទ្ធភាពសហការលើកិច្ចការតាមដាន និងវាយតម្លៃយុទ្ធសាស្ត្របញ្ចកោណ
- បានប្រជុំពិភាក្សាជាមួយអង្គការ Oxfam ចំនួន២លើក នៅទីស្តីការក្រសួង ដើម្បីពិនិត្យលទ្ធភាពរកជំនួយក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ និងគាំទ្រដល់វិទ្យាស្ថានជាតិអធិការកិច្ច។

### ឆ- សហប្រតិបត្តិការជាមួយស្ថាប័នរដ្ឋ

ក្រៅពីកិច្ចសហប្រតិបត្តិការជាមួយប្រទេស និងស្ថាប័នអន្តរជាតិ ក្រសួងក៏មានកិច្ចសហការនិងភាពជាដៃគូជាមួយស្ថាប័នរដ្ឋដូចខាងក្រោម៖

- បានបញ្ជូនមន្ត្រីនិងថ្នាក់ដឹកនាំដើម្បីចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការតាក់តែងលិខិតរដ្ឋបាល និងលិខិតគតិយុត្តនៅសាលាភូមិន្ទរដ្ឋបាលចំនួន១១២រូប

- បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ជាមួយ ១)មន្ទីរពេទ្យកេតុមាលា ២)ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ៣)ក្រសួងព័ត៌មាន ៤)វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ៥)សាលាភូមិន្ទរដ្ឋបាលនៃក្រសួងមុខងារសាធារណៈ ៦)គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

## VIII. ការធ្វើបរិវត្តកម្មឌីជីថល

### ក- អនុសាសន៍តម្រង់ទិសរបស់សម្តេចធិបតី

ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍តម្រង់ទិសដ៏ខ្ពង់ខ្ពស់ថា ក្រសួងអធិការកិច្ច ត្រូវសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការពង្រឹងការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការរបស់ខ្លួន ជាពិសេសលើផ្នែកអក្ខរកម្មឌីជីថល ដើម្បីជំរុញការធ្វើបរិវត្តកម្មឌីជីថលអធិការកិច្ច ក្នុងបរិបទឌីជីថល និងធ្វើទំនើបកម្មស្ថាប័ន សំដៅឈានដល់ការសម្រេចអធិការកិច្ចដោយប្រើបច្ចេកវិទ្យាឌីជីថល។

### ខ- សកម្មភាពក្រុមការងារបរិវត្តកម្មឌីជីថលក្រសួងអធិការកិច្ច

- បង្កើតគេហទំព័ររបស់ក្រសួងអធិការកិច្ច (www.inspection.gov.kh) សម្រាប់ផ្សព្វផ្សាយនូវព័ត៌មានសកម្មភាពការងារ បណ្ណុំឯកសារសាធារណៈនានា និងទទួលពាក្យបណ្តឹងអនឡាញរបស់ក្រសួងអធិការកិច្ច
- បង្កើតថ្នាល (Mobile App) ក្រសួងអធិការកិច្ច សម្រាប់ប្រើលើទូរសព្ទ និងឧបករណ៍ឆ្លាតវៃនានា ដែលប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការ iOS និង Android
- រៀបចំស្តង់ដារហេដ្ឋារចនាសម្ព័ន្ធឌីជីថល តខ្សែបណ្តាញប្រព័ន្ធអ៊ីនធឺណែត និងបណ្តាញ Network នៅក្នុងបរិវេណទីស្តីការក្រសួងអធិការកិច្ច
- តម្លើងប្រព័ន្ធកាំមេរ៉ាសុវត្ថិភាពនៅទីស្តីការក្រសួងចំនួន៥៨គ្រាប់ សម្រាប់ផ្តិតយកសកម្មភាពនានានៅក្នុងបរិវេណក្រសួង ជាឧបករណ៍ឆ្លាតវៃសម្រាប់រក្សាសុវត្ថិភាពសម្ភារៈផ្សេងៗរបស់ក្រសួង
- តម្លើង Screen LED ក្នុងសាលប្រជុំ សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ដែលជាឧបករណ៍ឆ្លាតវៃសម្រាប់បង្ហាញមាតិកាព័ត៌មានក្នុងកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំ
- តម្លើងទូរទស្សន៍ LCD នៅទីស្តីការក្រសួងអគារ A សម្រាប់ផ្តល់ព័ត៌មានស្តីពីកម្មវិធីប្រជុំនានា និងសកម្មភាពការងាររបស់ថ្នាក់ដឹកនាំក្រសួង
- តម្លើងប្រព័ន្ធបណ្តាញទូរសព្ទ លេខកូដខ្លី (Hotline) ១២៦៨ ចំនួន១ខ្សែ ដែលប្រើសម្រាប់ទទួលការហៅចូលពីសាធារណជន ក្នុងការសាកសួរព័ត៌មានទូទៅ និងសម្រាប់ដាក់ពាក្យបណ្តឹងមកកាន់ក្រសួងអធិការកិច្ច។ សាធារណជនអាចធ្វើការហៅចូលដោយចុចលេខ១ មាន Extension ចំនួន២គ្រឿង (IP Phone) សម្រាប់ទទួលការសាកសួរព័ត៌មានទូទៅ និងចុចលេខ២ មានExtension ចំនួន៣គ្រឿង (IP Phone) សម្រាប់ទទួលការដាក់ពាក្យបណ្តឹង

- តម្លើងម៉ាស៊ីនមេ (Server) សម្រាប់ផ្ទុកទិន្នន័យ និងចែករំលែកទិន្នន័យទៅកាន់អង្គភាពក្រោមឱវាទក្រសួង
- តម្លើងប្រព័ន្ធ Zoom Meeting សម្រាប់កិច្ចប្រជុំតាមអនឡាញនៅក្នុងសាលប្រជុំសម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន។

### គ- សកម្មភាពការងារអនុវត្តតាមអនុស្សរណៈរវាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងអធិការកិច្ច

ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រសួងអធិការកិច្ច និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ការតភ្ជាប់បណ្តាញអ៊ីនធឺណែត និងការរៀបចំវគ្គបណ្តុះបណ្តាលជំនាញឌីជីថលជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងអធិការកិច្ច។

លទ្ធផលនៃការអនុវត្តអនុស្សរណៈនៃការយោគយល់រវាងស្ថាប័នទាំងពីរសម្រេចបានដូចខាងក្រោម៖

១. កិច្ចសហប្រតិបត្តិការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ (VERIFY.GOV.KH)

ក្រុមការងារបរិវត្តកម្មឌីជីថលក្រសួងអធិការកិច្ចបានរៀបចំ QR Code ស្តង់ដារនៃថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh នៅលើវិញ្ញាបនបត្របញ្ជាក់ការសិក្សា នៃវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចរបស់វិទ្យាស្ថានជាតិអធិការកិច្ចចំនួន៤លើក សរុបស្មើនឹង២០៨វិញ្ញាបនបត្រ ក្នុងនោះមាន វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចស្តីពី «វិធីសាស្ត្រអង្កេតស្រាវជ្រាវ និងដោះស្រាយវិវាទដីធ្លី» ចំនួន៥៤ វិញ្ញាបនបត្រ វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចបឋមជំនាន់ទី៦ វគ្គ១+២ ចំនួន៥២វិញ្ញាបនបត្រ វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចបឋមជំនាន់ទី៦ វគ្គ៣+៤ ចំនួន៥២វិញ្ញាបនបត្រ និងវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចបឋមជំនាន់ទី៦ វគ្គ៥+៦ ចំនួន៥០វិញ្ញាបនបត្រ។

២. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់បណ្តាញអ៊ីនធឺណែត

- ក្រុមការងារបរិវត្តកម្មឌីជីថលក្រសួងអធិការកិច្ច បានសហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រៀបចំហេដ្ឋារចនាសម្ព័ន្ធនិងតភ្ជាប់បណ្តាញអ៊ីនធឺណែតថ្មី ព្រមទាំងបែងចែកល្បឿនអ៊ីនធឺណែតតាមការកំណត់ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការសម្រាប់ប្រើប្រាស់នៅទីស្តីការក្រសួងរួចរាល់
- រៀបចំបន្ទប់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យរួម (Data Center) សម្រាប់ប្រើប្រាស់ជាមជ្ឈមណ្ឌលគ្រប់គ្រង និងបែងចែកប្រព័ន្ធព័ត៌មានវិទ្យា សេវាអ៊ីនធឺណែត និងទិន្នន័យរួម (Database) នៅទីស្តីការក្រសួងអធិការកិច្ច
- បានរៀបចំ និងបំពាក់សម្ភារៈបរិក្ខារអ៊ីនធឺណែតថ្មីបន្ថែម រួមមាន តម្លើងទូ Main Server (ទូ Rack) នៅបន្ទប់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យរួម សម្រាប់ផ្ទុកសម្ភារៈបរិក្ខារមេ (Router, Switch និងខ្សែបណ្តាញមេ)និងតម្លើងទូ Sub Server (ទូ Rack) ចំនួន២ទីតាំងទៀតនៅអគារB និងអគារC ដើម្បីបំពេញតាមតម្រូវការប្រើប្រាស់នៅទីស្តីការក្រសួងអធិការកិច្ច

- បំពាក់ឧបករណ៍ចែកសេវាអ៊ីធឺណែត Access Point (WiFi Router) ចំនួន៧៤គ្រឿង និងប្រអប់ភ្ជាប់អ៊ីនធឺណែត (Outlet) ចំនួន១១៩ប្រអប់ តាមអគារនិងបន្ទប់នីមួយៗ។

៣. ការផ្គត់ផ្គង់សម្ភារៈបរិក្ខារបច្ចេកវិទ្យាឌីជីថល

- ក្រសួងអធិការកិច្ចបានទទួល Server ចំនួន១គ្រឿង និងកុំព្យូទ័រ ចំនួន១៨៧គ្រឿង (កុំព្យូទ័រយួរដៃចំនួន១០០គ្រឿង និងកុំព្យូទ័រលើតុចំនួន៨៧គ្រឿង) ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងអធិការកិច្ចបានសហការជាមួយក្រុមការងារបច្ចេកទេសក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀបចំតម្លើងគណនីសម្រាប់អ្នកប្រើប្រាស់លើកុំព្យូទ័រយួរដៃ និងកុំព្យូទ័រលើតុទាំង១៨៧គ្រឿង (Active Directory and Microsoft office 365 license) ដើម្បីផ្តល់ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការតាមបណ្តាអង្គភាពចំណុះក្រសួងប្រើប្រាស់ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។

## ផ្នែកទី៣៖ បញ្ហាប្រឈម

ទន្ទឹមនឹងវឌ្ឍនភាពដែលសម្រេចបានជាច្រើនក្នុងរយៈពេលកន្លងមក វិស័យអធិការកិច្ចនៅមានបញ្ហាប្រឈម និងចំណុចខ្វះខាតមួយចំនួនរួមមាន៖ (១)ក្រសួងស្ថាប័នមួយចំនួនពុំទាន់យល់ច្បាស់ពីមុខងារភារកិច្ច និងឋានានុក្រមអធិការកិច្ច, (២)ក្រសួងស្ថាប័នមួយចំនួនបានកសាងលិខិតបទដ្ឋានគតិយុត្តជាបន្តបន្ទាប់ ដែលប៉ះពាល់ដល់សមត្ថកិច្ចក្រសួងអធិការកិច្ច, (៣)កិច្ចសហការរបស់ក្រសួង ស្ថាប័ន និងអង្គភាពវេងអធិការកិច្ច និងការតាមដានការអនុវត្តច្បាប់មួយចំនួននៅមានកម្រិត, (៤)ពុំមានយន្តការតាមដាន ត្រួតពិនិត្យលើរបាយការណ៍លទ្ធផលការងារអធិការកិច្ច និងការងារតាមដានការអនុវត្តច្បាប់, (៥)ពុំមានយន្តការតាមដានត្រួតពិនិត្យលើមុខងារអធិការកិច្ចរបស់ក្រសួងស្ថាប័ន, (៦)ពុំទាន់មានផែនការអធិការកិច្ចរួមស្របទៅនឹងអភិក្រមទាំង ៧ សម្រាប់អនុវត្តលើវិស័យអធិការកិច្ចនៅឡើយ, (៧)យន្តការដោះស្រាយបណ្តឹងពុំទាន់ឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង, (៨)ខ្វះកិច្ចសហការពេញលេញពីភាគីពាក់ព័ន្ធក្នុងដំណើរការដោះស្រាយបណ្តឹង, (៩)ការវិភាគ វាយតម្លៃ និងស្ទង់មតិក្នុងដំណើរការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈនៅមានកម្រិត, (១០)មូលដ្ឋាននៃការកំណត់លិខិតបទដ្ឋានគតិយុត្ត ប្រធានបទ និងគោលដៅក្នុងការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈពុំទាន់ច្បាស់លាស់, (១១)ការចូលរួម និងការយល់ពីសារៈសំខាន់នៃការផ្សព្វផ្សាយអប់រំច្បាប់និងវេទិកាសាធារណៈរបស់ប្រជាពលរដ្ឋនៅមានកម្រិត, (១២)កត្តាធនធានមនុស្ស ក្រមសីលធម៌វិជ្ជាជីវៈ និងវិន័យនៅមានកម្រិត, (១៣)លិខិតបទដ្ឋានគតិយុត្តមិនគ្រប់គ្រាន់, (១៤)ប្រព័ន្ធតាមដាននិងវាយតម្លៃលទ្ធផលការងារនៅមានកម្រិត, (១៥)ប្រព័ន្ធលើកទឹកចិត្តនៅមានកម្រិត, (១៦)កញ្ចប់ថវិកានៅមានកម្រិតពុំទាន់ឆ្លើយតបទៅនឹងទំហំការងារ, (១៧)កត្តាធនធានមនុស្សនិងសម្ភារៈបរិក្ខារឌីជីថលនៅមានកម្រិត, (១៨)កិច្ចសហប្រតិបត្តិការ និងការគាំទ្រពីជាតិនិងអន្តរជាតិនៅមានកម្រិត, (១៩)ការបណ្តុះបណ្តាលក្នុងវិស័យអធិការកិច្ចមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅឡើយ, (២០)ជាទូទៅតម្រូវការជាក់ស្តែង បេសកកម្មលើការងារអធិការកិច្ច ការងារតាមដានការអនុវត្តច្បាប់ ការងារដោះស្រាយបណ្តឹង មានរយៈពេលលើសពី ៩យប់ ១០ថ្ងៃ ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងចំណោមបញ្ហាប្រឈមខាងលើ មានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃការដឹកនាំនិងគ្រប់គ្រងវិស័យអធិការកិច្ច ទាមទារឱ្យមានដំណោះស្រាយជាប្រព័ន្ធឱ្យបានឆាប់រហ័ស៖

ចាប់តាំងពីពេលបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅឆ្នាំ១៩៩៩ ការអនុវត្តតួនាទីភារកិច្ចក្នុងវិស័យអធិការកិច្ច គឺពឹងផ្អែកស្ទើរទាំងស្រុងលើអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ដោយពុំមានលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ ដែលធ្វើឱ្យការអនុវត្តតួនាទីភារកិច្ចក្នុងការងារអធិការកិច្ច ការងារដោះស្រាយបណ្តឹង ការងារតាមដានការអនុវត្តច្បាប់ និងការងារអប់រំផ្សព្វផ្សាយច្បាប់ ជួបបញ្ហាលំបាកជាច្រើន។ សេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចត្រូវបានចាប់ផ្តើមរៀបចំចាប់តាំងពីឆ្នាំ២០០៩ រហូតមកដល់បច្ចុប្បន្ន និងបានសម្របសម្រួលកម្រិតខ្ពស់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ប៉ុន្តែពុំទាន់បានសម្រេចលទ្ធផលតាមការគ្រោងទុកនៅឡើយ។ ជាមួយគ្នានេះ ក្រសួង ស្ថាប័នមួយចំនួនក៏បានកសាងលិខិតបទដ្ឋានគតិយុត្តជាបន្តបន្ទាប់ ដោយបានកំណត់សមត្ថកិច្ច និងសិទ្ធិអំណាចធ្វើអធិការកិច្ចរបស់ខ្លួនទៅជ្រកក្រោមច្បាប់ជំនាញផ្សេងៗ ធ្វើឱ្យប៉ះពាល់សមត្ថកិច្ចក្រសួងអធិការកិច្ចក្នុងការដឹកនាំនិងគ្រប់គ្រងវិស័យអធិការកិច្ច ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតក្រសួងអធិការកិច្ច និងមិនមានសុខដុមនីយកម្មក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។ ជារួម បច្ចុប្បន្ននេះ ពុំទាន់មានយន្តការប្រកបដោយប្រសិទ្ធភាព ក្នុងការសម្របសម្រួលនិងដោះស្រាយបញ្ហារំលោភសមត្ថកិច្ច ក្នុងវិស័យអធិការកិច្ចនៅឡើយ។

លើសពីនេះ ក្រសួង ស្ថាប័នមួយចំនួនមានការរួញរាក្នុងកិច្ចសហការ ឬគេចវេះ ឬព្យាយាមពន្យារពេល ឬមិនផ្តល់ឯកសារ ឬផ្តល់ឯកសារមិនគ្រប់គ្រាន់ ឬបង្កការលំបាកផ្សេងៗ ក្នុងគោលបំណងបង្ការរាំងស្ទះការងាររបស់គណៈប្រតិភូក្រសួងអធិការកិច្ច។ ប្រធានអង្គភាពរងអធិការកិច្ចនិងតាមដានការអនុវត្តច្បាប់មួយចំនួន ពុំចុះហត្ថលេខាលើរបាយការណ៍ដែលបានរកឃើញនូវកំហុសឆ្គងដែលប៉ះពាល់ដល់បុគ្គល ឬស្ថាប័នសាមី និងមានភាពយឺតយ៉ាវក្នុងការឆ្លើយតបលើរបាយការណ៍ស្តីពីលទ្ធផលអធិការកិច្ចនិងការតាមដានការអនុវត្តច្បាប់។ ក្រៅពីនេះ ទំនាក់ទំនងជាបណ្តាញ និងការអនុវត្តការងារតាមឋានានុក្រមនៃដែនសមត្ថកិច្ច រវាងអធិការកិច្ចរាជរដ្ឋាភិបាលជាមួយអធិការកិច្ចតាមក្រសួង ស្ថាប័ន និងអធិការកិច្ចនៅតាមរាជធានី ខេត្ត នៅមានកម្រិត។

ពាក្យបណ្តឹងដែលបានទទួលពីប្រជាពលរដ្ឋភាគច្រើនជាពាក្យបណ្តឹងសាំញ៉ាំ ស្មុគស្មាញ រ៉ាំរ៉ៃ មិនទាន់មានការផ្តន្ទាទោសឬដាក់ពិន័យចំពោះ (ក)មន្ត្រីមួយចំនួនដែលបានកសាងឯកសារមានភាពមិនប្រក្រតី (ខ)បុគ្គលខិលខូចដែលតែងតែចិញ្ចឹមចិត្តយកវប្បធម៌ឈ្នះបានដី ចាញ់បានលុយ និង(គ)បុគ្គលពាក់ព័ន្ធមួយចំនួនបានគេចវេសមិនចូលរួមផ្តល់ការបំភ្លឺ និងឯកសារពាក់ព័ន្ធតាមកាលកំណត់នៃការអញ្ជើញ និងខ្លះទៀតមិនចូលខ្លួនមកបំភ្លឺតាមការអញ្ជើញរបស់គណៈប្រតិភូក្រសួង និងមិនអាចទទួលបានព័ត៌មានពីសាក្សី ប្រជាពលរដ្ឋដែលត្រូវបំភ្លឺ និងវត្ថុតាងមួយចំនួនចាស់ យូរ ឬបាត់រូបរាងជាដើម និងប្រជាពលរដ្ឋខ្លះមានការផ្លាស់ទីលំនៅទៅឆ្ងាយឬទៅធ្វើការងារនៅក្រៅប្រទេសមិនអាចទំនាក់ទំនងបាន ខ្លះចាស់ជរា មានជំងឺ បាត់បង់កាយសម្បទានិងសតិស្មារតី។ ជាមួយគ្នានេះ ក្រសួង ស្ថាប័ន អង្គភាព និងអាជ្ញាធរដែនដីពាក់ព័ន្ធមួយចំនួនពុំទាន់មានកិច្ចសហការល្អដូចជា យឺតយ៉ាវក្នុងការឆ្លើយតបចំពោះពាក្យបណ្តឹងដែលក្រសួងអធិការកិច្ចបានបញ្ជូនជាសមត្ថកិច្ច មិនបានផ្តល់ពេលវេលាជួបពេលគណៈប្រតិភូរបស់ក្រសួងចុះទៅទីតាំង និងមិនបានផ្តល់ឯកសារពាក់ព័ន្ធជាដើម។

មន្ត្រីអធិការកិច្ចដែលមានស្នាដៃល្អក្នុងការប្រមូលមកវិញនូវទ្រព្យសម្បត្តិរដ្ឋ ថវិការបស់ជាតិដែលបានបាត់បង់ដោយអំពើទុច្ចរិតរបស់មន្ត្រីសាធារណៈ ពុំទាន់មានការលើកទឹកចិត្តជាថវិកាសម្រាប់ឧបត្ថម្ភបន្ថែម។

## I. ការងារអធិការកិច្ច

ចាប់តាំងពីពេលបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅឆ្នាំ១៩៩៩ ការអនុវត្តតួនាទី ភារកិច្ចលើវិស័យអធិការកិច្ច គឺពឹងផ្អែកលើអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងតែមួយ ពុំមានលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ ធ្វើឱ្យការអនុវត្តតួនាទី ភារកិច្ចក្នុងការងារអធិការកិច្ច ជួបបញ្ហាលំបាកជាច្រើន។

ក្រសួងបានរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីអធិការកិច្ចចាប់តាំងពីឆ្នាំ២០០៩ រហូតមកដល់បច្ចុប្បន្ន និងបានសម្របសម្រួលកម្រិតខ្ពស់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ប៉ុន្តែពុំទាន់បានសម្រេចលទ្ធផលតាមការគ្រោងទុកនៅឡើយ។ ជាមួយគ្នានេះ ក្រសួង ស្ថាប័នមួយចំនួនក៏បានកសាងលិខិតបទដ្ឋានគតិយុត្តរបស់ខ្លួនជាបន្តបន្ទាប់ ជាហេតុនាំឱ្យប៉ះពាល់ដល់សមត្ថកិច្ចរបស់ក្រសួងអធិការកិច្ច ជាសេនាធិការរបស់រាជរដ្ឋាភិបាលលើវិស័យអធិការកិច្ចដែលពុំស្របតាមច្បាប់ស្ដីពីការបង្កើតក្រសួងអធិការកិច្ច។

ផ្ដើមចេញពីកង្វះខាតផ្នែកលិខិតបទដ្ឋានគតិយុត្តខាងលើ បណ្ដាលឱ្យមានបញ្ហាប្រឈមដល់ប្រតិបត្តិការការងារអធិការកិច្ច។ ក្រសួង ស្ថាប័នមួយចំនួនមានការរួញរាក្នុងកិច្ចសហការ ឬព្យាយាមពន្យារពេល ឬមិនផ្ដល់ឯកសារ ឬបង្កការលំបាកផ្សេងៗ ក្នុងគោលបំណងបង្ការរាំងស្ទះការងារអធិការកិច្ចរបស់ក្រសួងអធិការកិច្ច។ ជាមួយគ្នានេះ ក្នុងដំណើរនៃការធ្វើអធិការកិច្ច ចាប់ពីពេលចាប់ផ្ដើមរហូតដល់ពេលពិនិត្យរបាយការណ៍បញ្ចប់ គណៈប្រតិភូអធិការកិច្ចតែងជួបនូវបញ្ហាប្រឈមជាច្រើនដូចជា ការចុះធ្វើអធិការកិច្ចត្រូវឆ្លងការឯកភាពពីប្រធានស្ថាប័ន ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្តដែលរងអធិការកិច្ច ការពន្យារពេលវេលានៃការចុះធ្វើអធិការកិច្ច ដោយលើកហេតុផលផ្សេងៗក្នុងគោលបំណងបង្ការរាំងស្ទះ គេចវេះ មិនផ្ដល់ឯកសារ ឬផ្ដល់ឯកសារមិនគ្រប់គ្រាន់តាមការស្នើសុំ។ល។ ទន្ទឹមនេះ មានពេលខ្លះមន្ត្រីអធិការកិច្ចត្រូវបានរងការចោទប្រកាន់ថាមករកតែរឿងចាប់កំហុស មករំខានការងារ មកបំបែកបំបាក់សាមគ្គីភាពផ្ទៃក្នុងរបស់អង្គភាពខ្លួន ឬមករកលាភសក្ការៈជាដើម។ ប្រធានអង្គភាពរងអធិការកិច្ចមួយចំនួនពុំចុះហត្ថលេខាលើរបាយការណ៍អធិការកិច្ច ក្នុងករណីរបាយការណ៍នោះបានលើកឡើងអំពីកំហុសឆ្គងដែលប៉ះពាល់ដល់បុគ្គល ឬស្ថាប័នសាមី និងមានភាពយឺតយ៉ាវក្នុងការឆ្លើយតបលើរបាយការណ៍ស្ដីពីលទ្ធផលអធិការកិច្ច។

ក្រៅពីនេះ ទំនាក់ទំនងជាបណ្ដាញ និងការអនុវត្តការងារតាមឋានានុក្រមនៃដែនសមត្ថកិច្ច រវាងអធិការកិច្ចរាជរដ្ឋាភិបាល ជាមួយអធិការកិច្ចតាមក្រសួង ស្ថាប័ន និងអធិការកិច្ចនៅតាមរាជធានី ខេត្ត នៅមានកម្រិត។

មន្ត្រីអធិការកិច្ចដែលមានស្នាដៃល្អក្នុងការប្រមូលមកវិញនូវទ្រព្យសម្បត្តិរដ្ឋ ថវិការបស់ជាតិដែលបានបាត់បង់ដោយអំពើទុច្ចរិតរបស់មន្ត្រីសាធារណៈ ពុំទាន់មានការលើកទឹកចិត្តជាថវិកាសម្រាប់ឧបត្ថម្ភបន្ថែម។

## II. ការងារទទួលនិងដោះស្រាយបណ្ដឹង

ការងារទទួលនិងដោះស្រាយបណ្ដឹងមានបញ្ហាប្រឈមធំៗចំនួន២គឺ (១)មិនទាន់មានច្បាប់បណ្ដឹងតវ៉ា និងច្បាប់បណ្ដឹងបរិហារ ដែលជាត្រីវិស័យក្នុងការអនុវត្តការងារឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាពខ្ពស់ និងមន្ត្រីមិនទាន់មានឯកសណ្ឋានជាផ្លូវការសម្រាប់ចុះបំពេញបេសកកម្មនិងបំពេញការងារប្រចាំថ្ងៃ និង(២)ពាក្យបណ្ដឹងដែលបានទទួលពីប្រជាពលរដ្ឋភាគច្រើនជាពាក្យបណ្ដឹង សាំញ៉ាំ ស្មុគស្មាញ រ៉ាំរ៉ៃ ម្ចាស់បណ្ដឹងបានដាក់ពាក្យបណ្ដឹង

ចូលច្រើនកន្លែងនិងច្រើនស្ថាប័ន មិនទាន់មានការផ្តន្ទាទោស ឬដាក់ពិន័យចំពោះ ៖ (ក)មន្ត្រីមួយចំនួនដែលបានកសាងឯកសារមានភាពមិនប្រក្រតី ជាពិសេសឯកសារកាន់កាប់ដីធ្លីឬលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យជាន់គ្នា ដោយខ្វះការទទួលខុសត្រូវនិងការចេញបណ្ណសម្គាល់ម្ចាស់អចលនវត្ថុឱ្យភាគីវិវាទម្ខាងទៀត ក្នុងអំឡុងពេលគណៈ-ប្រតិភូក្រសួងកំពុងចុះអង្កេតស្រាវជ្រាវ (ខ)បុគ្គលខិលខូចដែលតែងតែចិញ្ចឹមចិត្តយកវប្បធម៌ឈ្នះបានដី ចាញ់បានលុយ និង(គ)បុគ្គលពាក់ព័ន្ធមួយចំនួនបានគេចវេះមិនចូលរួមផ្តល់ការបំភ្លឺនិងឯកសារពាក់ព័ន្ធតាមកាលកំណត់នៃការអញ្ជើញ និងខ្លះទៀតមិនចូលខ្លួនមកបំភ្លឺតាមការអញ្ជើញរបស់គណៈប្រតិភូក្រសួង និងមិនអាចទទួលបានព័ត៌មានពីសាក្សី ប្រជាពលរដ្ឋដែលត្រូវបំភ្លឺ និងវត្ថុតាងមួយចំនួនចាស់ យូរ ឬបាត់រូបរាងជាដើម និងប្រជាពលរដ្ឋខ្លះមានការផ្លាស់ទីលំនៅទៅឆ្ងាយឬទៅធ្វើការងារនៅក្រៅប្រទេសមិនអាចទំនាក់ទំនងបាន ខ្លះចាស់ជរា មានជំងឺបាត់បង់កាយសម្បទានិងសតិស្មារតី។ ជាមួយគ្នានេះ ក្រសួង ស្ថាប័ន អង្គភាព និងអាជ្ញាធរដែនដីពាក់ព័ន្ធមួយចំនួនពុំទាន់មានកិច្ចសហការល្អដូចជា យឺតយ៉ាវ ក្នុងការឆ្លើយតបចំពោះពាក្យបណ្តឹងដែលក្រសួងអធិការកិច្ចបានបញ្ជូនជាសមត្ថកិច្ច មិនបានផ្តល់ពេលវេលាជួបនៅពេលគណៈប្រតិភូរបស់ក្រសួងចុះទៅទីតាំង និងមិនបានផ្តល់ឯកសារពាក់ព័ន្ធជាដើម។

## III. ការងារតាមដានការអនុវត្តច្បាប់

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលគួរឱ្យកត់សម្គាល់កន្លងមក ការងារតាមដានការអនុវត្តច្បាប់នៅមានបញ្ហាប្រឈមមួយចំនួនដូចជា ពុំមានយន្តការតាមដាន ត្រួតពិនិត្យលើរបាយការណ៍លទ្ធផលការងារអធិការកិច្ចនិងការងារតាមដានការអនុវត្តច្បាប់ ពុំមានលិខិតបទដ្ឋានគតិយុត្តក្នុងការងារតាមដានការអនុវត្តច្បាប់ កិច្ចសហការរបស់មុខសញ្ញាដែលត្រូវរងការតាមដានត្រួតពិនិត្យការអនុវត្តច្បាប់នៅមានកម្រិត ការឆ្លើយតបរបស់ក្រសួង ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិលើរបាយការណ៍ស្តីពីលទ្ធផលនៃការចុះតាមដានការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាលនៅមានភាពយឺតយ៉ាវជាដើម។

## IV. ការងារអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ

ការងារអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ នៅមានបញ្ហាប្រឈមមួយចំនួន រួមមាន (១)ការវិភាគវាយតម្លៃ និងស្ទង់មតិក្នុងដំណើរការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈនៅមានកម្រិត, (២)មូលដ្ឋាននៃការកំណត់លិខិតបទដ្ឋានគតិយុត្ត ប្រធានបទ និងគោលដៅក្នុងការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈពុំទាន់ច្បាស់លាស់, (៣)ការចូលរួម និងការយល់ពីសារៈសំខាន់នៃការផ្សព្វផ្សាយអប់រំច្បាប់និងវេទិកាសាធារណៈរបស់ប្រជាពលរដ្ឋនៅមានកម្រិត, និង(៤)មធ្យោបាយនៃការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈនៅមានកម្រិត។

## V. ការងារកសាងលិខិតបទដ្ឋានគតិយុត្ត

### ក- ការប្រឈមផ្ទៃក្នុង

### ១- កង្វះធនធានមនុស្ស

ការរៀបចំលិខិតបទដ្ឋានគតិយុត្តទាមទារធនធានមនុស្សដែលមានជំនាញចម្រុះដូចជា ចំណេះដឹងផ្នែកច្បាប់ ផ្នែកគោលនយោបាយ ផ្នែកសិក្សាស្រាវជ្រាវ ផ្នែកអធិការកិច្ច រួមទាំងបទពិសោធ និងមានការចូលរួមពីជំនាញពាក់ព័ន្ធដទៃទៀត សម្រាប់កសាងលិខិតបទដ្ឋានគតិយុត្តឱ្យបានល្អ គ្រប់ជ្រុងជ្រោយ មានប្រសិទ្ធភាព និងមានសង្គតិភាព។

### ២- យន្តការក្រុមការងារមានកម្រិត

ក្រុមការងារតាក់តែងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង បង្កើតឡើងដោយមានសមាសភាពថ្នាក់ដឹកនាំក្រសួង និងមន្ត្រីជំនាញដែលមានភារកិច្ចស្នូលរៀងៗខ្លួន ធ្វើឱ្យការរៀបចំយន្តការសម្រាប់ដំណើរការតាមផ្នែកនីមួយៗជាអចិន្ត្រៃយ៍មិនអាចប្រព្រឹត្តទៅបាន។ ទន្ទឹមនេះ មន្ត្រីក្រុមជំនួយការសុទ្ធតែមានភារកិច្ចស្នូលរៀងៗខ្លួនដែលធ្វើឱ្យជួបនូវការប្រឈមសម្រាប់ការប្រព្រឹត្តទៅរបស់ក្រុមការងារតាក់តែងលិខិតបទដ្ឋានគតិយុត្ត។

### ខ- ការប្រឈមផ្នែកក្រៅ

### ១- កង្វះខាតការគាំទ្រពីក្រសួង ស្ថាប័ន

លិខិតបទដ្ឋានគតិយុត្តដែលក្រសួងរៀបចំឡើងត្រូវបានក្រសួង ស្ថាប័នមួយចំនួនជំទាស់ ឬមិនគាំទ្រទៅលើតួនាទី ភារកិច្ច សិទ្ធិអំណាច និងសមត្ថកិច្ចរបស់ក្រសួងអធិការកិច្ច។ កត្តានេះធ្វើឱ្យក្រសួងជួបការប្រឈមស្មុគស្មាញក្នុងឱកាសឆ្លងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តម្តងៗ ហើយក៏ជាមូលហេតុបណ្តាលឱ្យក្រសួងដែលបានកកើតក្នុងរយៈ២៦ឆ្នាំ ពុំអាចកសាងបាននូវលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្ត ក្រៅពីអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ។ កង្វះខាតការគាំទ្រពីបណ្តាក្រសួង ស្ថាប័ន ចំពោះក្រសួងអធិការកិច្ចបានជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃការធ្វើអធិការកិច្ច។

### ២- កង្វះកិច្ចសហប្រតិបត្តិការ

អង្គភាពអធិការកិច្ចនៅតាមក្រសួង ស្ថាប័ន ដែលមានសមត្ថកិច្ចធ្វើអធិការកិច្ចពុំមានឆន្ទៈខ្ពស់ក្នុងការចូលរួមជាមួយក្រសួងអធិការកិច្ចក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអធិការកិច្ចទាំងមូល។

កិច្ចសហប្រតិបត្តិការ និងការគាំទ្រពីដៃគូជាតិ និងអន្តរជាតិលើការងាររៀបចំលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងអធិការកិច្ចក៏មិនទាន់មាន បណ្តាលឱ្យការប្រព្រឹត្តទៅរបស់ក្រុមការងារតាក់តែងលិខិតបទដ្ឋានគតិយុត្តបានជួបនូវបញ្ហាប្រឈមផ្នែកធនធានមនុស្ស ធនធានសម្ភារៈ ថវិកា និងការប្រឹក្សាយោបល់។

### ៣- ការកសាងលិខិតបទដ្ឋានគតិយុត្តដាច់ដោយដុំៗ

ក្រសួង ស្ថាប័នមួយចំនួនបានកំណត់សមត្ថកិច្ច សិទ្ធិអំណាចធ្វើអធិការកិច្ចរបស់ខ្លួន ទៅជ្រកក្រោមច្បាប់ជំនាញផ្សេងៗ ដែលធ្វើឱ្យលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអធិការកិច្ចពុំមានលក្ខណៈប្រមូលផ្តុំ។ ការកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអធិការកិច្ចទាំងនោះ ពុំបានឆ្លងឬពុំបានពិភាក្សាជាមួយក្រសួងអធិការកិច្ចដែលមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យអធិការកិច្ចនៃព្រះរាជាណាចក្រកម្ពុជាឡើយ។

### ៤- ការកសាងលិខិតបទដ្ឋានគតិយុត្តដោយរំលោភសមត្ថកិច្ច

ច្បាប់ស្តីពីការបង្កើតក្រសួងចែងថា ក្រសួងអធិការកិច្ចមានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងវិស័យអធិការកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ហើយអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ចចែងថា ក្រសួងអធិការកិច្ចមានភារកិច្ចធ្វើអធិការកិច្ចលើគ្រប់វិស័យ ផ្ទុយទៅវិញក្រសួងអធិការកិច្ចពុំអាចអនុវត្តបានពេញលេញតាមខ្លឹមសារដែលបានកំណត់នេះទេ ដោយៈ

- ការដឹកនាំ ចាត់ចែងនិងបែងចែកសមត្ថកិច្ចធ្វើអធិការកិច្ច ជាសមត្ថកិច្ចក្រសួងផ្សេង

- ក្រសួង ស្ថាប័នមួយចំនួនកសាងលិខិតបទដ្ឋានគតិយុត្តហាមឃាត់សមត្ថកិច្ចក្រសួងអធិការកិច្ច មិនឱ្យមានតួនាទីធ្វើអធិការកិច្ចលើស្ថាប័នរបស់ខ្លួន។

### ៥- យន្តការសម្របសម្រួល និងដោះស្រាយការរំលោភសមត្ថកិច្ចនៅមានកម្រិត

យន្តការសម្របសម្រួលសម្រាប់ដោះស្រាយ ក្នុងការរៀបចំសេចក្ដីព្រាងច្បាប់ ដើម្បីចៀសវាងវិវាទរវាងបទប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់នោះជាមួយនឹងច្បាប់ដែលចូលជាធរមាន វិវាទច្បាប់និងការបកស្រាយច្បាប់សម្រាប់ដោះស្រាយបញ្ហាមិនយល់ស្របគ្នាលើខ្លឹមសារ និងការរំលោភបំពានលើសមត្ថកិច្ចនៃស្ថាប័ននីមួយៗនៅមានកម្រិត។ កង្វះខាតយន្តការនេះ ធ្វើឱ្យការរៀបចំលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នមិនស្របគំនិតគ្នា ពុំត្រឹមត្រូវតាមសមត្ថកិច្ច ពុំមានសង្គតិភាពនិងសុខដុមនីយកម្មលើគតិយុត្ត ក៏ដូចជាសុខដុមនីយកម្មលើស្ថាប័ន។

## VI. ការងារបរិវត្តកម្មឌីជីថល

ចាប់តាំងពីបានដំណើរការសកម្មភាព ការងារបរិវត្តកម្មឌីជីថលសម្រេចបាននូវគុណប្រយោជន៍គួរជាទីមោទកៈ។ ទន្ទឹមនេះ ការងារបរិវត្តកម្មឌីជីថលក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចជា មិនទាន់មានបន្ទប់សម្រាប់បំពេញការងារសមរម្យនៅឡើយ សម្ភារៈបរិក្ខារឌីជីថលមិនទាន់ឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ជាក់ស្ដែង ថវិកា សម្រាប់ចំណាយមិនទាន់ឆ្លើយតបទៅនឹងតម្រូវការការងារផ្នែកបរិវត្តកម្មឌីជីថល ហើយធនធានមនុស្សទាក់ទងនឹងជំនាញបច្ចេកវិទ្យាព័ត៌មានវិទ្យានៅមានកម្រិតជាដើម។

# ជំពូកទី៤

# យន្តការ និងវិធានការដោះស្រាយជាយុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវចក្ខុវិស័យដ៏មុតស្រួច និងវែងឆ្ងាយរបស់ក្រសួងអធិការកិច្ច ក្នុងការដឹកនាំ និងគ្រប់គ្រងវិស័យអធិការកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីដោះស្រាយបញ្ហាប្រឈមទាំងអស់ខាងលើ ក៏ដូចជាចូលរួមពង្រឹងការអនុវត្តស្មារតីនៃមុំទី៣ នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១នៃរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រសួងអធិការកិច្ចដាក់ចេញនូវយុទ្ធសាស្ត្រ«ព៤ជ៤» ដែលអាចធានាបាននូវកំណែទម្រង់អធិការកិច្ច និងអភិបាលកិច្ចមានលក្ខណៈគ្រប់ជ្រុងជ្រោយ ចំគោលដៅ និងផ្តោតលើលទ្ធផល។

យុទ្ធសាស្ត្រ«ព៤ជ៤» ជាយុទ្ធសាស្ត្ររបស់ក្រសួងអធិការកិច្ច ដែលមានចក្ខុវិស័យវែងឆ្ងាយ ក្នុងការជំរុញឱ្យសង្គមកម្ពុជាមានភាពធន់ និងភាពប្រកួតប្រជែង ព្រមទាំងធ្វើឱ្យស្ថាប័នសាធារណៈមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ន និងធានាបាននូវយុត្តិធម៌ តម្លាភាព និងអភិបាលកិច្ចល្អ តាមរយៈបេសកកម្មច្បាស់លាស់ និងមុតស្រួច ដើម្បីពង្រឹងនិងលើកកម្ពស់ទំនុកចិត្តលើស្ថាប័នសាធារណៈ ដោយផ្តោតសំខាន់លើ (១)បញ្ចៀសនូវសកម្មភាពមិនអនុលោមតាមច្បាប់ ដើម្បីកាត់បន្ថយការរំលោភបំពានលើអភិបាលកិច្ច ដោយបង្កើតវប្បធម៌នៃការអនុវត្តច្បាប់ និងអភិបាលកិច្ចល្អ (២)រកឱ្យឃើញចំណុចខ្វះខាត ព្រមទាំងភាពមិនប្រក្រតី និងអសកម្ម (៣)ទុកពេលឱ្យស្ថាប័នសាធារណៈដើម្បីកែលម្អនូវចំណុចខ្វះខាត ភាពមិនប្រក្រតី និងភាពអសកម្ម ក្នុងការអនុវត្តច្បាប់ និងអភិបាលល្អ ដើម្បីឈានដល់ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពេញលេញ និង(៤)ឆ្លើយតបជាមួយដំណោះស្រាយប្រកបដោយយុត្តិធម៌ តម្លាភាព ប្រសិទ្ធភាព និងទាន់ពេលវេលា។ លើសពីនេះទៅទៀត យុទ្ធសាស្ត្រនេះ

មានគុណតម្លៃស្នូលសំខាន់ៗរួមមាន (១)សុចរិតភាព៖ លើកកម្ពស់ភាពស្មោះត្រង់ យុត្តិធម៌ និងតម្លាភាពក្នុងអភិបាលកិច្ច (២)វិជ្ជាជីវៈ៖ ធានាបាននូវវិជ្ជាជីវៈ និងប្រសិទ្ធភាពក្នុងការធ្វើអធិការកិច្ច ការទទួលនិងដោះស្រាយបណ្ដឹង ការតាមដានការអនុវត្តច្បាប់ ការផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ (៣)ភាពច្បាស់លាស់៖ លើកកម្ពស់ការយល់ដឹងរបស់វិស័យឯកជន និងប្រជាពលរដ្ឋអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្ត (៤)គណនេយ្យភាព៖ ធ្វើឱ្យស្ថាប័ន និងបុគ្គលមានការទទួលខុសត្រូវខ្ពស់ចំពោះការអនុវត្តច្បាប់ និងការពង្រឹងអភិបាលកិច្ច (៥)ភាពជាដៃគូ៖ ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នរដ្ឋ ឯកជន និងដៃគូអន្តរជាតិនានា។

យុទ្ធសាស្ត្រ«ព៤ជ៤»បានកំណត់គោលដៅយុទ្ធសាស្ត្រ វិធានការគន្លឹះ និងការងារអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

## I. ពង្រឹងការងារអធិការកិច្ច

ការងារអធិការកិច្ច គឺជាការងារមួយដ៏លំបាកដែលទាមទារឱ្យមន្ត្រីដែលធ្វើការងារនេះត្រូវមានសមត្ថភាព មានអត្តចរិត សីលធម៌ល្អ មានបទពិសោធ និងរបៀបរបបការងារត្រឹមត្រូវ ច្បាស់លាស់ ដើម្បីវាយតម្លៃបញ្ហាដោយសត្យានុម័ត ពិតប្រាកដ និងការសន្និដ្ឋានដោយផ្អែកលើអង្គហេតុ និងអង្គច្បាប់។ ទន្ទឹមនឹងនេះ ការងារអធិការកិច្ចក៏តម្រូវឱ្យមានការពិចារណា ប្រុងប្រយ័ត្ន ឈ្លាសវៃ មានកម្មវិធី និងមានផែនការការងារច្បាស់លាស់ ព្រមទាំងមានការចូលរួមគាំទ្រ និងសហការពីគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ ដើម្បីឱ្យការងារអធិការកិច្ចប្រព្រឹត្តទៅ បានដោយរលូន មាននិរន្តរភាព ប្រសិទ្ធភាព ការជឿទុកចិត្ត និងមានការទទួលខុសត្រូវខ្ពស់ ត្រូវមានច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យអធិការកិច្ចឱ្យបានគ្រប់គ្រាន់ ច្បាស់លាស់ សម្រាប់អនុវត្តស្របតាមសភាពការណ៍ជាក់ស្ដែង ព្រមទាំងបន្តកសាងសមត្ថភាពមន្ត្រីរាជការឱ្យកាន់តែទូលំទូលាយបន្ថែមទៀត ដើម្បីបំពេញការងារប្រកបដោយទំនុកចិត្ត ភាពច្បាស់លាស់ក្នុងការវិភាគ វិនិច្ឆ័យដោយឈរលើគោលការណ៍ច្បាប់ ព្រមទាំងប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងមានមនសិការវិជ្ជាជីវៈ។

ក្រសួងអធិការកិច្ចដាក់ចេញនូវយុទ្ធសាស្ត្រ ពង្រឹងការងារអធិការកិច្ច ក្នុងគោលបំណងលើកកម្ពស់ និងពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ ដោយផ្ដោតអាទិភាពលើការពង្រឹងយន្តការគ្រប់គ្រង និងផ្ដល់សេវាសាធារណៈ ការផ្ដល់ការលើកទឹកចិត្តផ្អែកលើគុណាធិបតេយ្យ និងការចាត់វិធានការម៉ឺងម៉ាត់តាមច្បាប់ក្នុងការដាក់ទណ្ឌកម្មវិន័យ និងវិធានការច្បាប់ចំពោះមន្ត្រីសាធារណៈណាដែលប្រព្រឹត្តបំពានក្រមសីលធម៌វិជ្ជាជីវៈ បំពានអំណាចក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន។ ក្នុងយុទ្ធសាស្ត្រនេះ ក្រសួងដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន ៦ គឺ (១)ពង្រឹងប្រសិទ្ធិភាពនៃការចុះធ្វើអធិការកិច្ច (២)ពង្រឹងប្រសិទ្ធភាពនៃការចេញសេចក្ដីជូនដំណឹងកែលម្អ និងតាមដានការអនុវត្តសេចក្ដីជូនដំណឹង និងពង្រឹងការអនុវត្តសេចក្ដីសម្រេចស្ដីពីលទ្ធផលអធិការកិច្ច (៣)ពង្រឹងទំនាក់ទំនងនិងសហការជាមួយអង្គភាពអធិការកិច្ចតាមក្រសួងស្ថាប័ន (៤)កំណត់ឱ្យបានច្បាស់ពីសមត្ថកិច្ច មុខងារភារកិច្ច និងឋានានុក្រមអធិការកិច្ច (៥)ជំរុញបង្កើតយន្តការតាមដាន ត្រួតពិនិត្យលើរបាយការណ៍លទ្ធផលការងារអធិការកិច្ច និងយន្តការតាមដានត្រួតពិនិត្យលើមុខងារអធិការកិច្ចរបស់ក្រសួងស្ថាប័ន (៦)ជំរុញរៀបចំផែនការអធិការកិច្ចរួមប្រចាំឆ្នាំនីមួយៗ

## ក- គោលដៅយុទ្ធសាស្ត្រទី១៖ ពង្រឹងប្រសិទ្ធភាពនៃការចុះធ្វើអធិការកិច្ច

> ➢ វិធានការគន្លឹះទី១៖ ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីអធិការកិច្ច

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីអធិការកិច្ច ក្នុងគោលបំណងដើម្បីធានានូវការអនុវត្តតួនាទីរបស់មន្ត្រីអធិការកិច្ច ដោយត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍អធិការកិច្ច រួមមាន តម្លាភាព ភាពមិនលម្អៀង សុចរិតភាព ប្រសិទ្ធភាព និងរក្សាការសម្ងាត់។ ក្នុងវិធានការនេះក្រសួងត្រូវរៀបចំកិច្ចប្រជុំផ្ទៃក្នុងជាប្រចាំ និងការត្រួតពិនិត្យវាយតម្លៃពីសកម្មភាពរបស់មន្ត្រី

> ➢ វិធានការគន្លឹះទី២៖ ពង្រឹងនីតិវិធីនៃការធ្វើអធិការកិច្ច

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការរៀបចំនីតិវិធីនៃការធ្វើអធិការកិច្ច ក្នុងគោលបំណងដើម្បីពង្រឹងប្រសិទ្ធភាពនិងប្រសិទ្ធផលនៃការធ្វើអធិការកិច្ច ដែលត្រូវកំណត់ច្បាស់លាស់អំពីគោលការណ៍ និងរបៀបនៃការងារអធិការកិច្ច ដូចជាការកសាងផែនការ ការជូនដំណឹង ការចុះត្រួតពិនិត្យនៅនឹងកន្លែង ការរៀបចំរបាយការណ៍អធិការកិច្ច និងការតាមដានការអនុវត្តវិធានការអធិការកិច្ច។

> ➢ វិធានការគន្លឹះទី៣៖ ពង្រឹងការរៀបចំផែនការសកម្មភាពមុនប្រតិបត្តិការអធិការកិច្ច

ការងាររៀបចំផែនការអធិការកិច្ចគឺជាការងារចាំបាច់មុនដំណើរប្រតិបត្តិការអធិការកិច្ច។ ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការពង្រឹងការរៀបចំផែនការ**សកម្មភាពមុនប្រតិបត្តិការ**អធិការកិច្ច ដើម្បីព្រងឹងប្រសិទ្ធភាពនៃការចុះធ្វើអធិការកិច្ច ដោយកំណត់នូវការងារអាទិភាពមួយចំនួនដូចជា ការចុះក្តាប់សភាពការណ៍ដោយមានការចូលរួមពីមន្ទីរអធិការកិច្ច រាជធានី ខេត្ត ប្រមូល ចងក្រងឯកសារច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នឹង ការងារអធិការកិច្ច និងវាយតម្លៃ លើទិន្នន័យ និងឯកសារពាក់ព័ន្ធដែលប្រមូលបាន

## ខ- គោលដៅយុទ្ធសាស្ត្រទី២៖ ពង្រឹងទំនាក់ទំនងនិងសហការជាមួយអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន

> ➢ វិធានការគន្លឹះទី១៖ ពង្រឹងកិច្ចសហការជាមួយអង្គភាពរងអធិការកិច្ច

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ ពង្រឹងកិច្ចសហការជាមួយអង្គភាពរងអធិការកិច្ច ដើម្បីជំរុញធានាការចូលរួមឱ្យបានពេញលេញពី**អង្គភាពអធិការកិច្ចតាមបណ្តាក្រសួង ស្ថាប័ន ជាពិសេស**តាមរយៈកិច្ចប្រជុំប្រចាំត្រីមាស និងឆ្នាំជាមួយអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន កិច្ចសហការចុះធ្វើអធិការកិច្ចរួមគ្នា។

> ➢ វិធានការគន្លឹះទី២៖ ពង្រឹងសុខដុមនីយកម្មក្នុងវិស័យអធិការកិច្ច តាមរយៈការពង្រឹងកិច្ចសហការជាមួយអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ ពង្រឹងសុខដុមនីយកម្មក្នុងវិស័យអធិការកិច្ច ក្នុងគោលបំណងដើម្បីធ្វើឱ្យមានសង្គតិភាពការងារក្នុងវិស័យអធិការកិច្ចប្រកបដោយសុខដុមនីយកម្ម តាមរយៈការរៀបចំគោលនយោបាយ នីតិវិធី គំរូស្តង់ដារអធិការកិច្ច និងផ្តល់ការណែនាំជំនាញបច្ចេកទេស ដល់អង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន រៀបចំការបណ្តុះបណ្តាលនិងចែករំលែកបទពិសោធ និងចងក្រង ឯកសារសកម្មភាព និងលទ្ធផលការងារក្នុងវិស័យអធិការកិច្ច

## គ- គោលដៅយុទ្ធសាស្ត្រទី៣៖ ពង្រឹងប្រសិទ្ធភាពនៃការចេញសេចក្តីជូនដំណឹងគោលម្ហ និងតាមដានការអនុវត្តសេចក្តីជូនដំណឹង និងពង្រឹងការអនុវត្តសេចក្តីសម្រេចស្តីពីលទ្ធផលអធិការកិច្ច

- **វិធានការគន្លឹះទី១៖ តាមដាន ត្រួតពិនិត្យ និងក្រើនរំលឹកការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីលទ្ធផលអធិការកិច្ច**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ តាមដាន ត្រួតពិនិត្យ និងក្រើនរំលឹកការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីលទ្ធផលអធិការកិច្ច ក្នុងគោលបំណងដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តសេចក្តីសម្រេចស្តីពីលទ្ធផលអធិការកិច្ចដែលរាជរដ្ឋាភិបាលបានដាក់ចេញសម្រេចដល់ស្ថាប័នរងអធិការកិច្ច តាមរយៈការរៀបចំកិច្ចប្រជុំពិនិត្យវាយតម្លៃលើការអនុវត្ត ដើម្បីក្រើនរំលឹកដល់ក្រសួង ស្ថាប័ន អង្គភាពអនុវត្តសេចក្តីសម្រេចស្តីពីលទ្ធផលអធិការកិច្ច

- **វិធានការគន្លឹះទី២៖ តាមដាន ត្រួតពិនិត្យ និងក្រើនរំលឹកការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចដាក់ចេញដល់ក្រសួង ស្ថាប័ន អង្គភាពរងអធិការកិច្ច**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការតាមដាន ត្រួតពិនិត្យ និងក្រើនរំលឹកការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចដាក់ចេញដល់ក្រសួង ស្ថាប័ន អង្គភាពរងអធិការកិច្ច ក្នុងគោលបំណងដើម្បីពង្រឹងប្រសិទ្ធភាពនៃវិធានការដែលក្រសួងអធិការកិច្ចដាក់ចេញ តាមរយៈការរៀបចំកិច្ចប្រជុំពិនិត្យវាយតម្លៃលើការអនុវត្តសេចក្តីសម្រេច និងក្រើនរំលឹកដល់ក្រសួង ស្ថាប័ន អង្គភាពរងអធិការកិច្ចអនុវត្តសេចក្តីសម្រេច។

## ឃ- គោលដៅយុទ្ធសាស្ត្រទី ៤៖ កំណត់ឱ្យបានច្បាស់ពីសមត្ថកិច្ច មុខងារភារកិច្ច និងឋានានុក្រមអធិការកិច្ច

- **វិធានការគន្លឹះទី១៖** កំណត់ឱ្យបានច្បាស់ពីសមត្ថកិច្ច មុខងារ និងភារកិច្ចអធិការកិច្ច

ក្រសួងអធិការកិច្ចជំរុញឱ្យមានយន្តការដែលអាចកំណត់សមត្ថកិច្ច និងមុខងារអធិការកិច្ច ដើម្បីជៀសវាងការស្ទួនភារកិច្ចគ្នា ជាពិសេស ត្រូវចែងឱ្យបានច្បាស់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត។

- **វិធានការគន្លឹះទី២៖** កំណត់ឋានានុក្រមអធិការកិច្ចឱ្យបានច្បាស់លាស់

ក្រសួង ស្ថាប័នដែលមានមុខងារធ្វើអធិការកិច្ចត្រូវយល់ឱ្យបានច្បាស់ពីឋានានុក្រមក្នុងការធ្វើអធិការកិច្ច ដោយក្រសួងអធិការកិច្ចជាក្រសួងអធិការកិច្ចរាជរដ្ឋាភិបាល ធ្វើអធិការកិច្ចលើគ្រប់វិស័យ និងក្រសួង ស្ថាប័នជាអធិការកិច្ចតាមវិស័យជំនាញរៀងៗខ្លួន។ ក្នុងន័យនេះ ក្រសួងអធិការកិច្ចជំរុញឱ្យមានយន្តការក្នុងការកំណត់ឋានានុក្រមអធិការកិច្ចត្រូវមានភាពច្បាស់លាស់ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តការងារក្នុងវិស័យអធិការកិច្ច ជាពិសេស ត្រូវចែងឱ្យបានច្បាស់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត។

## ង- គោលដៅយុទ្ធសាស្ត្រទី ៥៖ ជំរុញបង្កើតយន្តការតាមដាន ត្រួតពិនិត្យលើរបាយការណ៍លទ្ធផលការងារអធិការកិច្ច និងយន្តការតាមដានត្រួតពិនិត្យលើមុខងារអធិការកិច្ចរបស់ក្រសួង ស្ថាប័ន

- **វិធានការគន្លឹះទី១៖** បង្កើតយន្តការតាមដាន ត្រួតពិនិត្យលើរបាយការណ៍លទ្ធផលការងារអធិការកិច្ច

ក្រសួងអធិការកិច្ចដាក់ចេញយន្តការតាមដានត្រួតពិនិត្យលើ របាយការណ៍លទ្ធផលការងារអធិការកិច្ច ដោយមានសូចនាករ និងប្រព័ន្ធវិនិច្ឆ័យច្បាស់លាស់ដែលអាចវាស់វែងបាន សំដៅធានាបាននូវគណនេយ្យភាព សុចរិតភាព និងអភិបាលកិច្ចល្អ។

- **វិធានការគន្លឹះទី២៖** យន្តការតាមដានត្រួតពិនិត្យលើមុខងារអធិការកិច្ចរបស់ក្រសួង ស្ថាប័ន

ក្នុងនាមស្ថាប័នដឹកនាំ និងគ្រប់គ្រងវិស័យអធិការកិច្ច ក្រសួងអធិការកិច្ចដាក់ចេញយន្តការតាមដានត្រួតពិនិត្យលើការអនុវត្តមុខងារអធិការកិច្ចរបស់ក្រសួង ស្ថាប័ន តាមរយៈយន្តការច្បាស់លាស់។

### ខ- គោលដៅយុទ្ធសាស្ត្រទី ៦៖ ជំរុញរៀបចំផែនការអធិការកិច្ចរួមប្រចាំឆ្នាំនីមួយៗ

- **វិធានការគន្លឹះទី១៖** ជំរុញកិច្ចសហការពីអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័នលើការរៀបចំផែនការអធិការកិច្ចរួម

ក្រសួងអធិការកិច្ចដាក់ចេញនូវយន្តការក្នុងការរៀបចំផែនការអធិការកិច្ចរួមប្រចាំឆ្នាំ ដោយមានការសហការពីអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន ដើម្បីគោរពជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ក្នុងគោលដៅជៀសវាងការធ្វើអធិការកិច្ចស្ទួនគ្នា ក្នុងការិយបរិច្ឆេទតែមួយ ព្រមទាំងធានាបាននូវប្រសិទ្ធភាពក្នុងការធ្វើអធិការកិច្ច។ ក្នុងន័យនេះ ទាមទារឱ្យមានការសហការឱ្យបានពេញលេញពីអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន ក្នុងការរៀបចំផែនការអធិការកិច្ចរួមដែលមានលក្ខណៈប្រទាក់ក្រឡា និងគ្រប់ជ្រុងជ្រោយ។

- **វិធានការគន្លឹះទី២៖** បង្កើតយន្តការដើម្បីរៀបចំផែនការអធិការកិច្ចប្រចាំឆ្នាំរួម

ក្រសួងអធិការកិច្ចដាក់ចេញវិធានការក្នុងការបង្កើតយន្តការ សម្រាប់រៀបចំផែនការអធិការកិច្ចរួមប្រកបដោយភាពប្រទាក់ក្រឡា ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។

## II. ពង្រឹងការងារដោះស្រាយបណ្ដឹង

ឆ្លើយតបចំពោះបញ្ហាប្រឈមខាងលើ ក្រសួងដាក់ចេញនូវយុទ្ធសាស្ត្រ ពង្រឹងការងារដោះស្រាយបណ្ដឹងក្នុងគោលបំណងលើកកម្ពស់អភិបាលកិច្ចល្អ តម្លាភាព គណនេយ្យភាព សុចរិតភាព ភាពស្អាតស្អំ ក្នុងស្ថាប័នសាធារណៈ និងយុត្តិធម៌សង្គម តាមរយៈការដោះស្រាយបណ្ដឹងតវ៉ានិងបណ្ដឹងបរិហារអំពីនីតិបុគ្គលនិងរូបវន្តបុគ្គលសាធារណៈក្នុងក្របខ័ណ្ឌដែនសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលពីគ្រប់មជ្ឈដ្ឋានទាំងអស់ រួមទាំងពិនិត្យបាតុភាពអសកម្មផ្សេងៗពីមជ្ឈដ្ឋាននានា ដើម្បីចូលរួមក្នុងការកសាងនីតិរដ្ឋ ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងការពារផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ប្រជាពលរដ្ឋ។ ក្នុងយុទ្ធសាស្ត្រនេះ ក្រសួងអធិការកិច្ចដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន២ និងវិធានការគន្លឹះចំនួន៦ ដូចខាងក្រោម៖

### ក- គោលដៅយុទ្ធសាស្ត្រទី១៖ ពង្រឹងប្រសិទ្ធភាពនៃការទទួលបណ្ដឹង

- **វិធានការគន្លឹះទី១៖ ពង្រឹងយន្តការទទួលពាក្យបណ្ដឹង**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការពង្រឹងយន្តការទទួលពាក្យបណ្ដឹងតវ៉ា និងបណ្ដឹងបរិហារពីគ្រប់មជ្ឈដ្ឋានតាមរយៈ ការទទួលដោយផ្ទាល់ បច្ចេកវិទ្យាព័ត៌មាន សារព័ត៌មាន បណ្ដឹងអនាមិក និងគ្រប់មធ្យោបាយទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ក្នុងវិធានការនេះ ក្រសួងអធិការកិច្ចនឹងពង្រឹងយន្តការទទួលពាក្យបណ្ដឹង ជាពិសេសតាមរយៈប្រព័ន្ធបច្ចេកវិទ្យា(អនឡាញ) និងការទទួលដោយផ្ទាល់

- **វិធានការគន្លឹះទី២៖ ផ្សព្វផ្សាយអំពីយន្តការនៃការទទួលនិងដោះស្រាយបណ្ដឹងរបស់ក្រសួងអធិការកិច្ច**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការនេះ ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយយន្តការនិងសមត្ថកិច្ចនៃការទទួលពាក្យបណ្ដឹងរបស់ក្រសួងអធិការកិច្ចឱ្យកាន់តែទូលំទូលាយ ជូនដល់សាធារណជនទូទាំងព្រះរាជាណាចក្រកម្ពុជា

- **វិធានការគន្លឹះទី៣៖ ពង្រឹងការពិនិត្យសមត្ថកិច្ចបណ្ដឹង**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការនេះ ក្នុងគោលបំណងពង្រឹងសមត្ថភាពមន្ត្រីក្នុងការពិនិត្យកម្មវត្ថុបណ្ដឹង ដើម្បីកំណត់សមត្ថកិច្ច ចំពោះបណ្ដឹងដែលត្រូវដោះស្រាយនៅក្រសួងអធិការកិច្ច ឬបណ្ដឹងដែលត្រូវបញ្ជូនទៅក្រសួង ស្ថាប័នពាក់ព័ន្ធ

- **វិធានការគន្លឹះទី៤៖ រៀបចំនិងថែទាំកន្លែងទទួលបណ្ដឹង**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការនេះ ក្នុងគោលបំណងរៀបចំកន្លែងឱ្យបានសមរម្យសម្រាប់ទទួលសាធារណជនដែលមកដាក់ពាក្យបណ្ដឹង ដើម្បីធានានូវប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ ក្នុងការងារបណ្ដឹង។

## ខ- គោលដៅយុទ្ធសាស្ត្រទី២៖ ពង្រឹងប្រសិទ្ធភាពនៃការដោះស្រាយបណ្ដឹង

- **វិធានការគន្លឹះទី១៖ ពង្រឹងនីតិវិធីនៃការដោះស្រាយបណ្ដឹង**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការរៀបចំនីតិវិធីក្នុងការដោះស្រាយបណ្ដឹង ក្នុងគោលបំណងដើម្បី (១)កំណត់អំពីគោលការណ៍ច្បាស់លាស់ពីរបៀបនៃការដោះស្រាយបណ្ដឹងឱ្យបានឆាប់រហ័ស (២)ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីដោះស្រាយបណ្ដឹង ក្នុងការអនុវត្តតួនាទីឱ្យបានទូលំទូលាយ ស្មើភាព មិនរើសអើង ប្រកបដោយភាពទន់ភ្លន់តែម៉ឺងម៉ាត់និងផ្អែកលើច្បាប់ ស្របតាមគោលការណ៍ តម្លាភាព មិនលម្អៀង សុចរិតភាព ប្រសិទ្ធភាព និងការសម្ងាត់ និង(៣)ពង្រឹងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ ទាំងដើមបណ្ដឹង ចុងចម្លើយ សាក្សី អាជ្ញាធរមានសមត្ថកិច្ច និងប្រជាពលរដ្ឋ ដើម្បីបង្កើនជំនឿទុកចិត្តពីគ្រប់ភាគី សំដៅពង្រឹងប្រសិទ្ធភាពនៃការដោះស្រាយបណ្ដឹង និង(៤)ប្រជុំតាមដានត្រួតពិនិត្យនិងវាយតម្លៃផ្ទៃក្នុង។

- **វិធានការគន្លឹះទី២៖ ពង្រឹងយន្តការតាមដានការអនុវត្តសេចក្ដីសម្រេច លើលទ្ធផលនៃការដោះស្រាយបណ្ដឹង**

ការតឿនទារលើលទ្ធផលដោះស្រាយបណ្ដឹងដែលបានបញ្ជូនទៅសមត្ថកិច្ចផ្សេង និងតាមដានការអនុវត្តសេចក្ដីសម្រេចស្ដីពីលទ្ធផលនៃការដោះស្រាយបណ្ដឹង ជាការងារចាំបាច់ដែលមិនអាចខ្វះបាន។ ក្នុងន័យនេះ ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការគន្លឹះ ក្នុងការពង្រឹងយន្តការតាមដានការអនុវត្តសេចក្ដីសម្រេចលើលទ្ធផល នៃការដោះស្រាយបណ្ដឹង ដើម្បីធានាប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ និងការពារផលប្រយោជន៍ជូនភាគីពាក់ព័ន្ធ។

# III. ពង្រឹងការងារតាមដានការអនុវត្តច្បាប់

ឆ្លើយតបចំពោះបញ្ហាប្រឈមខាងលើ ក្រសួងដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រពង្រឹងការងារតាមដានការអនុវត្តច្បាប់ ក្នុងគោលបំណងពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទបញ្ជា អនុសាសន៍ និងសេចក្ដីសម្រេចផ្សេងៗរបស់ប្រមុខរាជរដ្ឋាភិបាល ដើម្បីចូលរួមពង្រឹងអភិបាលកិច្ច។ ឆ្លើយតបនឹងយុទ្ធសាស្ត្រនេះ ក្រសួងបានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ ចំនួន ៣ គឺ (១)ពង្រឹងការងារតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (២)

ពង្រឹងប្រសិទ្ធភាពនៃការចេញសេចក្តីជូនដំណឹងកែលម្អ និងតាមដានការអនុវត្តសេចក្តីជូនដំណឹង ពង្រឹងការអនុវត្តសេចក្តីសម្រេចស្តីពីលទ្ធផលនៃការងារតាមដានការអនុវត្តច្បាប់ (៣)ជំរុញបង្កើតយន្តការតាមដាន ត្រួតពិនិត្យលើរបាយការណ៍លទ្ធផលការងារតាមដានការអនុវត្តច្បាប់។

### ក- គោលដៅយុទ្ធសាស្ត្រទី១៖ ពង្រឹងការងារតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- **វិធានការគន្លឹះទី១៖ រៀបចំនីតិវិធីប្រតិបត្តិការការងារតាមដានការអនុវត្តច្បាប់**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ រៀបចំនីតិវិធីប្រតិបត្តិការការងារតាមដានការអនុវត្តច្បាប់ ក្នុងគោលបំណងដើម្បីកំណត់ពីរបៀបរបបនៃការចុះតាមដានការអនុវត្តច្បាប់ ដោយមានកិច្ចពិគ្រោះយោបល់កម្រិតជំនាញដែលមានការចូលរួមពីអង្គភាពពាក់ព័ន្ធ។

- **វិធានការគន្លឹះទី២៖ ពង្រឹងការរៀបចំផែនការចុះតាមដានការអនុវត្តច្បាប់**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ ពង្រឹងការរៀបចំផែនការចុះតាមដានការអនុវត្តច្បាប់ ក្នុងគោលបំណងដើម្បីកំណត់គោលដៅ កម្មវត្ថុ ពេលវេលា តាមរយៈការធ្វើបញ្ជីសម្រង់រាល់ច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទបញ្ជា អនុសាសន៍ សេចក្តីសម្រេចផ្សេងៗរបស់ប្រមុខរាជរដ្ឋាភិបាល ចុះក្តាប់សភាពការណ៍ដោយការប្រមូលព័ត៌មានពីគ្រប់មជ្ឈដ្ឋាននិងគ្រប់មធ្យោបាយ លើចំណុចអសកម្មនានាពាក់ព័ន្ធនឹងការអនុវត្តច្បាប់ដែលមានការចូលរួមពីមន្ទីរអធិការកិច្ចរាជធានី ខេត្ត និងវាយតម្លៃលើទិន្នន័យដែលប្រមូលបានពីការចុះក្តាប់សភាពការណ៍។

- **វិធានការគន្លឹះទី៣៖ ជំរុញប្រសិទ្ធភាពការងារតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ ជំរុញប្រសិទ្ធភាពការងារតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងគោលបំណងដើម្បីធានានូវប្រសិទ្ធភាពនៃការងារតាមដានការអនុវត្តច្បាប់ដោយទទួលបាន នូវកិច្ចសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ រួមទាំងស្ថាប័នរងការតាមដានការអនុវត្តច្បាប់។

- **វិធានការគន្លឹះទី៤៖ ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីតាមដានការអនុវត្តច្បាប់**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីតាមដានការអនុវត្តច្បាប់ ក្នុងគោលបំណងដើម្បីធានានូវការអនុវត្តតួនាទីរបស់មន្ត្រីចុះតាមដានការអនុវត្តច្បាប់ ដោយផ្អែកលើគោលការណ៍តម្លាភាព ការទទួលខុសត្រូវ ភាពមិនលម្អៀង សុចរិតភាព ប្រសិទ្ធភាព និងរក្សាការសម្ងាត់ ប្រកបដោយភាពទន់ភ្លន់តែម៉ឺងម៉ាត់និងអនុលោមភាពនៃច្បាប់។

### ខ- គោលដៅយុទ្ធសាស្ត្រទី២៖ ពង្រឹងប្រសិទ្ធភាពនៃការចេញសេចក្តីជូនដំណឹងកែលម្អ និងតាមដានការអនុវត្តសេចក្តីជូនដំណឹង និងពង្រឹងការអនុវត្តសេចក្តីសម្រេចស្តីពីលទ្ធផលនៃការងារតាមដានការអនុវត្តច្បាប់

- **វិធានការគន្លឹះទី១៖ តាមដាន ត្រួតពិនិត្យ និងក្រើនរំលឹកការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីលទ្ធផលនៃការងារតាមដានការអនុវត្តច្បាប់**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ តាមដាន ត្រួតពិនិត្យ និងក្រើនរំលឹកការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីលទ្ធផលនៃការងារតាមដានការអនុវត្តច្បាប់ ក្នុងគោលបំណងដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តសេចក្តីសម្រេចដែលរាជរដ្ឋាភិបាលបានដាក់ចេញដល់ក្រសួង ស្ថាប័ន អង្គភាពរងការតាមដានត្រួតពិនិត្យ។

- **វិធានការគន្លឹះទី២៖ តាមដាន ត្រួតពិនិត្យ និងក្រើនរំលឹកការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចដាក់ចេញដល់ក្រសួង ស្ថាប័ន និងអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការនេះដើម្បីតាមដាន ត្រួតពិនិត្យ ក្រើនរំលឹក និងធានាប្រសិទ្ធភាពនៃការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចដាក់ចេញ ដល់ក្រសួង ស្ថាប័ន និងអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈលទ្ធផលនៃការចុះតាមដានការអនុវត្តច្បាប់។

- **វិធានការគន្លឹះទី៣៖ ពង្រឹងប្រសិទ្ធភាពនៃការចេញសេចក្តីជូនដំណឹងកែលម្អ**

ត្រូវពង្រឹងយន្តការក្នុងការចេញសេចក្តីជូនដំណឹងកែលម្អ និងយន្តការតាមដានការអនុវត្តសេចក្តីជូនដំណឹងឱ្យមានប្រសិទ្ធភាព សំដៅជំរុញការកែលម្អការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។

### គ- គោលដៅយុទ្ធសាស្ត្រទី៣៖ ជំរុញបង្កើតយន្តការតាមដាន ត្រួតពិនិត្យលើរបាយការណ៍លទ្ធផលការងារតាមដានការអនុវត្តច្បាប់

ក្រសួងអធិការកិច្ចដាក់ចេញយន្តការតាមដានត្រួតពិនិត្យលើ របាយការណ៍លទ្ធផលការងារតាមដានការអនុវត្តច្បាប់ សំដៅធានាបាននូវគណនេយ្យភាព សុចរិតភាព និងអភិបាលកិច្ចល្អ។

## IV. ពង្រឹងការងារផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ

ក្រសួងអធិការកិច្ចដាក់ចេញនូវយុទ្ធសាស្ត្រ ពង្រឹងការងារផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ ក្នុងគោលបំណង ដើម្បីធានាប្រសិទ្ធភាពនិងប្រសិទ្ធផលនៃការអប់រំផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជូនដល់សាធារណជន តាមរយៈការធ្វើយុទ្ធនាការនានា និងការធ្វើវេទិកាសាធារណៈដើម្បីទទួលយកសំណូមពរ និងស្វែងយល់ ពីកង្វល់របស់ប្រជាពលរដ្ឋ។

ក្នុងយុទ្ធសាស្ត្រពង្រឹងការងារផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ ក្រសួងដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន ៥៖ (១)ពង្រឹងប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយច្បាប់ (២)ពង្រឹងប្រសិទ្ធភាពនៃការរៀបចំវេទិកាសាធារណៈ និង(៣)ពង្រឹងប្រសិទ្ធភាពនៃការវិភាគតាមដានត្រួតពិនិត្យ វាយតម្លៃ និងស្ទង់មតិក្នុងដំណើរការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ (៤)ពង្រឹងការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយលើមូលដ្ឋានក្នុងការកំណត់លិខិតបទដ្ឋានគតិយុត្ត ប្រធានបទ និងគោលដៅអាទិភាពក្នុងការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ (៥)ជំរុញការផ្សព្វផ្សាយ និងពន្យល់អំពីសារៈសំខាន់នៃចំណេះដឹងអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តឱ្យបានទូលំទូលាយ។

### ក- គោលដៅយុទ្ធសាស្ត្រទី១៖ ពង្រឹងប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយច្បាប់

- **វិធានការគន្លឹះទី១៖ ទំនាក់ទំនង និងកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ**

ការងារអប់រំផ្សព្វផ្សាយច្បាប់ តម្រូវឱ្យមានការសហការជាមួយបណ្តាក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ក្នុងន័យនេះ ក្រសួងដាក់ចេញនូវវិធានការនេះ

ក្នុងគោលបំណង ពង្រឹង និងពង្រីកទំនាក់ទំនង កិច្ចសហការជាមួយភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ

➢ វិធានការគន្លឹះទី២៖ ជំរុញការអប់រំផ្សព្វផ្សាយច្បាប់

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ ជំរុញការអប់រំផ្សព្វផ្សាយច្បាប់ ក្នុងគោលបំណងដើម្បីលើកកម្ពស់កម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ លើច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្នុងគោលដៅធានាប្រសិទ្ធភាពនៃការចូលរួមគោរពនិងអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ។ ក្នុងវិធានការនេះ ក្រសួងអធិការកិច្ចដាក់ចេញនូវការងារអាទិភាពមួយចំនួនដូចជា សិក្សា ស្រាវជ្រាវ ចងក្រង ឯកសារច្បាប់និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អប់រំផ្សព្វផ្សាយ រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយ ផលិតនិងថតស្ប៉ត វីដេអូសំណួរចម្លើយច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តដែលត្រូវផ្សព្វផ្សាយ និងការរៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយ។

## ខ- គោលដៅយុទ្ធសាស្ត្រទី២៖ ពង្រឹងប្រសិទ្ធភាពនៃការរៀបចំវេទិកាសាធារណៈ

➢ វិធានការគន្លឹះទី១៖ ទំនាក់ទំនង និងកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ

ការងារវេទិកាសាធារណៈ តម្រូវឱ្យមានការសហការជាមួយបណ្តាក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ក្នុងន័យនេះ ក្រសួងដាក់ចេញនូវវិធានការនេះ ក្នុងគោលបំណង ពង្រឹង និងពង្រីកទំនាក់ទំនង កិច្ចសហការជាមួយភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ

➢ វិធានការគន្លឹះទី២៖ ជំរុញការរៀបចំវេទិកាសាធារណៈ

ក្រសួងអធិការកិច្ចរៀបចំវេទិកាសាធារណៈ ដើម្បីសិក្សាស្វែងយល់ពីកង្វល់ និងទទួលសំណូមពរពីប្រជាពលរដ្ឋនៅតាមបណ្តាមូលដ្ឋានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ វេទិកានេះផ្សារភ្ជាប់ទៅនឹងការដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហារ ចំពោះនីតិបុគ្គលនិងរូបវន្តបុគ្គលសាធារណៈ ក្នុងក្របខ័ណ្ឌដែនសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលពីគ្រប់មជ្ឈដ្ឋានទាំងអស់។ ក្នុងវិធានការនេះ ក្រសួងអធិការកិច្ចនឹងជំរុញការរៀបចំវេទិកាសាធារណៈឱ្យបានទូលំទូលាយ និងទទួលបានលទ្ធផលជាវិជ្ជមាន **ព្រមទាំងបន្តតាមដានដំណោះស្រាយជាក់ស្តែង**ពីអាជ្ញាធរមានសមត្ថកិច្ចដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់ស្តែង ក្នុងជីវភាពរបស់ប្រជាពលរដ្ឋ ស្របតាម គោលនយោបាយរបស់រាជរដ្ឋាភិបាល។

## គ- គោលដៅយុទ្ធសាស្ត្រទី៣៖ ពង្រឹងប្រសិទ្ធភាពនៃការវិភាគតាមដានត្រួតពិនិត្យ វាយតម្លៃ និងស្ទង់មតិក្នុងដំណើរការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ

➢ វិធានការគន្លឹះទី១៖ ការស្ទង់មតិពីកម្រិតយល់ដឹងរបស់ប្រជាពលរដ្ឋអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ ការស្ទង់មតិពីកម្រិតយល់ដឹងរបស់ប្រជាពលរដ្ឋអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត មុននិងក្រោយពេលអប់រំផ្សព្វផ្សាយ តាមរយៈសកម្មភាពជាអាទិភាពមួយចំនួនដូចជា ការរៀបចំវិធីសាស្ត្រស្ទង់មតិ រៀបចំបញ្ជីសំណួរដើម្បីវាយតម្លៃ ចុះប្រមូលទិន្នន័យ(សម្ភាសន៍) និងវិភាគទិន្នន័យ

➢ វិធានការគន្លឹះទី២៖ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពក្រោយបញ្ចប់កម្មវិធីផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ

ក្រោយបញ្ចប់កម្មវិធីអប់រំផ្សព្វផ្សាយច្បាប់និងការរៀបចំវេទិកាសាធារណៈ ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ក្នុងគោលបំណងដើម្បីវាស់វែងពីកម្រិតនៃការពេញចិត្តរបស់ប្រជាពលរដ្ឋដែលចូលរួមក្នុងការអប់រំផ្សព្វផ្សាយច្បាប់និងការរៀបចំវេទិកាសាធារណៈ ក្នុងគោលដៅទទួលបាននូវលទ្ធផលជាវិជ្ជមាន ឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់ស្តែងក្នុងជីវភាពរបស់ប្រជាពលរដ្ឋនិងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ឃ- គោលដៅយុទ្ធសាស្ត្រទី៤៖ ពង្រឹងការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយលើមូលដ្ឋានក្នុងការកំណត់លិខិតបទដ្ឋានគតិយុត្ត ប្រធានបទ និងគោលដៅអាទិភាពក្នុងការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ

ក្រសួងអធិការកិច្ចត្រូវពង្រឹងមូលដ្ឋាន និងនីតិវិធីក្នុងការជ្រើសរើសប្រធានបទ និងគោលដៅអាទិភាពក្នុងការអប់រំផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ ដោយត្រូវផ្តោតលើលិខិតបទដ្ឋានគតិយុត្ត ប្រធានបទ និងគោលដៅអាទិភាព ដែលឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។

### ង- គោលដៅយុទ្ធសាស្ត្រទី៥៖ ជំរុញការផ្សព្វផ្សាយ និងពន្យល់អំពីសារៈសំខាន់នៃចំណេះដឹងអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តឱ្យបានទូលំទូលាយ

ក្រសួងអធិការកិច្ចត្រូវជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធឱ្យបានទូលំទូលាយក្នុងការអប់រំផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ តាមរយៈការផ្សព្វផ្សាយតាមគ្រប់មធ្យោបាយអំពីសារៈសំខាន់នៃចំណេះដឹងអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ជាពិសេស នៅតាមគោលដៅអាទិភាពដែលបានកំណត់។

## V. ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត

អនុវត្តតាមអនុសាសន៍តម្រង់ទិសដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើការងារដឹកនាំនិងគ្រប់គ្រងវិស័យអធិការកិច្ចថា *«ក្រសួងអធិការកិច្ច ត្រូវផ្តួចផ្តើម និងនាំមុខក្នុងការរៀបចំយន្តការត្រួតពិនិត្យប្រកបដោយគុណភាព ប្រសិទ្ធភាព ព្រមទាំងសុខដុមនីយកម្មនៃមុខងារអធិការកិច្ចនៅក្នុងរដ្ឋបាលសាធារណៈ»* ក្រសួងអធិការកិច្ចដាក់ចេញនូវយុទ្ធសាស្ត្រ ជំរុញការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត ក្នុងគោលបំណង ដើម្បីពង្រឹងយន្តការសិក្សា ស្រាវជ្រាវ និងរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត នីតិវិធី វិធាននិងបទដ្ឋានផ្សេងទៀត សម្រាប់គាំទ្រដល់បេសកកម្មរបស់ក្រសួងអធិការកិច្ច ឱ្យបានគ្រប់គ្រាន់ច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ព្រមទាំងពង្រឹងប្រព័ន្ធការងារគ្រប់ផ្នែក គ្រប់ថ្នាក់ ឈរលើមូលដ្ឋានបុរេសកម្ម សកម្ម និងអន្តរ-សកម្ម។ ក្នុងយុទ្ធសាស្ត្រនេះ ក្រសួងអធិការកិច្ចដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន២គឺ (១) ពង្រឹងប្រសិទ្ធភាពនៃយន្តការរៀបចំលិខិតបទដ្ឋានគតិយុត្ត និង(២)ជំរុញការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងពង្រឹងប្រសិទ្ធភាពនិងសុខដុមនីយកម្មនៃលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអធិការកិច្ច។

### ក- គោលដៅយុទ្ធសាស្ត្រទី១៖ ពង្រឹងប្រសិទ្ធភាពនៃយន្តការរៀបចំលិខិតបទដ្ឋានគតិយុត្ត

ដើម្បីឱ្យយន្តការនៃការរៀបចំលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងប្រព្រឹត្តទៅដោយប្រសិទ្ធភាព ត្រូវមានរចនាសម្ព័ន្ធរឹងមាំនិងប្រទាក់ក្រឡា មានធនធានមនុស្ស និងធនធានថវិកា សម្ភារៈសម្រាប់លើកទឹកចិត្តនិងគាំទ្រ។ ក្នុងគោលដៅយុទ្ធសាស្ត្រនេះ ក្រសួងដាក់ចេញនូវវិធានការគន្លឹះមួយចំនួនរួមមាន៖

- **វិធានការគន្លឹះទី១៖ ការរៀបចំរចនាសម្ព័ន្ធ និងធនធានមនុស្ស**

ក្នុងវិធានការនេះ ក្រសួងដាក់ចេញនូវការងារអាទិភាពដូចជាការបង្កើតយន្តការច្បាស់លាស់មួយដែលដឹកនាំនិងសម្របសម្រួលដោយថ្នាក់ដឹកនាំ រួមជាមួយមន្ត្រីដែលមានជំនាញ និងមានបទពិសោធលើផ្នែកច្បាប់ ជំនាញគោលនយោបាយ ជំនាញឯកទេសអធិការកិច្ច ជំនាញរដ្ឋបាល ជំនាញពាក់ព័ន្ធ និងជំនួយការស្រាវជ្រាវសម្រាប់វិភាគគោលនយោបាយ ផ្តល់ជំនាញបច្ចេកទេសនិងបទពិសោធពាក់ព័ន្ធនឹងវិស័យអធិការកិច្ច ពិគ្រោះយោបល់ និងផ្តល់យោបល់លើគ្រប់ទិដ្ឋភាព ផ្តល់ធាតុចូលដែលជាការវិវត្តថ្មីៗនិងចងក្រងទិន្នន័យនៃការស្រាវជ្រាវសម្រាប់ជាឯកសារគាំទ្រ ដើម្បីដាក់ចេញនូវផែនការសកម្មភាព និងផែនការយុទ្ធសាស្ត្រ ពង្រាងគ្រោងឆ្អឹង និងខ្លឹមសារសំខាន់ៗនៃលិខិតបទដ្ឋានគតិយុត្ត។

- **វិធានការគន្លឹះទី២៖ អភិវឌ្ឍផ្នែកសិក្សាស្រាវជ្រាវ**

លិខិតបទដ្ឋានគតិយុត្តត្រូវតាក់តែងឡើងដោយការប្រុងប្រយ័ត្ន ជៀសវាងផលប៉ះពាល់ដែលមិនអាចស្មានទុក ឬផលអវិជ្ជមានផ្សេងៗ ដូចជាការបន្ធូរបន្ថយ ឬការរឹតបន្តឹង ក្នុងដាក់បន្ទុកធ្ងន់ធ្ងរដែលមិនចាំបាច់លើបុគ្គលដែលរងផលប៉ះពាល់ដោយសារបទប្បញ្ញត្តិទាំងនោះ តម្រូវឱ្យមានការវាយតម្លៃពីផលប៉ះពាល់ដាក់បញ្ចូលបញ្ញត្តិកម្មថ្មី ដោយផ្អែកលើកត្តាជាច្រើនដូចជា នយោបាយ ភូមិសាស្ត្រ សង្គម សេដ្ឋកិច្ច វប្បធម៌ ប្រពៃណីទំនៀមទម្លាប់ ជាដើម។ ក្នុងន័យនេះ ក្រសួងដាក់ចេញនូវវិធានការ អភិវឌ្ឍផ្នែកសិក្សាស្រាវជ្រាវ ក្នុងបំណងដើម្បីពង្រឹងប្រសិទ្ធភាពនៃការតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងចងក្រងឯកសារដែលពាក់ព័ន្ធនឹងវិស័យអធិការកិច្ច ដោយផ្តោតលើការងារអាទិភាពដូចជា បង្កើតយន្តការសិក្សាស្រាវជ្រាវជាក់លាក់ ផ្តល់ការបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា សិក្ខាសាលាទាំងក្នុងនិងក្រៅប្រទេស ជាមួយអ្នកជំនាញជាតិ អន្តរជាតិ ដើម្បីស្រាវជ្រាវឯកសារច្បាប់គ្រប់សម័យកាលជាតិនិងអន្តរជាតិដែលពាក់ព័ន្ធនឹងវិស័យអធិការកិច្ច ចែករំលែកការអនុវត្តល្អៗជាប្រចាំ និងការកៀរគរដៃគូនានាទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស

- **វិធានការគន្លឹះទី៣៖ ជំរុញកិច្ចសហការជាមួយភាគីពាក់ព័ន្ធ**

កិច្ចសហការពីក្រសួង ស្ថាប័ន និងគ្រប់ភាគីពាក់ព័ន្ធគឺជាកត្តាជាសារវន្តក្នុងដោះស្រាយបញ្ហាប្រឈមនានាក្នុងការកសាងលិខិតបទដ្ឋានគតិយុត្ត និងសម្រាប់គាំទ្រនិងពន្លឿនការកសាងលិខិតបទដ្ឋានគតិយុត្តកាន់តែមានភាពងាយស្រួល ទាន់ពេលវេលា មានប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ។ ក្នុងវិធានការនេះ ក្រសួងដាក់ចេញនូវការងារអាទិភាពមួយចំនួនដូចជា ការពិគ្រោះយោបល់តាមរយៈកិច្ចប្រជុំ និងសិក្ខាសាលា ជាមួយក្រសួង ស្ថាប័ន អង្គភាព និងភាគីពាក់ព័ន្ធ ជាដើម។ល។

- **វិធានការគន្លឹះទី៤៖ ពង្រឹងយន្តការនៃការផ្សព្វផ្សាយ**

ដើម្បីពង្រឹងការយល់ដឹង និងសារៈសំខាន់នៃការងារអធិការកិច្ច ក្រសួងដាក់ចេញនូវវិធានការ ពង្រឹងយន្តការនៃការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអធិការកិច្ច តាមរយៈសិក្ខាសាលា វេទិកាសាធារណៈ ទស្សនកិច្ចសិក្សា កិច្ចប្រជុំ កម្មវិធីផ្សេងៗ និងតាមប្រព័ន្ធបច្ចេកវិទ្យា។ល។

- **វិធានការគន្លឹះទី៥៖ ពង្រឹងយន្តការនៃការគាំទ្រ**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ ពង្រឹងយន្តការនៃការគាំទ្រទាំងផ្នែកមធ្យោបាយ សម្ភារៈ និងបច្ចេកទេស ក្នុងគោលបំណងដើម្បីបង្ហាញពីឆន្ទៈដ៏មោះមុតក្នុងការជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត ក្នុងវិស័យអធិការកិច្ច ជំរុញការលើកទឹកចិត្តដល់មន្ត្រីអនុវត្តការងារទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ។

## ខ- គោលដៅយុទ្ធសាស្ត្រទី២៖ ជំរុញការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងពង្រឹងប្រសិទ្ធភាពនិងសុខដុមនីយកម្មនៃលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអធិការកិច្ច

### វិធានការគន្លឹះទី១៖ ការកំណត់គោលនយោបាយ

ក្រសួងអធិការកិច្ច បានដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រដោយកំណត់នូវចក្ខុវិស័យ គោលបំណង គោលដៅ វិសាលភាព និងបេសកកម្មដែលត្រូវអនុវត្តឱ្យបានច្បាស់លាស់ជាយុទ្ធសាស្ត្រ សម្រាប់រៀបចំ គោលនយោបាយអធិការកិច្ចមួយដែលអាចទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធ ដោយឈរលើមូលដ្ឋានកែទម្រង់មួយ ដ៏ប្រាកដប្រជា ផ្អែកតាមការស្រាវជ្រាវ បទពិសោធ និងផ្អែកតាមស្ថានភាព និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយកំណត់នូវចំណុចសំខាន់ៗដូចខាងក្រោម៖

**១- ការកំណត់ពីគោលបំណង** (១)ត្រូវធានាអនុលោមតាមច្បាប់ ពង្រឹងនិងលើកកម្ពស់ការអនុវត្តច្បាប់ដល់ស្ថាប័នសាធារណៈ វិស័យឯកជន និងគ្រប់ភាគីពាក់ព័ន្ធ (២)លើកកម្ពស់គណនេយ្យភាព ធ្វើឱ្យស្ថាប័នរដ្ឋទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន និងធានាឱ្យមានតម្លាភាពក្នុងប្រតិបត្តិការ (៣)ទប់ស្កាត់អំពើអសកម្ម ដោយដោះស្រាយនិងមានវិធានការចំពោះការប្រព្រឹត្តមិនត្រឹមត្រូវ ការក្លែងបន្លំ និងអំពើមិនស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ និងឯកជន (៤)កែលម្អការផ្តល់សេវា លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាសាធារណៈ តាមរយៈការត្រួតពិនិត្យ និងផ្តល់យោបល់ជាប្រចាំ (៥)ការពារផលប្រយោជន៍សាធារណៈ ត្រូវការពារសិទ្ធិនិងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ដោយធានានូវការអនុវត្តប្រកបដោយយុត្តិធម៌ និងសីលធម៌

**២- វិសាលភាព** អនុវត្តចំពោះក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាប់កាតព្វកិច្ចតាមច្បាប់កំណត់ ឬបុគ្គលដទៃទៀតដែលពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ។ វិសាលភាពនេះពិតជាមានសារៈសំខាន់ សម្រាប់គាំទ្រដល់សមត្ថកិច្ច បេសកកម្ម និងសិទ្ធិអំណាចរបស់ក្រសួងអធិការកិច្ច

**៣- រចនាសម្ព័ន្ធអធិការកិច្ច** ត្រូវកំណត់ឱ្យច្បាស់លាស់នឹងជួយដោះស្រាយនូវបញ្ហាមិនឯកភាពលើមុខងារអធិការកិច្ច។ ក្រសួងអធិការកិច្ចមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងវិស័យអធិការកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាប័នកំពូលលើការងារអធិការកិច្ចត្រូវផ្តួចផ្តើម និងនាំមុខក្នុងការរៀបចំយន្តការត្រួតពិនិត្យប្រកបដោយគុណភាព ប្រសិទ្ធភាព ព្រមទាំងសុខដុមនីយកម្មនៃមុខងារអធិការកិច្ចនៅក្នុងរដ្ឋបាលសាធារណៈ

**៤- គោលការណ៍អធិការកិច្ច** ត្រូវប្រកាន់ខ្ជាប់នូវ (១)តម្លាភាពការត្រួតពិនិត្យត្រូវបានធ្វើឡើងដោយបើកចំហ ដោយមានទំនាក់ទំនងនិងការទទួលខុសត្រូវច្បាស់លាស់ជាមួយមុខសញ្ញារងអធិការកិច្ច (២)ភាពមិនលម្អៀងមន្ត្រីអធិការកិច្ចធ្វើសកម្មភាពដោយមិនលម្អៀង ធានាបាននូវភាពយុត្តិធម៌ និងស្មើភាពចំពោះមុខច្បាប់ (៣)សុចរិតភាព មន្ត្រីអធិការកិច្ច ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌ខ្ពស់ និងជៀសវាងទំនាស់ផលប្រយោជន៍ (៤) ប្រសិទ្ធភាព ការត្រួតពិនិត្យត្រូវបានធ្វើឡើងទាន់ពេលវេលា គ្រប់ជ្រុងជ្រោយ និង(៥)ការសម្ងាត់ ព័ត៌មានដែលទទួលបានក្នុងអំឡុងពេល ត្រួតពិនិត្យត្រូវបានរក្សាការសម្ងាត់

**៥- នីតិវិធីអធិការកិច្ច** ជាបញ្ហាសំខាន់ក្នុងកិច្ចប្រតិបត្តិការអធិការកិច្ច ដែលជះឥទ្ធិពលដល់ប្រសិទ្ធភាព និងលទ្ធផលអធិការកិច្ច។ នីតិវិធីអធិការកិច្ចត្រូវកំណត់ឱ្យបានច្បាស់លាស់ដូចជា ការកសាងផែនការ ការជូនដំណឹង

ការត្រួតពិនិត្យនៅនឹងកន្លែង ភាពឯករាជ្យនៃរបាយការណ៍អធិការកិច្ចនិងរយៈពេលនៃការឆ្លើយតប និងការតាមដាននូវវិធានការអធិការកិច្ចដែលដាក់ចេញ

**៦- ធនធាន និងបច្ចេកវិទ្យា** ត្រូវគិតគូរជាចាំបាច់ដើម្បីបង្កើនជំនាញ និងចំណេះដឹងឱ្យបានទូលំទូលាយ និងណែនាំអំពីនីតិវិធី ដើម្បីធានាបាននូវភាពស៊ីសង្វាក់គ្នាក្នុងការត្រួតពិនិត្យ និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់សម្រួលដល់ការប្រមូលទិន្នន័យ ការវិភាគ និងការរាយការណ៍ ឱ្យសមស្របតាមបរិបថអធិការកិច្ចឌីជីថល

**៧- ការទទួលខុសត្រូវរបស់ក្រសួងអធិការកិច្ច** លើសេចក្ដីសន្និដ្ឋាន និងវិធានការកែលម្អដោយផ្អែកលើច្បាប់ជាធរមាន ត្រួតពិនិត្យដំណើរការអធិការកិច្ចជាប្រចាំ និងប្រកាន់ខ្ជាប់នូវការអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល សហការយ៉ាងពេញលេញជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីទទួលព័ត៌មាន និងធ្វើការកែតម្រូវ

**៨- ទណ្ឌកម្ម និងការលើកទឹកចិត្ត** ចំពោះបុគ្គលដែលប្រព្រឹត្តល្មើសបទល្មើសអធិការកិច្ច ត្រូវមានវិធានការទណ្ឌកម្ម និងលើកទឹកចិត្តចំពោះបុគ្គលដែលមានស្នាដៃ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការធ្វើអធិការកិច្ច

**៩- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** ដោយកំណត់សូចនាករនៃការអនុវត្ត ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការត្រួតពិនិត្យ បង្កើតយន្តការមតិកែលម្អពីអង្គភាពដែលបានត្រួតពិនិត្យ និងអ្នកពាក់ព័ន្ធ ដើម្បីកែលម្អដំណើរការ ត្រួតពិនិត្យជាប្រចាំ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយអធិការកិច្ច ដើម្បីដោះស្រាយបញ្ហាប្រឈមដែលកំពុងកើតមាន

គោលនយោបាយអធិការកិច្ចរបស់ក្រសួងអធិការកិច្ច ត្រូវគោរពស្នើសុំការសម្រេចជាគោលការណ៍ដ៏ខ្ពង់ខ្ពស់ពី **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី**។ បន្ទាប់ពីការសម្រេចជាគោលការណ៍ពី**សម្តេចមហាបវរធិបតី** គោលនយោបាយអធិការកិច្ចនេះ ជាមូលដ្ឋានគ្រឹះនៃរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអធិការកិច្ចដែលជាយន្តការលើកកម្ពស់គណនេយ្យភាព តម្លាភាព ភាពស្អាតស្អំ និងអភិបាលកិច្ចល្អក្នុងរដ្ឋបាលសាធារណៈ និងធានាថាការត្រួតពិនិត្យត្រូវបានធ្វើឡើងប្រកបដោយប្រសិទ្ធភាព រួមចំណែកដល់ការអភិវឌ្ឍន៍ និងសុខុមាលភាពសង្គមទាំងមូល។

- **វិធានការគន្លឹះទី២៖ ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តជាអាទិភាពរបស់ក្រសួងអធិការកិច្ច**

ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តដែលជាអាទិភាពរបស់ក្រសួងអធិការកិច្ច ដើម្បីពង្រឹងប្រសិទ្ធភាព និងជាយន្តការនៃការគាំទ្រដល់ការអនុវត្តមុខងារ និងភារកិច្ចរបស់ក្រសួងលើការងារអធិការកិច្ច ការងារដោះស្រាយបណ្តឹង ការងារតាមដានការអនុវត្តច្បាប់ និងការផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ។ ក្នុងវិធានការនេះ ក្រសួងនឹងដាក់ចេញនូវផែនការនិងកំណត់នូវលិខិតបទដ្ឋានគតិយុត្តជាអាទិភាពសម្រាប់តាក់តែងឱ្យបានច្បាស់លាស់ សម្រាប់គាំទ្រដល់ស្មារតីអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច មានដូចខាងក្រោម៖

- វិធាននិងនីតិវិធីប្រតិបត្តិ (SOP) សម្រាប់អនុវត្តមុខងារស្នូលរបស់ក្រសួងអធិការកិច្ចរួមមាន ការងារអធិការកិច្ច ការងារដោះស្រាយបណ្តឹង និងការងារតាមដានការអនុវត្តច្បាប់
- អនុក្រឹត្យស្តីពីការបង្កើតមន្ទីរអធិការកិច្ចរាជធានី ខេត្ត
- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរអធិការកិច្ចរាជធានី ខេត្ត

- ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន នៃអគ្គនាយកដ្ឋានអធិការកិច្ច
- ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន នៃអគ្គនាយកដ្ឋានដោះស្រាយបណ្តឹង
- ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះវិទ្យាស្ថានជាតិអធិការកិច្ច
- ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះមន្ទីរអធិការកិច្ចរាជធានី ខេត្ត
- ប្រកាសស្តីពីការបែងចែកក្រសួង ស្ថាប័ន តាមវិស័យក្នុងការធ្វើអធិការកិច្ច និងការកំណត់សមត្ថកិច្ចរបស់នាយកដ្ឋានតាមដានការអនុវត្តច្បាប់ចំណុះអគ្គនាយកដ្ឋានអធិការកិច្ច
- ប្រកាសស្តីពីរូបសញ្ញា និងត្រារបស់វិទ្យាស្ថានជាតិអធិការកិច្ច
- សេចក្តីណែនាំស្តីពីការប្រើប្រាស់រូបសញ្ញា និងត្រារបស់មន្ទីរអធិការកិច្ចរាជធានី ខេត្ត បណ្តោះអាសន្ន
- បទបញ្ជាផ្ទៃក្នុងសម្រាប់គណៈប្រតិភូអធិការកិច្ច និងតាមដានការអនុវត្តច្បាប់
- ប្រកាសស្តីពីក្រមសីលធម៌មន្ត្រីដោះស្រាយបណ្តឹងនិងអង្កេតស្រាវជ្រាវ
- បទបញ្ជាផ្ទៃក្នុងសម្រាប់គណៈប្រតិភូដោះស្រាយបណ្តឹង និងអង្កេតស្រាវជ្រាវ

➢ **វិធានការគន្លឹះទី៣៖ ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រក្នុងវិស័យអធិការកិច្ច**

អនុវត្តតាមអនុសាសន៍តម្រង់ទិសដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងដើម្បីធានាប្រសិទ្ធភាពនៃការដឹកនាំ និងគ្រប់គ្រងវិស័យអធិការកិច្ច ក្រសួងអធិការកិច្ចផ្តួចផ្តើមនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យនិងពិភាក្សា កែសម្រួលលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអធិការកិច្ចឱ្យមានសង្គតិភាព មានឯកភាព ប្រសិទ្ធភាព ស្តង់ដារួម សមានគតិភាព ឧត្តមានុភាពគតិយុត្ត និងសន្តិសុខគតិយុត្ត ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងបរិការណ៍កម្ពុជា។ ក្រសួងអធិការកិច្ចដាក់ចេញនូវវិធានការ ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រក្នុងវិស័យអធិការកិច្ចសម្រាប់ជាយន្តការនៃការគាំទ្រដល់ការអនុវត្តមុខងារ និងភារកិច្ចរបស់អង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន។ ក្នុងវិធានការនេះ ក្រសួងនឹងដាក់ចេញនូវផែនការនិងកំណត់នូវលិខិតបទដ្ឋានគតិយុត្តជាអាទិភាពសម្រាប់តាក់តែងឱ្យបានច្បាស់លាស់ សម្រាប់គាំទ្រវិស័យអធិការកិច្ច មានដូចខាងក្រោម៖

- ឯកសារទស្សនាទានស្តីពីអធិការកិច្ច
- គោលនយោបាយជាតិស្តីពីអធិការកិច្ច
- ច្បាប់ស្តីពីអធិការកិច្ច
- អនុក្រឹត្យស្តីពីឯកសណ្ឋាន និងសញ្ញាស័ក្តិរបស់មន្ត្រីអធិការកិច្ច

- អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈ និងក្រមប្រតិបត្តិមន្ត្រីអធិការកិច្ច
- អនុក្រឹត្យស្តីពីនីតិវិធីអធិការកិច្ច និងតាមដានការអនុវត្តច្បាប់
- អនុក្រឹត្យស្តីពីនីតិវិធីទទួល ពិនិត្យ អង្កេតស្រាវជ្រាវ និងដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហារ
- អនុក្រឹត្យស្តីពីភារកិច្ច និងសិទ្ធិអំណាចរបស់ស្ថាប័នអធិការកិច្ច
- អនុក្រឹត្យស្តីពីនីតិវិធីនៃការរៀបចំផែនការរួមស្តីពីអធិការកិច្ច
- អនុក្រឹត្យស្តីពីនីតិវិធីនៃការអនុវត្តសេចក្តីសម្រេចលើលទ្ធផលអធិការកិច្ច
- ច្បាប់ស្តីពីបណ្តឹងតវ៉ា និងបណ្តឹងបរិហារ។

## VI. ជំរុញ និងបង្កើនសមត្ថភាពស្ថាប័ន

ក្រសួងអធិការកិច្ចដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រ ជំរុញ និងបង្កើនសមត្ថភាពស្ថាប័ន ក្នុងគោលបំណងដើម្បីប្រែក្លាយក្រសួងអធិការកិច្ចទៅជាស្ថាប័នសាធារណៈរឹងមាំ ទំនើប ប្រកបដោយឧត្តមភាព សមត្ថភាព ប្រសិទ្ធភាព និងគុណវុឌ្ឍិគ្រប់គ្រាន់។ ក្នុងយុទ្ធសាស្ត្រនេះ ក្រសួងអធិការកិច្ចដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន៤ អមដោយវិធានការគន្លឹះចំនួន១០ដូចខាងក្រោម៖

### ក- គោលដៅយុទ្ធសាស្ត្រទី១៖ លើកកម្ពស់សមត្ថភាព និងការធ្វើទំនើបកម្មស្ថាប័ន

ការដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រលើកកម្ពស់សមត្ថភាព និងការធ្វើទំនើបកម្មស្ថាប័ន ក្នុងគោលបំណងដើម្បីបង្កើនសមត្ថភាពស្ថាប័នក្នុងដំណាក់កាលកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលកំពុងត្រូវបានជំរុញ និងការវិវត្តដ៏ឆាប់រហ័សនៃប្រព័ន្ធបច្ចេកវិទ្យា។ គោលដៅយុទ្ធសាស្ត្រទី១នេះ គាំទ្រដោយវិធានការគន្លឹះចំនួន៤គឺ៖

➢ **វិធានការគន្លឹះទី១៖ ពង្រឹងការងារវិភាគមុខងារ និងការរៀបចំរចនាសម្ព័ន្ធអង្គភាពចំណុះក្រសួង**

ការវិភាគមុខងារ និងពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធអង្គភាពគឺជាការងារដ៏មុតស្រួចរបស់រាជរដ្ឋាភិបាលតាមរយៈការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនៃការរៀបចំមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន។ តាមរយៈការងារវិភាគមុខងារដែលក្រសួងអធិការកិច្ចបានចាប់ផ្តើមរៀបចំកាលពីចុងឆ្នាំ២០២៣ កន្លងមក ក្រសួងបានពិនិត្យឡើងវិញនូវមុខងារនិងរចនាសម្ព័ន្ធរបស់ក្រសួង និងបានរៀបចំឡើងវិញនូវមុខងារ និងរចនាសម្ព័ន្ធដូចកំណត់ក្នុងអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច នឹងត្រូវបន្តការងារនេះនៅដំណាក់កាលបន្តបន្ទាប់ ក្នុងការពិនិត្យមុខងាររបស់មន្ត្រីចាប់ពីថ្នាក់អគ្គនាយកចុះ រៀបចំឡើងវិញនូវរចនាសម្ព័ន្ធរបស់អង្គភាពចំណុះក្រសួង ទាំងថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ។ ដើម្បីពង្រឹងប្រសិទ្ធភាពនៃវិធានការនេះ ក្រសួងដាក់ចេញនូវការងារអាទិភាពចំនួន៣គឺ (១)បន្តវិភាគមុខងាររបស់មន្ត្រីចាប់ពីថ្នាក់អគ្គនាយកចុះ (២)ពង្រឹងការរៀបចំរចនាសម្ព័ន្ធរបស់អង្គភាពចំណុះក្រសួង (៣)ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តមុខងាររបស់មន្ត្រី

➢ **វិធានការគន្លឹះទី២៖ ជំរុញការធ្វើទំនើបកម្មស្ថាប័ន**

ក្រសួងដាក់ចេញនូវវិធានការជំរុញការធ្វើទំនើបកម្មស្ថាប័ន ក្នុងគោលបំណងពង្រឹងនូវសមត្ថភាពស្ថាប័ន និងធានាប្រសិទ្ធភាព នៃការអនុវត្តការងារឱ្យកាន់តែប្រសើរក្នុងការបម្រើសេវាជូនប្រជាពលរដ្ឋក្នុងវិស័យអធិការកិច្ច ស្របពេលនៃការរីកចម្រើនយ៉ាងឆាប់រហ័សនៃប្រព័ន្ធបច្ចេកវិទ្យាឌីជីថល។ ក្នុងវិធានការនេះត្រូវបានគាំទ្រដោយការងារ

អាទិភាពចំនួន៤គឺ (១)បំពាក់សម្ភារៈបរិក្ខារទំនើបឱ្យបានគ្រប់គ្រាន់នៅការិយាល័យ (២)កែលម្អសាលប្រជុំ និងបំពាក់ឧបករណ៍បំពងសំឡេងទំនើបតាមបែបឌីជីថល (៣)ពង្រឹងការត្រួតពិនិត្យ Camera សុវត្ថិភាពនៅតាមច្រកចេញចូល និង(៤)រៀបចំប្រព័ន្ធលំហូរឯកសារឌីជីថល

➢ **វិធានការគន្លឹះទី៣៖ កែលម្អកន្លែងធ្វើការប្រកបដោយផាសុកភាព សោភ័ណភាព និងអនាម័យ**

បរិស្ថានក្រសួង និងសុខភាពរបស់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការរបស់ក្រសួងជាបញ្ហាសំខាន់។ ការដាក់ចេញនូវវិធានការ កែលម្អកន្លែងធ្វើការប្រកបដោយផាសុកភាព សោភ័ណភាព និងអនាម័យ ក្នុងគោលបំណងលើកកម្ពស់ការចូលរួមរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្នុងការងារបរិស្ថាន ធានានូវនិរន្តភាពនិងប្រសិទ្ធភាពការងាររបស់ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់រូប។ វិធានការគន្លឹះទី៣នេះ ត្រូវបានគាំទ្រដោយការងារអាទិភាពចំនួន៧គឺ (១)កែលម្អបន្ទប់ទឹក និងពង្រឹងការរក្សាអនាម័យ (២)ពង្រឹងការកែលម្អសោភ័ណភាព និងបរិស្ថានបរិវេណក្នុងនិងក្រៅ (៣)ពង្រឹងការផ្គត់ផ្គង់ទឹកស្អាត (៤)ពង្រឹងស្មារតីចូលរួមរបស់មន្ត្រីក្នុងការថែរក្សាបរិស្ថាន និងអនាម័យ តាមរយៈយុទ្ធនាការការងារផ្សារភ្ជាប់នឹងសុខភាព (៥)រៀបចំឡើងវិញនូវបទបញ្ជាផ្ទៃក្នុងរបស់ក្រសួង (៦)ពង្រឹងការងារសន្តិសុខនិងសណ្តាប់ធ្នាប់ និង(៧)បង្កើតទារកដ្ឋានសម្រាប់សម្រួលដល់មន្ត្រីដែលមានកូនតូច។

➢ **វិធានការគន្លឹះទី៤៖ ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារ**

ដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្តការងារ ក្រសួងដាក់ចេញនូវវិធានការ ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារ ត្រូវបានគាំទ្រដោយការងារអាទិភាពចំនួន៥គឺ (១)ពង្រឹងយន្តការប្រជុំថ្នាក់ដឹកនាំប្រចាំសប្តាហ៍ (២)បង្កើតយន្តការតាមដានវាយតម្លៃការងាររបស់អង្គភាព (៣)ធ្វើការវាយតម្លៃការងាររបស់អង្គភាពជាប្រចាំ (៤)ពង្រឹងប្រព័ន្ធត្រួតពិនិត្យនិងតាមដានវាយតម្លៃនៅគ្រប់កម្រិត និង(៥)អភិវឌ្ឍសមត្ថភាពអង្គភាព និងមន្ត្រីទទួលបន្ទុកការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

## ខ- គោលដៅយុទ្ធសាស្ត្រទី២៖ ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់ធនធានមនុស្ស

ការដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការប្រើប្រាស់ធនធានមនុស្ស ក្នុងគោលបំណងធានានិរន្តភាពការងារ លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងនិងប្រើប្រាស់មន្ត្រីឱ្យបានត្រឹមត្រូវតាមជំនាញ សមត្ថភាព និងសេចក្តីត្រូវការជាក់ស្តែង ស្របតាមវិធានការគន្លឹះរបស់រាជរដ្ឋាភិបាលក្នុងការងារកែទម្រង់រដ្ឋបាលសាធារណៈ។ គោលដៅយុទ្ធសាស្ត្រទី២នេះ ត្រូវបានគាំទ្រដោយវិធានការចំនួន២គឺ៖

➢ **វិធានការគន្លឹះទី១៖ ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងមន្ត្រី**

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងមន្ត្រី ក្រសួងដាក់ចេញនូវការងារអាទិភាពចំនួន៦គឺ (១)បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រី (២)ពង្រឹងប្រព័ន្ធគ្រប់គ្រងបៀវត្ស (៣)រៀបចំបោះពុម្ពបណ្ណសម្គាល់ខ្លួនមន្ត្រីរាជការឡើងវិញ (៤)ធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីប្រចាំឆ្នាំ (៥)ពង្រឹងការគ្រប់គ្រងបម្រែបម្រួលស្ថានភាពរដ្ឋបាលរបស់មន្ត្រី និង(៦)បំពាក់ប្រព័ន្ធគ្រប់គ្រងវត្តមានមន្ត្រីរាជការទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

➢ **វិធានការគន្លឹះទី២៖ ពង្រឹងការប្រើប្រាស់ធនធានមនុស្ស**

ក្រសួងត្រូវពិនិត្យការប្រើប្រាស់មន្ត្រីដែលមានស្រាប់ឱ្យអស់សក្តានុពល មុននឹងធ្វើវិចារណកម្មលើការជ្រើសរើសបន្ថែមនូវបុគ្គលិក និងមន្ត្រីរាជការថ្មី។ វិធានការពង្រឹងការប្រើប្រាស់ធនធានមនុស្ស ត្រូវបានគាំទ្រដោយ

ការងារអាទិភាពចំនួន៣គឺ (១)ពង្រឹងការបែងចែកតួនាទី មុខងារ ភារកិច្ចមន្ត្រីនៅតាមអង្គភាព (២)ពង្រឹងការអនុវត្ត មុខងារ និងភារកិច្ចរបស់មន្ត្រី និង(៣)ពង្រឹងការរៀបចំផែនការប្រើប្រាស់ធនធានមនុស្ស។

### គ- គោលដៅយុទ្ធសាស្ត្រទី៣៖ អភិវឌ្ឍន៍ធនធានមនុស្សឈានទៅកសាងមូលធនមនុស្សប្រកបដោយគុណវុឌ្ឍិ

ធនធានមនុស្សជាកត្តាកំណត់សំខាន់បំផុតដើម្បីធានាបាននូវនិរន្តរភាពការងារ និងការអភិវឌ្ឍប្រកបដោយចីរភាពរបស់ក្រសួង ស្ថាប័ន ឬអង្គភាព។ ហេតុនេះក្រសួងត្រូវចាំបាច់យកចិត្តទុកដាក់ខ្ពស់លើការកសាងធនធានមនុស្ស និងអភិវឌ្ឍមូលធនមនុស្សជាប់ជាប្រចាំ ទាំងសមត្ថភាពចំណេះដឹង និងជំនាញវិជ្ជាជីវៈស្របតាមតម្រូវការអនុវត្តមុខងារ ភារកិច្ច និងបេសកកម្មដែលរាជរដ្ឋាភិបាលបានប្រគល់ឱ្យ។ ក្នុងន័យនេះ ក្រសួងដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ អភិវឌ្ឍធនធានមនុស្សឈានទៅកសាងមូលធនមនុស្សប្រកបដោយគុណវុឌ្ឍិ ដែលគាំទ្រដោយវិធានការគន្លឹះចំនួន២គឺ៖

- **វិធានការគន្លឹះទី១៖ ពង្រឹងការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស**

ការបណ្តុះបណ្តាលសមត្ថភាពចំណេះដឹង និងជំនាញវិជ្ជាជីវៈជាកិច្ចការចាំបាច់នៃការអភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រីរាជការ។ ក្រសួងអធិការកិច្ចមានធនធានមនុស្សដែលពោរពេញដោយចំណេះដឹងខ្ពស់ ប៉ុន្តែត្រូវការការបំប៉នបន្ថែមនូវជំនាញវិជ្ជាជីវៈឱ្យស្របតាមបរិបទនៃការប្រែប្រួលបច្ចេកវិទ្យា ដើម្បីធានាប្រសិទ្ធភាពនៃការអភិវឌ្ឍធនធានមនុស្សប្រកបដោយសក្តានុពល និងឆ្ពោះទៅមូលធនមនុស្សប្រកបដោយគុណវុឌ្ឍិ។ ក្រសួងដាក់ចេញនូវវិធានការ ពង្រឹងការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស លើចំណេះដឹង ជំនាញវិជ្ជាជីវៈ ដោយផ្អែកតាមការស្ទង់មតិលើតម្រូវការជាក់ស្តែង ដោយបានកំណត់ការងារអាទិភាពចំនួន៣គឺ (១)បង្កើនកម្មវិធីបណ្តុះបណ្តាលចំណេះដឹង និងជំនាញវិជ្ជាជីវៈ (២)ស្ទង់មតិអំពីតម្រូវការនៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង(៣)ជំរុញការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស

- **វិធានការគន្លឹះទី២៖ ការពង្រឹងការអនុវត្តច្បាប់និងក្រមសីលធម៌វិជ្ជាជីវៈ**

ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ក្រមសីលធម៌និងការគោរពវិន័យ គឺជាកត្តាសំខាន់ដែលមិនអាចខ្វះបានក្នុងការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងជំរុញនូវប្រសិទ្ធភាពការងាររបស់អង្គភាព លើកកម្ពស់មនសិការវិជ្ជាជីវៈមន្ត្រីរាជការនិងបុគ្គលិករបស់ក្រសួង។ ក្នុងវិធានការគន្លឹះនេះ ក្រសួងដាក់ចេញនូវការងារអាទិភាពចំនួន២គឺ (១)ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ក្រមសីលធម៌វិជ្ជាជីវៈ និងវិន័យរបស់មន្ត្រីរាជការ និង(២)ពង្រឹងវិធានការវិន័យ និងយន្តការទណ្ឌកម្មចំពោះមន្ត្រីដែលមានកំហុស។

### ឃ- គោលដៅយុទ្ធសាស្ត្រទី៤៖ ពង្រឹងយន្តការវាយតម្លៃលទ្ធផលការងារ និងជំរុញប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម

ការវាយតម្លៃជាសូចនាករវាស់វែងពីលទ្ធផលនៃការអនុវត្តការងារ កិច្ចខិតខំប្រឹងប្រែងក្នុងការបំពេញការងារ ការលះបង់ និងការព្យាយាមរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក និងអង្គភាពចំណុះក្រសួង។ ការវាយតម្លៃជាមូលដ្ឋាននៃការលើកទឹកចិត្តជាហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ឬការចាត់វិធានការខាងវិន័យ។ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងាររបស់អង្គភាពនីមួយៗ ក្រសួងដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ ពង្រឹងយន្តការវាយតម្លៃ និងជំរុញប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ដែលគាំទ្រដោយវិធានការគន្លឹះចំនួន២គឺ៖

➢ **វិធានការគន្លឹះទី១៖ ពង្រឹងប្រសិទ្ធភាពនៃការវាយតម្លៃមន្ត្រីដែលមានស្នាដៃ**

ការវាយតម្លៃការអនុវត្តការងាររបស់បុគ្គល និងអង្គភាព ទាមទារឱ្យមានឧបករណ៍វាស់វែងច្បាស់លាស់ ជាក់លាក់ដែលមានកំណត់ពីយន្តការ បែបបទ នីតិវិធីនៃការត្រួតពិនិត្យនិងវាយតម្លៃ ដែលអាចធ្វើការវាយតម្លៃប្រកបដោយសុក្រឹតភាព តម្លាភាព និងសមធម៌។ ផ្អែកតាមគោលការណ៍នេះ ក្រសួងដាក់ចេញនូវវិធានការពង្រឹងប្រសិទ្ធភាពនៃការវាយតម្លៃមន្ត្រីដែលមានស្នាដៃ គាំទ្រដោយការងារអាទិភាពចំនួន៣គឺ (១)បង្កើតគណៈកម្មការវាយតម្លៃមន្ត្រី (២)បង្កើតវិធីសាស្ត្រនៃការវាយតម្លៃប្រកបដោយតម្លាភាព និង(៣)ពង្រឹងការវាយតម្លៃដោយផ្អែកលើសមិទ្ធកម្មការងារ

➢ **វិធានការគន្លឹះទី២៖ ពង្រឹងយន្តការប្រព័ន្ធលើកទឹកចិត្តមន្ត្រីគាំទ្រសមិទ្ធកម្ម**

ក្រៅពីអត្ថប្រយោជន៍ផ្នែកបៀវត្ស ការលើកទឹកចិត្តផ្សេងទៀតទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិករបស់ក្រសួង ក៏ជាការចាំបាច់ដែលត្រូវយកចិត្តទុកដាក់ផងដែរ ដើម្បីធានាតម្លាភាព សមធម៌ និងគណនេយ្យភាពធៀបនឹងសមិទ្ធកម្ម។ ហេតុនេះក្រសួងដាក់ចេញនូវវិធានការពង្រឹងយន្តការប្រព័ន្ធលើកទឹកចិត្តមន្ត្រីគាំទ្រសមិទ្ធកម្ម ដោយបានកំណត់នូវការងារអាទិភាពចំនួន៦គឺ (១)ពង្រឹងការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុផ្អែកលើសមិទ្ធកម្មរបស់អង្គភាព (២)ពង្រឹងការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុផ្អែកលើសមិទ្ធកម្មរបស់បុគ្គល (៣)ពង្រឹងការលើកទឹកចិត្តមិនមែនហិរញ្ញវត្ថុដូចជាការផ្តល់នូវតួនាទី គ្រឿងឥស្សរិយយស បណ្ណសរសើរ ការបណ្តុះបណ្តាលក្រៅប្រទេស ឬការដំឡើងកាំប្រាក់ជាដើម (៤)រៀបចំកែសម្រួលប្រព័ន្ធលើកទឹកចិត្តគ្រប់អង្គភាពឱ្យមានប្រសិទ្ធភាព ប្រសិទ្ធផល និងតម្លាភាព (៥)ជួយឧបត្ថម្ភមន្ត្រីក្នុងពេលរៀបអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួន និង(៦)ការចូលរួមចំណែក និងដោះស្រាយការលំបាករបស់មន្ត្រីដូចជាពេលមានជំងឺជាដើម។

## VII. ជំរុញកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូ

ភាពជោគជ័យនៃកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូរបស់ក្រសួង អាស្រ័យលើគំនិតផ្តួចផ្តើមនិងយុទ្ធសាស្ត្រប្រកបដោយភាពបុរេសកម្ម សកម្ម និងអន្តរសកម្ម ដែលត្រូវបានរៀបចំឡើងដើម្បីកសាងទំនុកចិត្ត ជំរុញកិច្ចសហ-ប្រតិបត្តិការជាមួយតួអង្គពាក់ព័ន្ធទាំងអស់។ ក្នុងយុទ្ធសាស្ត្រ ជំរុញកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូ ក្រសួងអធិការកិច្ចដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន៣ ដូចខាងក្រោម៖

### ក- គោលដៅយុទ្ធសាស្ត្រទី១៖ ជំរុញ និងពង្រីងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

ក្នុងរយៈពេលកន្លងមក ក្រសួងអធិការកិច្ចបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួង ស្ថាប័នមួយចំនួនដូចជា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងព័ត៌មាន សាលាភូមិន្ទរដ្ឋបាលនៃក្រសួងមុខងារសាធារណៈ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងមន្ទីរពេទ្យព្រះកេតុមាលា។ ក្រសួងដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រនេះ ក្នុងគោលបំណងដើម្បីជំរុញនិងអនុវត្តកិច្ចសហការជាមួយក្រសួង ស្ថាប័នដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នា និងបន្តជំរុញកិច្ចសហការជាមួយក្រសួង ស្ថាប័នដទៃទៀតចំណុះរាជរដ្ឋាភិបាល ក្នុងគោលដៅពង្រីកវិសាលភាពនៃកិច្ចសហប្រតិបត្តិការលើវិស័យអធិការកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

### ខ- គោលដៅយុទ្ធសាស្ត្រទី២៖ ជំរុញ និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់និងពិភពលោក

ក្នុងគោលដៅទំនាក់ទំនងផ្លាស់ប្តូរបទពិសោធវិស័យអធិការកិច្ចកម្ពុជាជាមួយបណ្តាប្រទេសនានា ក្រសួងអធិការកិច្ចដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ ការជំរុញកិច្ចសហប្រតិបត្តិការស៊ីជម្រៅជាមួយដៃគូសំខាន់ៗ ដែលមានការងារអាទិភាពមួយចំនួនដូចជា (១)បន្តអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម (២)ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយសាធារណរដ្ឋប្រជាមានិតចិន (៣)បន្តសហប្រតិបត្តិការជាមួយសាធារណរដ្ឋឥណ្ឌា (៤)បន្តសហការជាមួយស្ថានទូតដើម្បីឈានទៅរកកិច្ចសហប្រតិបត្តិការជាមួយព្រះរាជាណាចក្រថៃ សាធារណរដ្ឋឥណ្ឌូនេស៊ី និងសាធារណរដ្ឋហ្វីលីពីន ឆ្ពោះទៅចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយស្ថាប័នដោះស្រាយបណ្តឹងនៃប្រទេសទាំងបី (៥)បន្តសហការ ជាមួយស្ថានទូតសាធារណរដ្ឋហុងគ្រី និងសាធារណរដ្ឋទួរគីយេ ដើម្បីផ្សារភ្ជាប់វិស័យអធិការកិច្ចកម្ពុជាជាមួយប្រទេសនៅអឺរ៉ុប (៦)ពិនិត្យលទ្ធភាពសហការជាមួយប្រទេសផ្សេងទៀតដូចជា ប្រទេសជប៉ុន សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋសឹង្ហបុរី ជាដើម។

### គ- គោលដៅយុទ្ធសាស្ត្រទី៣៖ ជំរុញកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ

ក្រសួងអធិការកិច្ចដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ ការជំរុញកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗក្នុងក្របខ័ណ្ឌភាពជាដៃគូក្នុងការប្រឆាំងអំពើពុករលួយ ASEAN Parties Against Corruption (ASEAN-PAC) វេទិកាដោះស្រាយបណ្តឹងអាស៊ីអាគ្នេយ៍ South East Asian Ombudsman Forum (SEAOF) និងពិនិត្យលទ្ធភាពសហការជាមួយអង្គការអន្តរជាតិដូចជា UNDP Asia Foundation និងដៃគូផ្សេងទៀត។

## VIII. ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល

ក្រសួងអធិការកិច្ចដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រ ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងគោលបំណងរួមចំណែកសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញស្ថាប័នសាធារណៈឱ្យក្លាយជាស្ថាប័នទំនើប ខ្លាំង វៃឆ្លាត និងដើម្បីធានាប្រសិទ្ធភាពនិងប្រសិទ្ធផលការងាររបស់ក្រសួងអធិការកិច្ច ក្នុងដំណាក់កាលនៃការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល។ ក្នុងយុទ្ធសាស្ត្រនេះ ក្រសួងអធិការកិច្ចដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន៣ អមដោយវិធានការគន្លឹះដូចខាងក្រោម៖

### ក- គោលដៅយុទ្ធសាស្ត្រទី១៖ លើកកម្ពស់ការអភិវឌ្ឍអេឡិចត្រូនិចឌីជីថល

➢ វិធានការគន្លឹះទី១៖ កសាងហេដ្ឋារចនាសម្ព័ន្ធរឹង

ដើម្បីចូលរួមចំណែកសម្រេចឱ្យបាននូវវិធានការ កសាងហេដ្ឋារចនាសម្ព័ន្ធរឹង ក្រសួងអធិការកិច្ចដាក់ចេញនូវការងារអាទិភាពដូចជា (១)រៀបចំហេដ្ឋារចនាសម្ព័ន្ធឌីជីថល តខ្សែបណ្តាញប្រព័ន្ធអ៊ីនធើណែត និងប្រព័ន្ធ Network (២)រៀបចំបំពាក់សម្ភារៈបរិក្ខារបច្ចេកវិទ្យាព័ត៌មានវិទ្យារួមមាន ម៉ាស៊ីន Computer, Printer, Scanner, Photocopy (៣)រៀបចំបំពាក់ឧបករណ៍សន្តិសុខសាយប័រ សម្រាប់ការពារមជ្ឈមណ្ឌលទិន្នន័យរួមរបស់ក្រសួង (៤)រៀបចំបំពាក់គ្រឿងសង្ហារិមដើម្បីធានាបានផាសុកភាព សុវត្ថិភាព និងប្រសិទ្ធភាពនៃដំណើរការ

ការងាររបស់នាយកដ្ឋានបរិវត្តកម្មឌីជីថល និង(៥)រៀបចំធ្វើឌីជីថលលូបនីយកម្ម រួមទាំងការបង្កើតបញ្ញាសិប្បនិម្មិត និងបច្ចេកវិទ្យាទាន់សម័យសម្រាប់ការងារគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអធិការកិច្ច

➢ **វិធានការគន្លឹះទី២៖ កសាងហេដ្ឋារចនាសម្ព័ន្ធទន់**

ដើម្បីចូលរួមចំណែកសម្រេចឱ្យបាននូវវិធានការ កសាងហេដ្ឋារចនាសម្ព័ន្ធទន់ ក្រសួងអធិការកិច្ចដាក់ចេញនូវការងារអាទិភាពដូចជា (១)រៀបចំសហការបង្កើតកម្មវិធីផ្សព្វផ្សាយ ណែនាំនូវរបៀបប្រើប្រាស់ថ្នាល (Mobile App) និងបច្ចេកវិទ្យាព័ត៌មានវិទ្យាដល់មន្ត្រីរាជការក្រោមឱវាទក្រសួង (២)ច្នៃប្រឌិត និងបង្កើតវិធីសាស្ត្រ នីតិវិធីនិងកម្មវិធីសម្រាប់គាំទ្រនិងទ្រទ្រង់ដំណើរការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអធិការកិច្ច និង(៣)រៀបចំសហការ សម្របសម្រួល និងជំរុញបរិវត្តកម្មឌីជីថល ស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលឌីជីថល។

## ខ- គោលដៅយុទ្ធសាស្ត្រទី២៖ លើកកម្ពស់អភិវឌ្ឍកម្មវិធីកុំព្យូទ័រ និងឧបករណ៍ឆ្លាតវៃ

➢ **វិធានការគន្លឹះទី១៖ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាឌីជីថល**

ដើម្បីចូលរួមចំណែកសម្រេចឱ្យបាននូវវិធានការ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាឌីជីថល ក្រសួងអធិការកិច្ចដាក់ចេញនូវការងារអាទិភាពដូចជា (១)បន្តកិច្ចសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការរៀបចំថ្នាលសម្រាប់ផ្ទុកឯកសារ ថ្នាលសម្រាប់ដំណើរការចរន្តឯកសារ ថ្នាលសម្រាប់គ្រប់គ្រងព័ត៌មានមន្ត្រីរាជការក្រសួងអធិការកិច្ច (២)បន្តកិច្ចសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការរៀបចំថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh នៅលើវិញ្ញាបនបត្របញ្ជាក់ការសិក្សាចេញដោយវិទ្យាស្ថានជាតិអធិការកិច្ច (៣)ស្នើសុំទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រើប្រាស់នូវថ្នាល និងកម្មវិធីរាជរដ្ឋាភិបាលឌីជីថល (Digital Government Products – DGPs) ចំនួន៤រួមមាន ថ្នាលផ្ទុកឯកសារសាធារណៈ GO.GOV.KH ថ្នាលបង្កើតទម្រង់បែបបទអនឡាញ FORM.GOV.KH ថ្នាលបញ្ជូនសារពហុទិសដៅ NOMSA.GOV.KH និងកម្មវិធីបញ្ញាសិប្បនិម្មិតបំប្លែងអត្ថបទទៅជាសំឡេងសារិកា "SIRIKA" សម្រាប់ប្រើប្រាស់ក្នុងក្របខ័ណ្ឌក្រសួងអធិការកិច្ច (៤)បន្តកិច្ចសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីរៀបចំតម្លើងសុសវែ(Software) ដែលមានអាជ្ញាបណ្ណត្រឹមត្រូវលើម៉ាស៊ីនកុំព្យូទ័រឬឧបករណ៍ឌីជីថលជូនថ្នាក់ដឹកនាំនិងមន្ត្រីរាជការ សម្រាប់ប្រើប្រាស់ក្នុងការងារប្រចាំថ្ងៃ ដើម្បីធានាសុវត្ថិភាពពីការជ្រៀតជ្រែកលួចបន្លំ តាមរយៈការវាយប្រហារសាយប័រ (Cyber Attack) (៥)ធ្វើបច្ចុប្បន្នភាពគេហទំព័រ និងថ្នាលព្រមទាំងដាក់ឱ្យដំណើរការឡើងវិញ បន្ទាប់ពីធ្វើកំណែរួច(Mobile App) របស់ក្រសួងអធិការកិច្ច ដើម្បីធានាសុវត្ថិភាពឱ្យស្របទៅនឹងការវិវត្តនៃបច្ចេកវិទ្យាឌីជីថលសកល (៦)សហការជាមួយអង្គភាពក្រោមឱវាទក្រសួងក្នុងការផលិតមាតិកាព័ត៌មានលើថ្នាល សម្រាប់ការងារផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ (៧)ធ្វើការសិក្សា និងរៀបចំចងក្រងមូលដ្ឋានទិន្នន័យរបស់មន្ត្រីរួមមាន ការគ្រប់គ្រងវត្តមានកម្រិតជំនាញ ការពិពណ៌នាមុខតំណែង និងការវាយតម្លៃសមិទ្ធកម្មការងារ (៨)រៀបចំអភិវឌ្ឍកម្មវិធីគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការធ្វើសមាហរណកម្មនិងសន្ទានកម្មប្រព័ន្ធព័ត៌មាន ដើម្បីបម្រើដល់ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអធិការកិច្ច (៩)រៀបចំរចនានូវផ្ទាំងរូបភាពណែនាំពីរបៀបប្រើប្រាស់ថ្នាលនៃប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីនៃក្រសួងអធិការកិច្ចតាមប្រព័ន្ធឌីជីថល (១០)រៀបចំនិងថែទាំបន្ទប់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យរួម(Data Center)

សម្រាប់ប្រើប្រាស់ជាមជ្ឈមណ្ឌលគ្រប់គ្រងនិងបែងចែកប្រព័ន្ធព័ត៌មានវិទ្យា សេវាអ៊ីនធឺណែតនិងទិន្នន័យរួម (Database) នៅទីស្តីការក្រសួងអធិការកិច្ច (១១)រៀបចំតម្លើងនិងថែទាំម៉ាស៊ីនមេ (Server) សម្រាប់ផ្ទុកទិន្នន័យនិងចែករំលែកទិន្នន័យទៅកាន់អង្គភាពក្រោមឱវាទក្រសួង (១២)រៀបចំបំពាក់និងថែទាំសម្ភារៈបរិក្ខារអ៊ីនធឺណែតថ្មីបន្ថែមរួមមាន តម្លើងទូ Main Server នៅបន្ទប់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យរួមសម្រាប់ផ្ទុកសម្ភារៈបរិក្ខារមេ (Server, Router, Switch និងខ្សែបណ្ដាញមេ) និងតម្លើងទូ Sub Server(ទូ Rack)ចំនួន២ទីតាំងទៀតនៅអគារB និងអគារC នៅទីស្តីការក្រសួងអធិការកិច្ច (១៣)រៀបចំបំពាក់និងថែទាំឧបករណ៍ចែកសេវាអ៊ីនធឺណិត Access Point (WiFi Router) និងប្រអប់ភ្ជាប់អ៊ីនធឺណែតនិងបណ្ដាញ(Outlet) ក្នុងក្រសួងអធិការកិច្ចនិង (១៤)រៀបចំពង្រឹងពង្រីកថ្នាលសម្រាប់ផ្ទុកនិងផ្លាស់ប្តូរទិន្នន័យ ដើម្បីបង្កើនសមត្ថភាពគ្រប់គ្រងសម្រាប់ផ្លាស់ប្តូរទិន្នន័យប្រព័ន្ធព័ត៌មានរវាងក្រសួងអធិការកិច្ចជាមួយក្រសួង ស្ថាប័ន និងមន្ទីរអធិការកិច្ចរាជធានីខេត្ត ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពការងារ។

- **វិធានការគន្លឹះទី២៖ ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល**

ដើម្បីចូលរួមចំណែកសម្រេចឱ្យបាននូវវិធានការ ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល ក្រសួងអធិការកិច្ចដាក់ចេញនូវការងារអាទិភាពដូចជា (១)ការរៀបចំបណ្តុះបណ្តាលអភិវឌ្ឍធនធានមនុស្សលើជំនាញសន្តិសុខបច្ចេកវិទ្យាឌីជីថល (២)ការរៀបចំ និងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល មានគោលបំណងការពារហេដ្ឋារចនាសម្ព័ន្ធឌីជីថលឱ្យបានគ្រប់ជ្រុងជ្រោយ ធានាសុវត្ថភាព និងសន្តិសុខខ្ពស់លើការគ្រប់គ្រងប្រត្តិបត្តិការនិងការប្រើប្រាស់ប្រព័ន្ធឌីជីថល និង(៣)ពង្រឹងប្រព័ន្ធគ្រប់គ្រង និងការពារសន្តិសុខឌីជីថលសម្រាប់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន តាមរយៈការកំណត់នីតិវិធីសុវត្ថិភាព និងការបំពាក់សម្ភារៈបច្ចេកទេសសម្រាប់តាមដានត្រួតពិនិត្យ និងទប់ស្កាត់ការវាយប្រហារនានាស្របតាមស្តង់ដាសន្តិសុខឌីជីថល។

## គ- គោលដៅយុទ្ធសាស្ត្រទី៣៖ អភិវឌ្ឍនវានុវត្តន៍ឌីជីថលក្នុងវិស័យអធិការកិច្ច

ដើម្បីចូលរួមចំណែកសម្រេចឱ្យបាននូវការអភិវឌ្ឍន៍នវានុវត្តឌីជីថលក្នុងវិស័យអធិការកិច្ច ក្រសួងអធិការកិច្ចដាក់ចេញនូវការងារអាទិភាពដូចជា (១)ស្វែងរកកិច្ចសហប្រត្តិបត្តិការជាមួយបណ្ដាក្រុមហ៊ុនជាតិនិងអន្តរជាតិទាំងក្នុងនិងក្រៅប្រទេស ក្នុងការស្រាវជ្រាវអភិវឌ្ឍនវានុវត្តន៍បច្ចេកវិទ្យាឌីជីថលសម្រាប់វិស័យអធិការកិច្ច (២)ជំរុញការកសាងប្រព័ន្ធស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល តាមរយៈការរៀបចំផែនការមេ យន្តការនៃការលើកទឹកចិត្តនិងជំរុញភាពជាដៃគូរវាងគ្រឹះស្ថានស្រាវជ្រាវ គ្រឹះស្ថានឧត្តមសិក្សា និងបណ្ដាក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលដើម្បីលើកកម្ពស់សកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល (៣)ជំរុញឱ្យមានការចូលរួមប្រកួតប្រជែងពីសំណាក់សាធារណជន ស្តីពីនវានុវត្តន៍បច្ចេកវិទ្យាឌីជីថលសម្រាប់វិស័យអធិការកិច្ច។

## ជំពូកទី៥
## ផែនការសកម្មភាពឆ្នាំ២០២៥-២០២៨

| ល.រ | សកម្មភាព | សូចនាករ | ឆ្នាំអនុវត្ត | | | | ស្ថាប័ន អង្គភាព ទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|
| | | | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | |
| I. | **ពង្រឹងការងាររអធិការកិច្ច** | | | | | | |
| | **ក- គោលដៅយុទ្ធសាស្ត្រទី១៖ ពង្រឹងប្រសិទ្ធភាពនៃការចុះធ្វើអធិការកិច្ច** | | | | | | |
| | ➢ **វិធានការគន្លឹះទី១៖ ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីអធិការកិច្ច** | | | | | | |
| 1 | រៀបចំកិច្ចប្រជុំផ្ទៃក្នុងជាប្រចាំ | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- នាយកដ្ឋានជំនាញ |
| 2 | ត្រួតពិនិត្យវាយតម្លៃពីសកម្មភាពរបស់មន្ត្រី | ការអនុវត្តសម្រេចបាននូវលទ្ធផលដែលបានកំណត់ប្រកបដោយប្រសិទ្ធភាព | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានី ខេត្ត |
| | ➢ **វិធានការគន្លឹះទី២៖ ពង្រឹងនីតិវិធីនៃការធ្វើអធិការកិច្ច** | | | | | | |
| 1 | រៀបចំគោលការណ៍ របៀបរបបការងារអធិការកិច្ច | - ឯកសារស្តីពីគោលការណ៍ របៀបរបបការងារអធិការកិច្ច<br>- ចំនួនលើកនៃកិច្ចប្រជុំ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 2 | ប្រជុំតាមដាន ត្រួតពិនិត្យវាយតម្លៃផ្ទៃក្នុង | - ចំនួនលើកនៃកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| | ➢ **វិធានការគន្លឹះទី៣៖ ពង្រឹងការរៀបចំផែនការសកម្មភាពមុនប្រតិបត្តិការអធិការកិច្ច** | | | | | | |
| 1 | ចុះក្តាប់សភាពការណ៍ដោយមានការចូលរួមពីមន្ទីរអធិការកិច្ចរាជធានី ខេត្ត | - ចំនួនលើកនៃការចុះក្តាប់សភាពការណ៍<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានី ខេត្ត |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 2 | ប្រមូល ចងក្រងឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារអធិការកិច្ច | - ចំនួនច្បាប់និងលិខិតបទដ្ឋាន | ✓ | ✓ | ✓ | ✓ | - អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 3 | វាយតម្លៃលើទិន្នន័យដែលប្រមូលបានពីការចុះក្តាប់សភាពការណ៍ | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានី ខេត្ត |
| **ខ- គោលដៅយុទ្ធសាស្ត្រទី២៖ ពង្រឹងទំនាក់ទំនងនិងសហការជាមួយអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ ពង្រឹងកិច្ចសហការជាមួយអង្គភាពវេងអធិការកិច្ច** | | | | | | | |
| 1 | រៀបចំយន្តការទំនាក់ទំនងជាមួយអង្គភាពវេងអធិការកិច្ចឱ្យកាន់តែមានប្រសិទ្ធភាព | - យន្តការទំនាក់ទំនងទាំងផ្លូវការ និងក្រៅផ្លូវការ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 2 | រៀបចំកិច្ចប្រជុំប្រចាំត្រីមាស និងឆ្នាំជាមួយអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន | - ចំនួនលើកនៃកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| ➢ **វិធានការគន្លឹះទី២៖ ពង្រឹងសុខដុមនីយកម្មក្នុងវិស័យអធិការកិច្ច តាមរយៈការពង្រឹងកិច្ចសហការជាមួយអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន** | | | | | | | |
| 1 | រៀបចំគោលនយោបាយ នីតិវិធី គំរូស្តង់ដារអធិការកិច្ចរួម និងផ្តល់ការណែនាំជំនាញបច្ចេកទេសដល់អង្គភាពអធិការកិច្ចតាមក្រសួងស្ថាប័ន | ឯកសារគោលនយោបាយ នីតិវិធី គំរូស្តង់ដារ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច |
| 2 | បណ្តុះបណ្តាលនិងចែករំលែកបទពិសោធ | - ចំនួនលើកនៃការបណ្តុះបណ្តាល<br>- ចំនួនលើកនៃទស្សនកិច្ចសិក្សា | ✓ | ✓ | ✓ | ✓ | - អគ្គនាយកដ្ឋានអធិការកិច្ច<br>- វិទ្យាស្ថានជាតិអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 3 | ចងក្រងឯកសារសកម្មភាពនិងលទ្ធផលការងារក្នុងវិស័យអធិការកិច្ច | ឯកសារសកម្មភាពនិងលទ្ធផលការងារ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| **គ- គោលដៅយុទ្ធសាស្ត្រទី៣៖ ពង្រឹងប្រសិទ្ធភាពនៃការចេញសេចក្ដីជូនដំណឹងកែលម្អ និងតាមដានការអនុវត្តសេចក្ដីជូនដំណឹង និងពង្រឹងការអនុវត្តសេចក្ដីសម្រេចស្ដីពីលទ្ធផលអធិការកិច្ច** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ តាមដាន ត្រួតពិនិត្យ និងក្រើនរំលឹកការអនុវត្តសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលស្ដីពីលទ្ធផលអធិការកិច្ច** | | | | | | | |
| 3 | រៀបចំកិច្ចប្រជុំពិនិត្យវាយតម្លៃលើការអនុវត្តសេចក្ដីសម្រេចស្ដីពីលទ្ធផលអធិការកិច្ច | - ចំនួនលើកនៃកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 4 | ក្រើនរំលឹកដល់ក្រសួង ស្ថាប័ន អង្គភាពអនុវត្តសេចក្ដីសម្រេចស្ដីពីលទ្ធផលអធិការកិច្ច | ចំនួនក្រសួង ស្ថាប័ន អង្គភាព | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| 5 | រៀបចំរបាយការណ៍ស្ដីពីការអនុវត្តសេចក្ដីសម្រេច | ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| ➢ **វិធានការគន្លឹះទី២៖ តាមដាន ត្រួតពិនិត្យ និងក្រើនរំលឹកការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញដល់ក្រសួង ស្ថាប័ន អង្គភាពរងអធិការកិច្ច** | | | | | | | |
| 1 | រៀបចំកិច្ចប្រជុំពិនិត្យវាយតម្លៃលើការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញ | - ចំនួនលើកនៃកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 2 | ក្រើនរំលឹកដល់ក្រសួង ស្ថាប័ន អង្គភាពអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញ | ចំនួនក្រសួង ស្ថាប័ន អង្គភាព | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| 3 | រៀបចំរបាយការណ៍ស្ដីពីការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញ | ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **គ- គោលដៅយុទ្ធសាស្ត្រទី៣៖ ធានានិរន្តរភាពការងារក្នុងវិស័យអធិការកិច្ច** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ ពង្រឹងសុខដុមនីយកម្មក្នុងវិស័យអធិការកិច្ច** | | | | | | | |
| 4 | រៀបចំគោលនយោបាយ នីតិវិធី គំរូស្តង់ដារ អធិការកិច្ចរួម និងផ្តល់ការណែនាំជំនាញបច្ចេកទេសដល់អង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន | ឯកសារគោលនយោបាយ នីតិវិធី គំរូស្តង់ដារ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច |
| 5 | បណ្តុះបណ្តាលនិងចែករំលែកបទពិសោធ | - ចំនួនលើកនៃការបណ្តុះបណ្តាល<br>- ចំនួនលើកនៃទស្សនកិច្ចសិក្សា | ✓ | ✓ | ✓ | ✓ | - អគ្គនាយកដ្ឋានអធិការកិច្ច<br>- វិទ្យាស្ថានជាតិអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 6 | ចងក្រងឯកសារសកម្មភាពនិងលទ្ធផលការងារក្នុងវិស័យអធិការកិច្ច | ឯកសារសកម្មភាពនិងលទ្ធផលការងារ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| ➢ **វិធានការគន្លឹះទី២៖ ពង្រឹងទំនាក់ទំនងជាមួយអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន** | | | | | | | |
| 1 | កិច្ចប្រជុំប្រចាំត្រីមាស និងឆ្នាំ ជាមួយអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន | ចំនួនលើកនៃកិច្ចប្រជុំ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 2 | សហការចុះធ្វើអធិការកិច្ចរួមគ្នា | ចំនួនលើកនៃកិច្ចសហការ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 3 | បូកសរុបរបាយការណ៍លទ្ធផលអធិការកិច្ចរបស់អង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័ន ជូនប្រមុខរាជរដ្ឋាភិបាល | ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ឃ- គោលដៅយុទ្ធសាស្ត្រទី៤៖ កំណត់ឱ្យបានច្បាស់ពីសមត្ថកិច្ច មុខងារភារកិច្ច និងឋានានុក្រមអធិការកិច្ច** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ កំណត់ឱ្យបានច្បាស់ពីសមត្ថកិច្ច មុខងារ និងភារកិច្ចអធិការកិច្ច** | | | | | | | |
| 1 | រៀបចំបញ្ចូលការបែងចែកសមត្ថកិច្ច មុខងារភារកិច្ចអធិការកិច្ចក្នុងលិខិតបទដ្ឋានគតិយុត្ត | - ចំនួនលិខិតបទដ្ឋានគតិយុត្ត<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 2 | ដឹកនាំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| ➢ **វិធានការគន្លឹះទី១៖ កំណត់ឋានានុក្រមអធិការកិច្ចឱ្យបានច្បាស់លាស់** | | | | | | | |
| 1 | រៀបចំកំណត់ឋានានុក្រមអធិការកិច្ចក្នុងលិខិតបទដ្ឋានគតិយុត្ត | - ចំនួនលិខិតបទដ្ឋានគតិយុត្ត<br>- ចំនួនរបាយការណ៍ | ✓ | | | | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 2 | ដឹកនាំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ | ✓ | | | | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| **ង- គោលដៅយុទ្ធសាស្ត្រទី៥៖ ជំរុញបង្កើតយន្តការតាមដាន ត្រួតពិនិត្យលើរបាយការណ៍លទ្ធផលការងារអធិការកិច្ច និងយន្តការតាមដានត្រួតពិនិត្យលើមុខងារអធិការកិច្ចរបស់ក្រសួង ស្ថាប័ន** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ បង្កើតយន្តការតាមដាន ត្រួតពិនិត្យលើរបាយការណ៍លទ្ធផលការងារអធិការកិច្ច** | | | | | | | |
| 1 | ជំរុញបង្កើតយន្តការតាមដាន ត្រួតពិនិត្យលើរបាយការណ៍ដោយមានសូចនាករ និងប្រព័ន្ធវិនិច្ឆ័យច្បាស់លាស់ដែលអាចវាស់វែងបាន | - ទស្សនទាននៃយន្តការតាមដាន ត្រួតពិនិត្យ<br>- បង្កើតក្រុមការងារតាមដាន ត្រួតពិនិត្យ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | | | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 2 | ដឹកនាំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | | | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| ➢ **វិធានការគន្លឹះទី២៖ យន្តការតាមដានត្រួតពិនិត្យលើមុខងារអធិការកិច្ចរបស់ក្រសួង ស្ថាប័ន** | | | | | | | |
| 1 | ជំរុញបង្កើតយន្តការតាមដាន ត្រួតពិនិត្យលើមុខងារអធិការកិច្ចរបស់ក្រសួង ស្ថាប័ន | - ទស្សនទាននៃយន្តការតាមដាន ត្រួតពិនិត្យ<br>- បង្កើតក្រុមការងារតាមដាន ត្រួតពិនិត្យ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | | | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 2 | ដឹកនាំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | | | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| **ច- គោលដៅយុទ្ធសាស្ត្រទី៦៖ ជំរុញរៀបចំផែនការអធិការកិច្ចរួមប្រចាំឆ្នាំនីមួយៗ** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ ជំរុញកិច្ចសហការពីអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័នលើការរៀបចំផែនការអធិការកិច្ចរួម** | | | | | | | |
| 1 | ជំរុញការចូលរួមពីអង្គភាពអធិការកិច្ចតាមក្រសួង ស្ថាប័នក្នុងការរៀបចំផែនការអធិការកិច្ចរួមប្រចាំឆ្នាំ | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 2 | ដឹកនាំកិច្ចជាមួយភាគីពាក់ព័ន្ធ | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| ➢ **វិធានការគន្លឹះទី២៖ បង្កើតយន្តការដើម្បីរៀបចំផែនការអធិការកិច្ចប្រចាំឆ្នាំរួម** | | | | | | | |
| 1 | បង្កើតយន្តការរៀបចំផែនការអធិការកិច្ចរួមរបស់ក្រសួង ស្ថាប័ន | - បង្កើតក្រុមការងាររៀបចំផែនការអធិការកិច្ចរួម<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 2 | ដឹកនាំកិច្ចជាមួយភាគីពាក់ព័ន្ធ | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| II. | **ពង្រឹងការងារដោះស្រាយបណ្តឹង** | | | | | | |
| | **ក- គោលដៅយុទ្ធសាស្ត្រទី១៖ ពង្រឹងប្រសិទ្ធភាពនៃការទទួលបណ្តឹង** | | | | | | |
| | ➢ **វិធានការគន្លឹះទី១៖ ពង្រឹងយន្តការទទួលពាក្យបណ្តឹង** | | | | | | |
| 1 | ការទទួលពាក្យបណ្តឹងដោយផ្ទាល់ ឬនៅតាមវេទិកាសាធារណៈ | ចំនួនពាក្យបណ្តឹង | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានី ខេត្ត |
| 2 | ការទទួលពាក្យបណ្តឹងតាមរយៈប្រអប់សំបុត្រ | ចំនួនពាក្យបណ្តឹង | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 3 | ការទទួលពាក្យបណ្តឹងតាមរយៈអនឡាញ | - ភាគរយនៃពាក្យបណ្តឹងដែលបានដាក់និងតាមដានតាមប្រព័ន្ធអនឡាញប្រចាំឆ្នាំ<br>- ភាគរយនៃពាក្យបណ្តឹងដែលបានឆ្លើយតបចាត់បញ្ជូន និងដោះស្រាយប្រចាំឆ្នាំ<br>- កម្រិតនៃការពេញចិត្តចំពោះយន្តការបណ្តឹងអនឡាញដែលត្រូវបានវាស់វែងដោយមតិអ្នកប្រើប្រាស់ ឬការស្ទង់មតិ<br>- ចំនួននៃការកែលម្អ ឬការធ្វើបច្ចុប្បន្នភាពដែលបានធ្វើឡើងចំពោះប្រព័ន្ធបណ្តឹងអនឡាញ ដោយផ្អែកលើមតិកែលម្អរបស់អ្នកប្រើប្រាស់ ឬការត្រួតពិនិត្យផ្ទៃក្នុង | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 4 | ការទទួលពាក្យបណ្តឹងតាមរយៈបច្ចេកវិទ្យាព័ត៌មាន សារព័ត៌មាន | ចំនួនពាក្យបណ្តឹង | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 5 | ការទទួលពាក្យបណ្ដឹងពីក្រសួង ស្ថាប័ន អង្គភាពនានា | ចំនួនពាក្យបណ្ដឹង | ✓ | ✓ | ✓ | ✓ | ក្រសួងអធិការកិច្ច |
| ➢ **វិធានការគន្លឹះទី២៖ ផ្សព្វផ្សាយអំពីយន្តការនៃការទទួលនិងដោះស្រាយបណ្ដឹងរបស់ក្រសួងអធិការកិច្ច** | | | | | | | |
| 1 | បញ្ជ្រាបការផ្សព្វផ្សាយយន្តការទទួលពិនិត្យនិងដោះស្រាយបណ្ដឹងតាមរយៈវេទិកាសាធារណៈ កិច្ចប្រជុំនានា ខិត្តប័ណ្ណ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | - ចំនួនលើកនៃការផ្សព្វផ្សាយ<br>- ចំនួនខិត្តប័ណ្ណដែលបានផ្សព្វផ្សាយ<br>- ចំនួនអ្នកចូលទស្សនា | ✓ | ✓ | ✓ | ✓ | គ្រប់អង្គភាពចំណុះក្រសួង |
| 2 | ផ្សព្វផ្សាយអំពីលទ្ធផលនៃការដោះស្រាយបណ្ដឹង | - ចំនួនលើកនៃការផ្សព្វផ្សាយ<br>- ចំនួនអ្នកចូលទស្សនា | ✓ | ✓ | ✓ | ✓ | ក្រសួងអធិការកិច្ច |
| ➢ **វិធានការគន្លឹះទី៣៖ ពង្រឹងការពិនិត្យសមត្ថកិច្ចបណ្ដឹង** | | | | | | | |
| 1 | ពង្រឹងសមត្ថភាពមន្ត្រីក្នុងការពិនិត្យកម្មវត្ថុបណ្ដឹងនិងកំណត់សមត្ថកិច្ចដោះស្រាយបណ្ដឹង | ចំនួនកិច្ចប្រជុំ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានជំនាញ<br>- ថ្នាក់ដឹកនាំ |
| 2 | ពង្រឹងយន្តការនៃការត្រួតពិនិត្យនិងវាយតម្លៃការងារ | ចំនួនកិច្ចប្រជុំ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានជំនាញ<br>- ថ្នាក់ដឹកនាំ |
| ➢ **វិធានការគន្លឹះទី៤៖ រៀបចំនិងថែទាំកន្លែងទទួលបណ្ដឹង** | | | | | | | |
| 1 | រៀបចំនិងថែទាំទីតាំងទទួលពាក្យបណ្ដឹងដោយផ្ទាល់នៅទីស្ដីការក្រសួង | - ចំនួនទីតាំង<br>- ចំនួនលើកនៃការថែទាំ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានជំនាញ<br>- ថ្នាក់ដឹកនាំ |
| 2 | រៀបចំនិងថែទាំទីតាំងទទួលពាក្យបណ្ដឹងដោយផ្ទាល់នៅមន្ទីររាជធានី ខេត្ត | - ចំនួនទីតាំង<br>- ចំនួនលើកនៃការថែទាំ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានជំនាញ<br>- ថ្នាក់ដឹកនាំ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ខ- គោលដៅយុទ្ធសាស្ត្រទី២៖ ពង្រឹងប្រសិទ្ធភាពនៃការដោះស្រាយបណ្តឹង** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ ពង្រឹងនីតិវិធីនៃការដោះស្រាយបណ្តឹង** | | | | | | | |
| 1 | រៀបចំគោលការណ៍ របៀបរបបការងារនៃការដោះស្រាយបណ្តឹង | - ឯកសារស្តីពីគោលការណ៍ របៀបរបបនៃការដោះស្រាយបណ្តឹង<br>- ចំនួនលើកនៃកិច្ចប្រជុំ | ✓ | ✓ | | | នាយកដ្ឋានជំនាញ |
| 2 | ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីដោះស្រាយបណ្តឹង | ចំនួនលើកនៃកិច្ចប្រជុំ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 3 | ពង្រឹងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ | ចំនួនអ្នកចូលរួមសហការ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 4 | ប្រជុំតាមដាន ត្រួតពិនិត្យ វាយតម្លៃផ្ទៃក្នុង | ចំនួនលើកនៃកិច្ចប្រជុំ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| ➢ **វិធានការគន្លឹះទី២៖ ពង្រឹងយន្តការតាមដានការអនុវត្តសេចក្តីសម្រេចលើលទ្ធផលនៃការដោះស្រាយបណ្តឹង** | | | | | | | |
| 1 | តាមដានលទ្ធផលនៃការដោះស្រាយបណ្តឹងដែលបានបញ្ជូនទៅសមត្ថកិច្ចផ្សេង | - ចំនួនលិខិតដែលបានបញ្ជូន<br>- ចំនួនលើកនៃការចុះតាមដានលទ្ធផលនៃការដោះស្រាយបណ្តឹង | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 2 | តាមដានការអនុវត្តសេចក្តីសម្រេចស្តីពីលទ្ធផលនៃការដោះស្រាយបណ្តឹងរបស់ក្រសួងអធិការកិច្ច និងរបស់រាជរដ្ឋាភិបាល | ចំនួនលើកនៃការចុះតាមដានសេចក្តីសម្រេច | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| III. **ពង្រឹងការងារតាមដានការអនុវត្តច្បាប់** | | | | | | | |
| **ក- គោលដៅយុទ្ធសាស្ត្រទី១៖ ពង្រឹងការងារតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ រៀបចំនីតិវិធីប្រតិបត្តិការការងារតាមដានការអនុវត្តច្បាប់** | | | | | | | |
| 1 | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ផ្ទៃក្នុង | - ចំនួនកិច្ចប្រជុំពិភាក្សាក្រុមការងាររៀបចំនីតិវិធីប្រតិបត្តិការការងារតាមដានការអនុវត្តច្បាប់ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | - ចំនួនសមាសភាពក្រុមការងារដែលបាន ចូលរួមប្រជុំ | | | | | |
| 2 | សុំការសម្រេចពីប្រធានស្ថាប័នលើសេចក្តីព្រាងនីតិវិធីប្រតិបត្តិការការងារតាមដានការអនុវត្តច្បាប់ | ចំនួនលិខិតបទដ្ឋានគតិយុត្តដែលបានស្នើសុំសម្រេចពីប្រធានស្ថាប័ន | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| ➢ **វិធានការគន្លឹះទី២៖ ពង្រឹងការរៀបចំផែនការចុះតាមដានការអនុវត្តច្បាប់** | | | | | | | |
| 1 | ផ្ញើបញ្ជីសម្រង់រាល់ច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទបញ្ជា អនុសាសន៍ សេចក្តីសម្រេចផ្សេងៗ របស់ប្រមុខរាជរដ្ឋាភិបាល | - ចំនួនច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទបញ្ជា អនុសាសន៍ និងសេចក្តីសម្រេចផ្សេងៗ របស់ប្រមុខរាជរដ្ឋាភិបាល | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 2 | ចុះក្តាប់សភាពការណ៍ តាមរយៈការប្រមូលព័ត៌មានពីគ្រប់មជ្ឈដ្ឋាន និងគ្រប់មធ្យោបាយលើចំណុចអសកម្មនានា ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ដោយមានការចូលរួមពីមន្ទីរអធិការកិច្ចរាជធានី ខេត្ត | - ចំនួនលើកនៃការចុះក្តាប់សភាពការណ៍ជាក់ស្តែង<br>- ចំនួនព័ត៌មានអសកម្ម ពាក់ព័ន្ធការអនុវត្តច្បាប់ដែលបានប្រមូលគ្រប់មជ្ឈដ្ឋាន និងគ្រប់មធ្យោបាយ<br>- ចំនួនរបាយការណ៍ ស្តីពីការចុះក្តាប់សភាពការណ៍ពីបណ្តាមន្ទីរអធិការកិច្ចរាជធានី-ខេត្ត | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 3 | វាយតម្លៃលើទិន្នន័យដែលប្រមូលបានពីការចុះក្តាប់សភាពការណ៍ | - ចំនួនកិច្ចប្រជុំពិភាក្សាវាយតម្លៃលើទិន្នន័យដែលបានប្រមូល<br>- ចំនួនទិន្នន័យ ឬខ្លឹមសារដែលបានវាយតម្លៃ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ➢ **វិធានការគន្លឹះទី៣៖ ជំរុញប្រសិទ្ធភាពការងារតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត** | | | | | | | |
| 1 | ទំនាក់ទំនង សម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ | - ចំនួនលើកដែលបានធ្វើការសម្របសម្រួល<br>- ចំនួនក្រសួង ស្ថាប័ន និងអង្គភាព ដែលបានធ្វើការសម្របសម្រួល | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 2 | ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ | - ចំនួនលិខិតបទដ្ឋានគតិយុត្តធ្វើការទំនាក់-ទំនង<br>- លិខិតបទដ្ឋានគតិយុត្តដែលបានទទួល | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 3 | ពង្រឹងកិច្ចសហការជាមួយស្ថាប័នវេងការតាមដានការអនុវត្តច្បាប់ | - សេចក្តីជូនដំណឹងដល់ក្រសួង ស្ថាប័ន និងអង្គភាព<br>- ចំនួនក្រសួង ស្ថាប័ន និងអង្គភាពវេងការតាមដានការអនុវត្តច្បាប់<br>- ចំនួនក្រសួង ស្ថាប័ន និងអង្គភាពវេងការតាមដានការអនុវត្តច្បាប់ដែលផ្តល់កិច្ចសហការ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 4 | ត្រួតពិនិត្យវាយតម្លៃលើលទ្ធផលនៃការចុះតាមដានការអនុវត្តច្បាប់ | - ចំនួនកិច្ចប្រជុំវាយតម្លៃលទ្ធផលនៃការចុះតាមដានការអនុវត្តច្បាប់<br>- កម្រងរបាយការណ៍លទ្ធផលត្រូវបានរៀបចំ<br>- របាយការណ៍លទ្ធផលនៃការចុះតាមដានការអនុវត្តច្បាប់ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- នាយកដ្ឋានជំនាញ |
| ➢ **វិធានការគន្លឹះទី៤៖ ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីតាមដានការអនុវត្តច្បាប់** | | | | | | | |
| 1 | រៀបចំកិច្ចប្រជុំផ្ទៃក្នុងជាប្រចាំ | - ចំនួនកិច្ចប្រជុំពិភាក្សាលើក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីតាមដានការអនុវត្តច្បាប់ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | - ចំនួនមន្ត្រីតាមដានការអនុវត្តច្បាប់បានបណ្តុះបណ្តាលនិងយល់ដឹងពីក្រមសីលធម៌វិជ្ជាជីវៈ | | | | | |
| 2 | ត្រួតពិនិត្យវាយតម្លៃពីសកម្មភាពរបស់មន្ត្រី | - ចំនួនកិច្ចប្រជុំវាយតម្លៃរបស់ក្រុមការងារ<br>- សកម្មភាពបំពេញការងាររបស់មន្ត្រី<br>- សមត្ថភាពការងារធ្វើការរបស់មន្ត្រី<br>- សីលធម៌និងឥរិយាបទក្នុងការអនុវត្តការងារ<br>- វិធានការត្រូវបានអនុវត្តចំពោះមន្ត្រី | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| **ខ- គោលដៅយុទ្ធសាស្ត្រទី២៖ ពង្រឹងប្រសិទ្ធភាពនៃការចេញសេចក្តីជូនដំណឹងកែលម្អ និងតាមដានការអនុវត្តសេចក្តីជូនដំណឹង និងពង្រឹងការអនុវត្តសេចក្តីសម្រេចស្តីពីលទ្ធផលនៃការងារតាមដានការអនុវត្តច្បាប់** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ តាមដាន ត្រួតពិនិត្យ និងក្រើនរំលឹកការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីលទ្ធផលនៃការងារតាមដានការអនុវត្តច្បាប់** | | | | | | | |
| 1 | រៀបចំកិច្ចប្រជុំពិនិត្យវាយតម្លៃលើការអនុវត្តសេចក្តីសម្រេចស្តីពីការតាមដានការអនុវត្តច្បាប់ | - ចំនួនកិច្ចប្រជុំពិនិត្យវាយតម្លៃលើការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីលទ្ធផលនៃការតាមដានការអនុវត្តច្បាប់<br>- ចំនួនសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីលទ្ធផល នៃការតាមដានការអនុវត្តច្បាប់ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 2 | ក្រើនរំលឹកដល់អង្គភាពអនុវត្តសេចក្តីសម្រេចស្តីពីការតាមដានការអនុវត្តច្បាប់ | - លិខិតជូនដំណឹងដល់អង្គភាពអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីលទ្ធផល នៃការតាមដានការអនុវត្តច្បាប់<br>- ចំនួនលើកក្នុងការក្រើនរំលឹកដល់អង្គភាពអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីលទ្ធផលនៃការតាមដានការអនុវត្តច្បាប់ | ✓ | ✓ | ✓ | ✓ | ក្រសួងអធិការកិច្ច |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 3 | រៀបចំរបាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេច | របាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីលទ្ធផលនៃការតាមដានការអនុវត្តច្បាប់ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| ➢ **វិធានការគន្លឹះទី២៖ តាមដាន ត្រួតពិនិត្យ និងក្រើនរំលឹកការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញដល់ក្រសួង ស្ថាប័ន និងអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** | | | | | | | |
| 1 | រៀបចំកិច្ចប្រជុំពិនិត្យវាយតម្លៃលើការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញ | - ចំនួនកិច្ចប្រជុំពិនិត្យវាយតម្លៃលើការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញដល់ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- ចំនួនវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញដល់ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 2 | ក្រើនរំលឹកដល់អង្គភាពអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញ | - លិខិតជូនដំណឹងដល់អង្គភាពអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញដល់ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- ចំនួនលើកក្នុងការក្រើនរំលឹកដល់អង្គភាពអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញដល់ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | ក្រសួងអធិការកិច្ច |
| 3 | រៀបចំរបាយការណ៍ស្តីពីការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញ | - របាយការណ៍ ស្តីពីការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញដល់ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ➢ **វិធានការគន្លឹះទី៣៖ ពង្រឹងប្រសិទ្ធភាពនៃការចេញសេចក្តីជូនដំណឹងកែលម្អ** | | | | | | |
| 1 | រៀបចំកិច្ចប្រជុំពិនិត្យវាយតម្លៃលើការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញ | - ចំនួនកិច្ចប្រជុំពិនិត្យវាយតម្លៃលើការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញដល់ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- ចំនួនវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញដល់ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 2 | ក្រើនរំលឹកដល់អង្គភាពអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញ | - លិខិតជូនដំណឹងដល់អង្គភាពអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញដល់ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- ចំនួនលើកក្នុងការក្រើនរំលឹកដល់អង្គភាពអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញដល់ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | ក្រសួងអធិការកិច្ច |
| 3 | រៀបចំរបាយការណ៍ស្តីពីការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញ | - របាយការណ៍ ស្តីពីការអនុវត្តវិធានការដែលក្រសួងអធិការកិច្ចបានដាក់ចេញដល់ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| | **គ- គោលដៅយុទ្ធសាស្ត្រទី៣៖ ជំរុញបង្កើតយន្តការតាមដាន ត្រួតពិនិត្យលើរបាយការណ៍លទ្ធផលការងារតាមដានការអនុវត្តច្បាប់** | | | | | | |
| 1 | ជំរុញបង្កើតយន្តការតាមដាន ត្រួតពិនិត្យលើរបាយការណ៍តាមដានការអនុវត្តច្បាប់ | បង្កើតក្រុមការងារតាមដាន ត្រួតពិនិត្យ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | | | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 2 | ដឹកនាំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ | ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | | | - ថ្នាក់ដឹកនាំ<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>នាយកដ្ឋានជំនាញ |
| **IV.** | **ពង្រឹងការងារផ្សព្វផ្សាយច្បាប់និងទេសិកាសាធារណៈ** | | | | | | |
| | **ក- គោលដៅយុទ្ធសាស្ត្រទី១៖ ពង្រឹងប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយច្បាប់** | | | | | | |
| | ➢ **វិធានការគន្លឹះទី១៖ ទំនាក់ទំនង និងកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ** | | | | | | |
| 1 | ទំនាក់ទំនង និងកិច្ចសហការជាមួយបណ្តាក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធ | ចំនួនក្រសួង ស្ថាប័ន និងអង្គភាពដែលបានទំនាក់ទំនងនិងសហការ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 2 | ទំនាក់ទំនង និងកិច្ចសហការជាមួយរដ្ឋបាលរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ | ចំនួនរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលទំនាក់ទំនង និងសហការជាមួយ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 3 | ទំនាក់ទំនង និងកិច្ចសហការជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ | ចំនួនដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិដែលបានទំនាក់ទំនងនិងសហការ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- នាយកដ្ឋានជំនាញ |
| 4 | រៀបចំគម្រោងស្នើសុំមូលនិធិគាំទ្រពីដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ | ចំនួនគម្រោងដែលបានស្នើសុំពីដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- នាយកដ្ឋានជំនាញ |
| | ➢ **វិធានការគន្លឹះទី២៖ ជំរុញការអប់រំផ្សព្វផ្សាយច្បាប់** | | | | | | |
| 1 | សិក្សាស្រាវជ្រាវ ចងក្រងឯកសារច្បាប់និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អប់រំផ្សព្វផ្សាយ | ចំនួនច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលបានសិក្សានិងចងក្រង | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 2 | រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត | ចំនួននៃការរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយច្បាប់ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 3 | ផលិត និងថតស្ប៉តការអប់រំផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត | ចំនួនស្ប៉តដែលបានផលិតនិងចាក់ផ្សាយ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានជំនាញ<br>- ស្ថានីយទូរទស្សន៍អប្សរា |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 4 | ផលិត និងចាក់ផ្សាយវីដេអូសំណួរ ចម្លើយច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត | ចំនួនវីដេអូដែលបានផលិតនិងចាក់ផ្សាយ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានជំនាញ<br>- ស្ថានីយទូរទស្សន៍អប្សរា |
| 5 | យុទ្ធនាការអប់រំផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត | - ចំនួនយុទ្ធនាការអប់រំផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត<br>- ប្រជាពលរដ្ឋចំនួន២០ម៉ឺននាក់ទទួលបានការយល់ដឹងពីច្បាប់ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| **ខ- គោលដៅយុទ្ធសាស្ត្រទី២៖ ពង្រឹងប្រសិទ្ធភាពនៃការរៀបចំវេទិកាសាធារណៈ** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ ទំនាក់ទំនង និងកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ** | | | | | | | |
| 1 | ទំនាក់ទំនង និងកិច្ចសហការជាមួយបណ្ដាក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធ | ចំនួនក្រសួង ស្ថាប័ន និងអង្គភាពដែលបានទំនាក់ទំនងនិងសហការ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 2 | ទំនាក់ទំនង និងកិច្ចសហការជាមួយរដ្ឋបាលរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ | ចំនួនរដ្ឋបាលរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលបានទំនាក់ទំនង និងសហការ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- នាយកដ្ឋានជំនាញ |
| 3 | ទំនាក់ទំនង និងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ | ចំនួនដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិដែលបានទំនាក់ទំនងនិងសហការ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំ<br>- នាយកដ្ឋានជំនាញ |
| 4 | រៀបចំគម្រោងស្នើសុំមូលនិធិគាំទ្រពីដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ | ចំនួនគម្រោងដែលបានស្នើសុំពីដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| ➢ **វិធានការគន្លឹះទី២៖ ជំរុញការរៀបចំវេទិកាសាធារណៈ** | | | | | | | |
| 1 | រៀបចំវេទិកាសាធារណៈនៅតាមបណ្ដារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ | - ចំនួននៃការរៀបចំវេទិកាសាធារណៈ<br>- ចំនួននៃអ្នកចូលរួមវេទិកាសាធារណៈ<br>- ចំនួននៃសំណូមពររបស់ប្រជាពលរដ្ឋ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានជំនាញ<br>- ក្រសួង ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 2 | ដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋដែលបានលើកឡើងក្នុងកម្មវិធីវេទិកាសាធារណៈ | - ចំនួនសំណូមពរដែលបានដោះស្រាយ<br>- ចំនួនសំណូមពរដែលមិនទាន់បានដោះស្រាយ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានជំនាញ<br>- សមត្ថកិច្ចជំនាញ<br>- អាជ្ញាធរដែនដី |
| 3 | រៀបចំរបាយការណ៍លទ្ធផលនៃការដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋ | លទ្ធផលនៃការដោះស្រាយសំណូមពរ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 4 | តាមដានសំណូមពររបស់ប្រជាពលរដ្ឋដែលបានទទួលយកទៅដោះស្រាយ | ចំនួនសំណូមពរដែលមិនបានដោះស្រាយ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| **គ- គោលដៅយុទ្ធសាស្ត្រទី៣៖ ពង្រឹងប្រសិទ្ធភាពនៃការវិភាគតាមដានត្រួតពិនិត្យ វាយតម្លៃ និងស្ទង់មតិក្នុងដំណើរការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ ការស្ទង់មតិពីកម្រិតយល់ដឹងរបស់ប្រជាពលរដ្ឋអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត** | | | | | | | |
| 1 | រៀបចំកម្មវិធីស្ទង់មតិអំពីការយល់ដឹងច្បាប់របស់ប្រជាពលរដ្ឋមុន និងក្រោយការអប់រំផ្សព្វផ្សាយច្បាប់ | ចំនួនកម្មវិធីនៃការចុះស្ទង់មតិមុននិងក្រោយការផ្សព្វផ្សាយច្បាប់ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 2 | រៀបចំវិធីសាស្ត្រស្ទង់មតិនិងចុះប្រមូលទិន្នន័យ (សម្ភាសន៍) | ចំនួនប្រជាពលរដ្ឋដែលបានសម្ភាសន៍ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 3 | ធ្វើការវិភាគទិន្នន័យនិងធ្វើរបាយការណ៍ | របាយការណ៍ស្ដីពីលទ្ធផលនៃការស្ទង់មតិ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| ➢ **វិធានការគន្លឹះទី២៖ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពក្រោយបញ្ចប់កម្មវិធីផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ** | | | | | | | |
| 1 | រៀបចំបញ្ជីសំណួរនិងវាយតម្លៃប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយច្បាប់ពីអ្នកចូលរួម | ភាគរយនៃការពេញចិត្តចំពោះការផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 2 | សម្ភាសន៍អ្នកចូលរួមការផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ | ចំនួនអ្នកចូលរួមការផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈដែលបានសម្ភាសន៍ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 3 | ធ្វើរបាយការណ៍ស្តីពីការវាយតម្លៃប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ | ភាគរយនៃការពេញចិត្ត និងមិនពេញចិត្តនៃការផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| **ឃ- គោលដៅយុទ្ធសាស្ត្រទី៤៖ ពង្រឹងការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយលើមូលដ្ឋានក្នុងការកំណត់លិខិតបទដ្ឋានគតិយុត្ត ប្រធានបទ និងគោលដៅអាទិភាពក្នុងការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ** | | | | | | | |
| 1 | ពង្រឹងមូលដ្ឋាន និងនីតិវិធីក្នុងការជ្រើសរើសលិខិតបទដ្ឋានគតិយុត្ត ប្រធានបទ និងគោលដៅអាទិភាពក្នុងការអប់រំផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ | ឯកសារគោលការណ៍ណែនាំ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 2 | ស្រាវជ្រាវ និងប្រមូលព័ត៌មាន ដើម្បីជាមូលដ្ឋានក្នុងការកំណត់លិខិតបទដ្ឋានគតិយុត្ត ប្រធានបទ និងគោលដៅអាទិភាពក្នុងការអប់រំផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ | ប្រភព និងប្រភេទព័ត៌មាននិងស្ថិតិដែលប្រមូលបាន | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| **ង- គោលដៅយុទ្ធសាស្ត្រទី៥៖ ជំរុញការផ្សព្វផ្សាយ និងពន្យល់អំពីសារៈសំខាន់នៃចំណេះដឹងអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តឱ្យបានទូលំទូលាយ** | | | | | | | |
| 1 | ផ្សព្វផ្សាយ និងពន្យល់អំពីសារៈសំខាន់នៃចំណេះដឹងអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តតាមគ្រប់មធ្យោបាយ | ចំនួននៃការអប់រំផ្សព្វផ្សាយ<br>ប្រភេទមធ្យោបាយនៃការផ្សព្វផ្សាយ<br>ចំនួនស្ថិតិដែលប្រជាពលរដ្ឋទទួលបានព័ត៌មាន | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |
| 2 | សហការជាមួយភាគីពាក់ព័ន្ធក្នុងការផ្សព្វផ្សាយ | ចំនួនស្ថាប័នដែលបានសហការ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **V. ជំរុញការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត** | | | | | | | |
| **ក- គោលដៅយុទ្ធសាស្ត្រទី១៖ ពង្រឹងប្រសិទ្ធភាពនៃយន្តការរៀបចំលិខិតបទដ្ឋានគតិយុត្ត** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ ការរៀបចំរចនាសម្ព័ន្ធនិងធនធានមនុស្ស** | | | | | | | |
| 1 | បង្កើតក្រុមការងារដឹកនាំ សម្របសម្រួលរៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអធិការកិច្ច ឱ្យមានសង្គតិភាពនិងសុខដុមនីយកម្ម | សេចក្តីសម្រេចបង្កើតក្រុមការងារ | ✓ | | | | ក្រសួងអធិការកិច្ច |
| 2 | កិច្ចប្រជុំត្រួតពិនិត្យនិងវាយតម្លៃ | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍ស្តីពីការត្រួតពិនិត្យ និងវាយតម្លៃ | ✓ | ✓ | ✓ | ✓ | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- ក្រុមការងារ |
| ➢ **វិធានការគន្លឹះទី២៖ អភិវឌ្ឍន៍ផ្នែកសិក្សាស្រាវជ្រាវ** | | | | | | | |
| 1 | ពង្រឹងយន្តការសិក្សាស្រាវជ្រាវជាក់លាក់តាមរយៈការបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សា កិច្ចប្រជុំនានា | ចំនួននៃការបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សា កិច្ចប្រជុំនានា | ✓ | ✓ | ✓ | ✓ | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 2 | ស្រាវជ្រាវ ចងក្រងទិន្នន័យជាឯកសារសម្រាប់គាំទ្រការរៀបចំលិខិតបទដ្ឋានគតិយុត្ត | ចំនួនឯកសារដែលបានស្រាវជ្រាវនិងចងក្រង | ✓ | ✓ | ✓ | ✓ | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 3 | កៀរគរដៃគូនានាទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស | - ចំនួនដៃគូដែលសហការ<br>- ចំនួនរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចសហការជាមួយដៃគូនានា | ✓ | ✓ | ✓ | ✓ | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| ➢ **វិធានការគន្លឹះទី៣៖ ជំរុញកិច្ចសហការជាមួយភាគីពាក់ព័ន្ធ** | | | | | | | |
| 1 | សហការជាមួយក្រសួង ស្ថាប័ន និងគ្រប់ភាគីពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាប្រឈម និង | - ចំនួនក្រសួង ស្ថាប័ន អង្គភាព និងភាគីពាក់ព័ន្ធដែលបានសហការ<br>- ចំនួនកិច្ចប្រជុំនានា | ✓ | ✓ | ✓ | ✓ | - ក្រសួងអធិការកិច្ច<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ពន្លឿនការរៀបចំលិខិតបទដ្ឋានគតិយុត្តដែលជាយន្តការសម្រាប់គាំទ្រមុខងាររបស់ក្រសួងអធិការកិច្ច តាមរយៈកិច្ចប្រជុំនិងសិក្ខាសាលាពិគ្រោះយោបល់ | - ចំនួនរបាយការណ៍នៃកិច្ចប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់ | | | | | |
| 2 | សហការជាមួយក្រសួង ស្ថាប័ន និងគ្រប់ភាគីពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាប្រឈម និងពន្លឿនការរៀបចំលិខិតបទដ្ឋានគតិយុត្តដែលជាយន្តការសម្រាប់គាំទ្រវិស័យអធិការកិច្ច តាមរយៈកិច្ចប្រជុំនិងសិក្ខាសាលាពិគ្រោះយោបល់ | - ចំនួនក្រសួង ស្ថាប័ន អង្គភាព និងភាគីពាក់ព័ន្ធដែលបានសហការ<br>- ចំនួនកិច្ចប្រជុំនានា<br>- ចំនួនរបាយការណ៍នៃកិច្ចប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់ | ✓ | ✓ | ✓ | ✓ | - ក្រសួងអធិការកិច្ច<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| ➢ **វិធានការគន្លឹះទី៤៖ ពង្រឹងយន្តការនៃការផ្សព្វផ្សាយ** | | | | | | | |
| 1 | រៀបចំផែនការនៃការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអធិការកិច្ច | - ចំនួនកិច្ចប្រជុំ<br>- ឯកសារផែនការដែលបានរៀបចំ | ✓ | ✓ | ✓ | ✓ | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 2 | ជំរុញការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអធិការកិច្ច តាមរយៈសិក្ខាសាលា ទស្សនកិច្ចសិក្សា វេទិកា កម្មវិធី កិច្ចប្រជុំនានា និង ប្រព័ន្ធបច្ចេកវិទ្យា | - ចំនួនសិក្ខាសាលា ទស្សនកិច្ចសិក្សា កម្មវិធី វេទិកា និងកិច្ចប្រជុំដែលបានផ្សព្វផ្សាយ<br>- ចំនួនលិខិតបទដ្ឋានគតិយុត្តដែលបានផ្សព្វផ្សាយ<br>- ចំនួនរបាយការណ៍ | ✓ | ✓ | ✓ | ✓ | - ក្រសួងអធិការកិច្ច<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| 3 | ត្រួតពិនិត្យ និងវាយតម្លៃ លើលទ្ធផលនៃការផ្សព្វផ្សាយ | ចំនួនកិច្ចប្រជុំ | ✓ | ✓ | ✓ | ✓ | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ➢ វិធានការគន្លឹះទី៥៖ ពង្រឹងយន្តការនៃការគាំទ្រ | | | | | | | |
| 1 | ជំរុញការគាំទ្រលើផ្នែកបច្ចេកទេស សម្ភារៈ | - ចំនួនសម្ភារៈដែលបានផ្តល់ជូនក្រុមការងារអនុវត្ត<br>- ចំនួនកិច្ចប្រជុំដែលបានរៀបចំក្នុងការផ្តល់នូវការប្រឹក្សាយោបល់ | ✓ | ✓ | ✓ | ✓ | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 2 | ជំរុញការគាំទ្រ និងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងមន្ត្រីអនុវត្តការងារលើផ្នែកហិរញ្ញវត្ថុ | ចំនួនថ្នាក់ដឹកនាំនិងមន្ត្រីដែលបានលើកទឹកចិត្ត | ✓ | ✓ | ✓ | ✓ | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| 3 | ជំរុញការគាំទ្រ និងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងមន្ត្រីអនុវត្តការងារលើផ្នែកមិនមែនហិរញ្ញវត្ថុ | ចំនួនថ្នាក់ដឹកនាំនិងមន្ត្រីដែលបានលើកទឹកចិត្ត | ✓ | ✓ | ✓ | ✓ | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |
| **ខ- គោលដៅយុទ្ធសាស្ត្រទី២៖ ជំរុញការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងពង្រឹងប្រសិទ្ធភាពនិងសុខដុមនីយកម្មនៃលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអធិការកិច្ច** | | | | | | | |
| ➢ វិធានការគន្លឹះទី១៖ ការកំណត់គោលនយោបាយ | | | | | | | |
| 1 | រៀបចំចក្ខុវិស័យ គោលបំណង គោលដៅវិសាលភាព និងបេសកកម្ម សម្រាប់រៀបចំគោលនយោបាយវិស័យអធិការកិច្ច | - ចំនួនឯកសារដែលបានរៀបចំនិងចងក្រង<br>- ចំនួនកិច្ចប្រជុំពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ក្រសួងអធិការកិច្ច |
| 2 | សុំការសម្រេចដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាលលើគោលនយោបាយវិស័យអធិការកិច្ច | សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីគោលនយោបាយលើវិស័យអធិការកិច្ច | ✓ | | | | ក្រសួងអធិការកិច្ច |
| ➢ វិធានការគន្លឹះទី២៖ ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តជាអាទិភាពរបស់ក្រសួងអធិការកិច្ច | | | | | | | |
| 3 | រៀបចំវិធាននិងនីតិវិធីប្រតិបត្តិ(SOP) សម្រាប់អនុវត្តមុខងារស្នូលរបស់ក្រសួងអធិការកិច្ច រួមមាន ការងារអធិការកិច្ច ការងារដោះស្រាយបណ្តឹង និងការងារតាមដានការអនុវត្តច្បាប់ | វិធាននិងនីតិវិធីប្រតិបត្តិ (SOP) ដែលបានសម្រេចដោយរាជរដ្ឋាភិបាល | ✓ | ✓ | ✓ | ✓ | - ក្រសួងអធិការកិច្ច<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 4 | អនុក្រឹត្យស្ដីពីការបង្កើតមន្ទីរអធិការកិច្ច រាជធានី ខេត្ត | - ចំនួនកិច្ចប្រជុំពាក់ព័ន្ធនានា<br>- អនុក្រឹត្យដែលបានសម្រេចដោយរាជរដ្ឋាភិបាល | ✓ | | | | - ក្រសួងអធិការកិច្ច<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| 5 | អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរអធិការកិច្ចរាជធានី ខេត្ត | - ចំនួនកិច្ចប្រជុំពាក់ព័ន្ធនានា<br>- អនុក្រឹត្យដែលបានសម្រេចដោយរាជរដ្ឋាភិបាល | ✓ | | | | - ក្រសួងអធិការកិច្ច<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| 6 | ប្រកាសស្ដីពីក្រមសីលធម៌វិជ្ជាជីវៈនិងក្រមប្រតិបត្តិមន្ត្រីតាមដានការអនុវត្តច្បាប់ | - ចំនួនកិច្ចប្រជុំពាក់ព័ន្ធនានា<br>- ប្រកាសដែលបានសម្រេចដោយរដ្ឋមន្ត្រី | ✓ | | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត |
| 7 | ប្រកាសស្ដីពីក្រមសីលធម៌វិជ្ជាជីវៈនិងក្រមប្រតិបត្តិមន្ត្រីដោះស្រាយបណ្ដឹង | - ចំនួនកិច្ចប្រជុំពាក់ព័ន្ធនានា<br>- ប្រកាសដែលបានសម្រេចដោយរដ្ឋមន្ត្រី | ✓ | | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត |
| 8 | ប្រកាសស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងអធិការកិច្ច | - ចំនួនកិច្ចប្រជុំពាក់ព័ន្ធនានា<br>- ប្រកាសដែលបានសម្រេចដោយរដ្ឋមន្ត្រី | ✓ | | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| 9 | ប្រកាសស្ដីពីការបែងចែកក្រសួង ស្ថាប័ន តាមវិស័យក្នុងការធ្វើអធិការកិច្ច និងការកំណត់សមត្ថកិច្ចរបស់នាយកដ្ឋានតាមដានការអនុវត្តច្បាប់ | - ចំនួនកិច្ចប្រជុំពាក់ព័ន្ធនានា<br>- ប្រកាសដែលបានសម្រេចដោយរដ្ឋមន្ត្រី | ✓ | | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត |
| 10 | ប្រកាសស្ដីពីរូបសញ្ញានិងត្រារបស់វិទ្យាស្ថានជាតិអធិការកិច្ច | - ចំនួនកិច្ចប្រជុំពាក់ព័ន្ធនានា<br>- ប្រកាសដែលបានសម្រេចដោយរដ្ឋមន្ត្រី | ✓ | | | | - ក្រសួងអធិការកិច្ច<br>- វិទ្យាស្ថានជាតិអធិការកិច្ច |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 11 | ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះមន្ទីរអធិការកិច្ចរាជធានី ខេត្ត | - ចំនួនកិច្ចប្រជុំពាក់ព័ន្ធនានា<br>- ប្រកាសដែលបានសម្រេចដោយរដ្ឋមន្ត្រី | ✓ | | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| 12 | សេចក្តីណែនាំស្តីពីការប្រើប្រាស់រូបសញ្ញា និងត្រារបស់មន្ទីរអធិការកិច្ចរាជធានី ខេត្ត បណ្តោះអាសន្ន | - ចំនួនកិច្ចប្រជុំពាក់ព័ន្ធនានា<br>- សេចក្តីណែនាំដែលបានចេញដោយក្រសួង | ✓ | | | | - ក្រសួងអធិការកិច្ច<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត |
| 13 | បទបញ្ជាផ្ទៃក្នុងសម្រាប់គណៈប្រតិភូអធិការកិច្ច និងតាមដានការអនុវត្តច្បាប់ | - ចំនួនកិច្ចប្រជុំពាក់ព័ន្ធនានា<br>- បទបញ្ជាផ្ទៃក្នុងដែលបានចេញដោយក្រសួង | ✓ | | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត |
| 14 | បទបញ្ជាផ្ទៃក្នុងសម្រាប់គណៈប្រតិភូដោះស្រាយបណ្តឹងនិងអង្កេតស្រាវជ្រាវ | - ចំនួនកិច្ចប្រជុំពាក់ព័ន្ធនានា<br>- បទបញ្ជាផ្ទៃក្នុងដែលបានចេញដោយក្រសួង | ✓ | | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត |
| ➢ **វិធានការគន្លឹះទី៣៖ ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រក្នុងវិស័យអធិការកិច្ច** | | | | | | | |
| 1 | ទស្សនាទានស្តីពីអធិការកិច្ច | - ចំនួនកិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ចសិក្សា<br>- ឯកសារទស្សនាទានស្តីពីអធិការកិច្ច | ✓ | | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| 2 | គោលនយោបាយជាតិស្តីពីអធិការកិច្ច | - ចំនួនកិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ចសិក្សា<br>- ឯកសារទស្សនាទានស្តីពីអធិការកិច្ច | ✓ | | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 3 | ច្បាប់ស្តីពីអធិការកិច្ច | - ចំនួនកិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ចសិក្សា<br>- ព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ស្តីពីអធិការកិច្ច | ✓ | | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| 4 | អនុក្រឹត្យស្តីពីឯកសណ្ឋាន និងសញ្ញាស័ក្តិរបស់មន្ត្រីអធិការកិច្ច | - ចំនួនកិច្ចប្រជុំ សិក្ខាសាលា<br>- អនុក្រឹត្យស្តីពីឯកសណ្ឋាននិងសញ្ញាស័ក្តិរបស់មន្ត្រីអធិការកិច្ចត្រូវបានសម្រេច | ✓ | | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| 5 | អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈ និងក្រមប្រតិបត្តិមន្ត្រីអធិការកិច្ច | - ចំនួនកិច្ចប្រជុំ សិក្ខាសាលា<br>- អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈ និងក្រមប្រតិបត្តិមន្ត្រីអធិការកិច្ចត្រូវបានសម្រេច | ✓ | | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| 6 | អនុក្រឹត្យស្តីពីនីតិវិធីទទួល ពិនិត្យ អង្កេតស្រាវជ្រាវនិងដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហារ | - ចំនួនកិច្ចប្រជុំ សិក្ខាសាលា<br>- អនុក្រឹត្យស្តីពីនីតិវិធីទទួល ពិនិត្យ អង្កេតស្រាវជ្រាវនិងដោះស្រាយបណ្តឹងតវ៉ានិងបណ្តឹងបរិហារត្រូវបានសម្រេច | | ✓ | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| 7 | អនុក្រឹត្យស្តីពីនីតិវិធីអធិការកិច្ច និងការតាមដានការអនុវត្តច្បាប់ | - ចំនួនកិច្ចប្រជុំ សិក្ខាសាលា<br>- អនុក្រឹត្យស្តីពីនីតិវិធីអធិការកិច្ច និងការតាមដានការអនុវត្តច្បាប់ | | ✓ | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| 8 | អនុក្រឹត្យស្តីពីភារកិច្ច និងសិទ្ធិអំណាចរបស់ស្ថាប័នអធិការកិច្ច | - ចំនួនកិច្ចប្រជុំ សិក្ខាសាលា | | ✓ | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | - អនុក្រឹត្យស្តីពីភារកិច្ច និងសិទ្ធិអំណាចរបស់ស្ថាប័នអធិការកិច្ច | | | | | - មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| 9 | អនុក្រឹត្យស្តីពីនីតិវិធីនៃការរៀបចំផែនការរួមស្តីពីអធិការកិច្ច | - ចំនួនកិច្ចប្រជុំ សិក្ខាសាលា<br>- អនុក្រឹត្យស្តីពីនីតិវិធីនៃការរៀបចំផែនការរួមស្តីពីអធិការកិច្ច | | ✓ | | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| 10 | អនុក្រឹត្យស្តីពីនីតិវិធីនៃការអនុវត្តសេចក្តីសម្រេចលើលទ្ធផលអធិការកិច្ច | - ចំនួនកិច្ចប្រជុំ សិក្ខាសាលា<br>- អនុក្រឹត្យស្តីពីនីតិវិធីនៃការអនុវត្តសេចក្តីសម្រេចលើលទ្ធផលអធិការកិច្ច | | | ✓ | | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| 11 | ច្បាប់ស្តីពីបណ្តឹងតវ៉ា និងបណ្តឹងបរិហារ | - ចំនួនកិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ចសិក្សា<br>- ព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ស្តីពីបណ្តឹងតវ៉ា និងបណ្តឹងបរិហារ | | ✓ | ✓ | ✓ | - ក្រសួងអធិការកិច្ច<br>- នាយកដ្ឋានជំនាញ<br>- មន្ទីរអធិការកិច្ចរាជធានីខេត្ត<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| VI. | **ជំរុញនិងបង្កើនសមត្ថភាពស្ថាប័ន** | | | | | | |
| | **ក- គោលដៅយុទ្ធសាស្ត្រទី១៖ លើកកម្ពស់សមត្ថភាពនិងការធ្វើទំនើបកម្មស្ថាប័ន** | | | | | | |
| | ➢ **វិធានការគន្លឹះទី១៖ ពង្រឹងការងារវិភាគមុខងារនិងការរៀបចំរចនាសម្ព័ន្ធអង្គភាពចំណុះក្រសួង** | | | | | | |
| 1 | បន្តវិភាគមុខងាររបស់មន្ត្រីចាប់ពីថ្នាក់អគ្គនាយកចុះក្រោម | - ភាគរយនៃមន្ត្រីរាជការដែលបានធ្វើវិភាគមុខងារប្រចាំឆ្នាំ<br>- ចំនួននៃការកែតម្រូវទៅលើ តួនាទីភារកិច្ចផ្អែកលើការវិភាគមុខងារដែលបានធ្វើ | ✓ | ✓ | ✓ | ✓ | ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 2 | ពង្រឹងការរៀបចំរចនាសម្ព័ន្ធរបស់អង្គភាពចំណុះក្រសួង | - ចំនួនអង្គភាពចំណុះក្រសួងដែលបានកែសម្រួលរចនាសម្ព័ន្ធថ្មី<br>- ភាគរយនៃអង្គភាពចំណុះក្រសួងរាយការណ៍ពីការកើនឡើងប្រសិទ្ធភាពប្រតិបត្តិការបន្ទាប់ពីការកែសម្រួលរចនាសម្ព័ន្ធ | ✓ | | | | | ថ្នាក់ដឹកនាំ |
| 3 | ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត មុខងាររបស់មន្ត្រី | - ចំនួននៃការវាយតម្លៃការអនុវត្តមុខងាររបស់មន្ត្រីដែលបានធ្វើប្រចាំឆមាស ឬប្រចាំឆ្នាំ<br>- ភាគរយនៃមន្ត្រីដែលបានធ្វើឱ្យប្រសើរឡើងនូវការអនុវត្តមុខងារបន្ទាប់ពីការវាយតម្លៃ | ✓ | ✓ | ✓ | ✓ | | ថ្នាក់ដឹកនាំ |
| ➢ **វិធានការគន្លឹះទី២៖ ជំរុញការធ្វើទំនើបកម្មស្ថាប័ន** | | | | | | | | |
| 1 | បំពាក់សម្ភារៈបរិក្ខារការិយាល័យទំនើបឱ្យបានគ្រប់គ្រាន់នៅបន្ទប់ធ្វើការ | - ចំនួនអង្គភាពដែលបានបំពាក់សម្ភារៈបរិក្ខារទំនើបប្រចាំឆ្នាំ<br>- ភាគរយនៃមន្ត្រីរាជការពេញចិត្តនឹងគុណភាពនិងមុខងាររបស់ឧបករណ៍ការិយាល័យដែលបានបំពាក់ | ✓ | ✓ | ✓ | ✓ | | ថ្នាក់ដឹកនាំ |
| 2 | កែលម្អសាលប្រជុំ និងបំពាក់គ្រឿងបំពងសម្លេងទំនើបតាមបែបឌីជីថល | - ចំនួនសាលប្រជុំដែលបានកែលម្អ និងបំពាក់គ្រឿងបំពងសម្លេងទំនើប<br>- កម្រិតពេញចិត្តរបស់មន្ត្រីរាជការលើប្រព័ន្ធបំពងសម្លេងនៅពេលប្រជុំ | ✓ | ✓ | ✓ | ✓ | | ថ្នាក់ដឹកនាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 3 | ពង្រឹងការត្រួតពិនិត្យCameraសុវត្ថិភាពនៅតាមច្រកចេញចូល | កាមេរ៉ាសុវត្ថិភាពដែលបានបំពាក់ដំណើរការបានល្អ | ✓ | ✓ | ✓ | ✓ | ក្រុមការងារឌីជីថល |
| 4 | រៀបចំប្រព័ន្ធលំហូរឯកសារឌីជីថល | - ចំនួនប្រព័ន្ធលំហូរឯកសារឌីជីថលដែលបានរៀបចំ និងដាក់ឱ្យដំណើរការ<br>- ភាគរយនៃឯកសារចូល និងចេញដែលបានដំណើរការតាមរយៈប្រព័ន្ធលំហូរឯកសារឌីជីថល | ✓ | ✓ | ✓ | ✓ | ក្រុមការងារឌីជីថល |
| | ➢ **វិធានការគន្លឹះទី៣៖ កែលម្អកន្លែងធ្វើការប្រកបដោយផាសុកភាព សោភណភាព និងអនាម័យ** | | | | | | |
| 1 | កែលម្អបន្ទប់ទឹក និងពង្រឹងការរក្សាអនាម័យ | - ចំនួនបន្ទប់ទឹកដែលបានជួសជុលកែលម្អ<br>- ភាគរយនៃអ្នកប្រើប្រាស់ពេញចិត្តនឹងភាពស្អាតនៃបន្ទប់ទឹក និងអនាម័យក្រោយការស្ទង់មតិ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានហិរញ្ញវត្ថុ<br>- នាយកដ្ឋានរដ្ឋបាល |
| 2 | ពង្រឹងការកែលម្អសោភ័ណភាពនិងបរិស្ថានបរិវេណក្នុងនិងក្រៅ | - ចំនួននៃគម្រោងថែទាំ ឬជួសជុលដែលបានបញ្ចប់ ដើម្បីបង្កើនសោភ័ណភាពនិងបរិស្ថានល្អ<br>- ភាគរយនៃមន្ត្រីរាជការពេញចិត្តនឹងទីធ្លាសួនច្បារក្រោយការស្ទង់មតិ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានរដ្ឋបាល |
| 3 | ពង្រឹងការផ្គត់ផ្គង់ទឹកស្អាត | - ភាពញឹកញាប់នៃការត្រួតពិនិត្យគុណភាពនិងកែលម្អប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| 4 | ពង្រឹងស្មារតីចូលរួមរបស់មន្ត្រីក្នុងការថែរក្សាបរិស្ថាន និងអនាម័យ តាមរយៈយុទ្ធនាការការងារផ្សារភ្ជាប់នឹងសុខភាព | - ភាពញឹកញាប់នៃយុទ្ធនាការបំផុសស្មារតីមន្ត្រីរាជការក្នុងការចូលរួមថែរក្សាបរិស្ថាននិងអនាម័យ | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 5 | រៀបចំឡើងវិញ នូវបទបញ្ញាផ្ទៃក្នុងរបស់ក្រសួង | - បទបញ្ញាផ្ទៃក្នុងរបស់ក្រសួងដែលបានកែសម្រួល និងដាក់ឱ្យអនុវត្ត | ✓ | | | | ថ្នាក់ដឹកនាំ |
| 6 | ពង្រឹងការងារសន្តិសុខ សណ្តាប់ធ្នាប់ | - សេចក្តីណែនាំអំពីការងារ<br>- សន្តិសុខ សណ្តាប់ធ្នាប់ដែលបានកែលម្អ និងដាក់ឱ្យអនុវត្ត<br>- កម្រិតពេញចិត្តរបស់មន្ត្រីរាជការលើសេវាសន្តិសុខសណ្តាប់ធ្នាប់ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានរដ្ឋបាល |
| 7 | បង្កើតទារកដ្ឋានសម្រាប់មន្ត្រីដែលមានកូនតូច | - ទារកដ្ឋានសម្រាប់មន្ត្រីដែលមានកូនតូចត្រូវបានបង្កើត និងដាក់ឱ្យដំណើរការ<br>- កម្រិតពេញចិត្តលើការប្រើប្រាស់សេវារបស់ទារកដ្ឋាន | | | ✓ | | ថ្នាក់ដឹកនាំ |
| ➢ **វិធានការគន្លឹះទី៤៖ ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារ** | | | | | | | |
| 1 | ពង្រឹងយន្តការប្រជុំថ្នាក់ដឹកនាំប្រចាំសប្តាហ៍ | - ចំនួននៃកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំសប្តាហ៍ដែលបានរៀបចំតាមពេលកំណត់<br>- ភាគរយនៃថ្នាក់ដឹកនាំដែលចូលរួមការប្រជុំប្រចាំសប្តាហ៍ជាប់លាប់ | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| 2 | បង្កើតយន្តការតាមដានវាយតម្លៃការងាររបស់អង្គភាព | - យន្តការតាមដានវាយតម្លៃការងារដែលបានបង្កើត និងដាក់ឱ្យអនុវត្ត<br>- ភាពញឹកញាប់នៃការត្រួតពិនិត្យ និងការវាយតម្លៃដែលធ្វើឡើងនៅទូទាំងអង្គភាពរបស់ស្ថាប័ន<br>- ភាគរយនៃការសម្រេចចិត្ត ឬការផ្លាស់ប្តូរគោលនយោបាយដែលត្រូវបានរកឃើញ និងផ្តល់អនុសាសន៍ | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | ធ្វើការវាយតម្លៃជាប្រចាំដើម្បីវាស់ប្រសិទ្ធភាពនៃសកម្មភាពព្រមទាំងកែលម្អផែនការតាមលទ្ធផលនៃការវាយតម្លៃ | - ចំនួនលើកនៃការវាយតម្លៃប្រសិទ្ធភាព និងសកម្មភាពការងារដែលបានធ្វើ<br>- ភាគរយនៃអនុសាសន៍វាយតម្លៃប្រចាំឆ្នាំដែលបានកែប្រែ | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| ៤ | ពង្រឹងប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃនៅគ្រប់កម្រិត | គោលការណ៍ ឬវិធានការណែនាំដើម្បីពង្រឹងប្រព័ន្ធ តាមដានត្រួតពិនិត្យនិងវាយតម្លៃដែលបានកែលម្អនិងដាក់ឱ្យអនុវត្ត | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| ៥ | អភិវឌ្ឍសមត្ថភាពអង្គភាព និងមន្ត្រីទទួលបន្ទុកត្រួតពិនិត្យ តាមដាន និងវាយតម្លៃ | ចំនួនមន្ត្រីទទួលបន្ទុកតាមដានត្រួតពិនិត្យនិងវាយតម្លៃដែលបានទទួលការបណ្តុះ-បណ្តាល | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| **ខ- គោលដៅយុទ្ធសាស្ត្រទី២៖ ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់ធនធានមនុស្ស** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងមន្ត្រី** | | | | | | | |
| 1 | បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រី | - ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការដែលបានបង្កើត និងធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ<br>- ភាគរយនៃការថយចុះនូវកំហុសទិន្នន័យ ឬភាពមិនស៊ីសង្វាក់គ្នា បន្ទាប់ពីការអនុវត្តប្រព័ន្ធគ្រប់គ្រង | | ✓ | | | នាយកដ្ឋានធនធានមនុស្ស |
| 2 | ពង្រឹងប្រព័ន្ធគ្រប់គ្រងបៀវត្ស | - ប្រព័ន្ធគ្រប់គ្រងបៀវត្សត្រូវបានកែលម្អ និងធ្វើទំនើបកម្ម<br>- ភាគរយនៃប្រតិបត្តិការបើកប្រាក់បៀវត្សបានដំណើរការត្រឹមត្រូវ និងទាន់ពេលវេលា | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានធនធានមនុស្ស |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 3 | រៀបចំបោះពុម្ពបណ្ណសម្គាល់ខ្លួនមន្ត្រីរាជការឡើងវិញ | - ចំនួនកាតមន្ត្រីរាជការដែលបានរៀបចំកែលម្អ និងបោះពុម្ព | ✓ | | | | នាយកដ្ឋានធនធានមនុស្ស |
| 4 | ធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីប្រចាំឆ្នាំ | - ចំនួននៃកំណត់ត្រាមន្ត្រីដែលបានធ្វើបច្ចុប្បន្នភាពនៅក្នុងប្រព័ន្ធប្រចាំឆ្នាំ<br>- ចំនួននៃភាពមិនស៊ីគ្នាដែលបានរកឃើញ និងកែតម្រូវក្នុងអំឡុងពេលដំណើរការធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានធនធានមនុស្ស |
| 5 | ពង្រឹងការគ្រប់គ្រងបម្រែបម្រួលស្ថានភាពរដ្ឋបាលរបស់មន្ត្រី | - សេចក្តីណែនាំ ឬអនុសាសន៍ដែលបានកែលម្អ និងដាក់ឱ្យអនុវត្ត<br>- ភាគរយនៃមន្ត្រីដែលមានកំណត់ត្រាស្ថានភាពរដ្ឋបាលបច្ចុប្បន្នកម្មនៅក្នុងប្រព័ន្ធ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានធនធានមនុស្ស |
| 6 | បំពាក់ប្រព័ន្ធគ្រប់គ្រងវត្តមានមន្ត្រីរាជការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | - របាយការណ៍ស្តីពីវត្តមានមន្ត្រីរាជការប្រចាំថ្ងៃ សប្តាហ៍ ត្រីមាស ឆមាស ឆ្នាំ<br>- ភាគរយនៃចំនួនមន្ត្រីដែលមកបំពេញការងារ | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| ➢ **វិធានការគន្លឹះទី២៖ ពង្រឹងការប្រើប្រាស់ធនធានមនុស្ស** | | | | | | | |
| 1 | ពង្រឹងការបែងចែកតួនាទី មុខងារ ភារកិច្ចមន្ត្រីនៅតាមអង្គភាព | គោលការណ៍ ឬសេចក្តីណែនាំឬសេចក្តីសម្រេច ដែលបានបែងចែកតួនាទី ភារកិច្ច និងដាក់ឱ្យអនុវត្ត | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 2 | ពង្រឹងការអនុវត្តមុខងារ និងភារកិច្ចរបស់មន្ត្រី | - វិធានការ ឬសេចក្តីណែនាំស្តីពីដាក់ឱ្យអនុវត្ត<br>- របាយការណ៍ស្តីពីការវិភាគមុខងារតាមអង្គភាព | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| 3 | ពង្រឹងការរៀបចំផែនការប្រើប្រាស់ធនធានមនុស្ស | បែងចែកមន្ត្រីឱ្យត្រូវជំនាញដើម្បីប្រសិទ្ធភាពការងារ | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| **គ- គោលដៅយុទ្ធសាស្ត្រទី៣៖ អភិវឌ្ឍន៍ធនធានមនុស្សឈានទៅកសាងមូលធនមនុស្សប្រកបដោយគុណឧត្តម** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ ពង្រឹងការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស** | | | | | | | |
| 1 | បង្កើនកម្មវិធីបណ្តុះបណ្តាលចំណេះដឹង និងជំនាញវិជ្ជាជីវៈ | - ចំនួនកម្មវិធីបណ្តុះបណ្តាល<br>- ចំនួនមន្ត្រីរាជការ បុគ្គលិកដែលបានទទួលការបណ្តុះបណ្តាល | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានធនធានមនុស្ស<br>- វិទ្យាស្ថានជាតិអធិការកិច្ច |
| 2 | ស្តង់មតិពីតម្រូវការនៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ | ចំនួនដងនៃការស្ទង់មតិពីតម្រូវការនៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈតាមអង្គភាព | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានធនធានមនុស្ស<br>- វិទ្យាស្ថានជាតិអធិការកិច្ច |
| 3 | ជំរុញការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស | ចំនួនមន្ត្រីដែលចូលរួមក្នុងកម្មវិធីបណ្តុះ-បណ្តាលទាំងក្នុង និងក្រៅប្រទេសក្នុងមួយឆ្នាំ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានធនធានមនុស្ស<br>- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ<br>- វិទ្យាស្ថានជាតិអធិការកិច្ច |
| ➢ **វិធានការគន្លឹះទី២៖ ការពង្រឹងការអនុវត្តច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈ** | | | | | | | |
| 1 | ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ក្រមសីលធម៌វិជ្ជាជីវៈ និងវិន័យរបស់មន្ត្រីរាជការ | - វិធានការ ឬគោលការណ៍ដែលបានកែលម្អ និងដាក់ឱ្យអនុវត្ត | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានធនធានមនុស្ស |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | - ចំនួនមន្ត្រីរាជការដែលទទួលបានការបណ្តុះបណ្តាលអំពីនីតិវិធីអនុវត្តច្បាប់ ក្រមសីលធម៌ និងវិន័យ | | | | | |
| 2 | ពង្រឹងវិធានការវិន័យ និងយន្តការទណ្ឌកម្មចំពោះមន្ត្រីដែលមានកំហុស | - ចំនួនសេចក្តីសម្រេច ឬបទបញ្ជាដែលបានដាក់ចេញ<br>- ចំនួននៃវិធានការវិន័យចំពោះមន្ត្រីរាជការដែលបានប្រព្រឹត្តខុស | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានធនធានមនុស្ស |
| **ឃ- យុទ្ធសាស្ត្រទី៤៖ ពង្រឹងយន្តការវាយតម្លៃលទ្ធផលការងារ និងជំរុញប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម** | | | | | | | |
| ➢ **វិធានការគន្លឹះទី១៖ ពង្រឹងប្រសិទ្ធភាពនៃការវាយតម្លៃមន្ត្រីដែលមានស្នាដៃ** | | | | | | | |
| 1 | បង្កើតគណៈកម្មការវាយតម្លៃមន្ត្រី | សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការវាយតម្លៃមន្ត្រី | ✓ | | | | ថ្នាក់ដឹកនាំ |
| 3 | បង្កើតវិធីសាស្ត្រនៃការវាយតម្លៃប្រកបដោយតម្លាភាព | វិធីសាស្ត្រសម្រាប់ការវាយតម្លៃការងារមន្ត្រីរាជការដែលបានរៀបចំ និងដាក់ឱ្យអនុវត្ត | ✓ | | | | ថ្នាក់ដឹកនាំ |
| 2 | ពង្រឹងការវាយតម្លៃដោយផ្អែកលើសមិទ្ធកម្មការងារ | ចំនួនមន្ត្រីរាជការដែលបានទទួលការវាយតម្លៃការងារផ្អែកលើសមិទ្ធកម្ម | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| ➢ **វិធានការគន្លឹះទី២៖ ពង្រឹងយន្តការប្រព័ន្ធលើកទឹកចិត្តមន្ត្រីគាំទ្រសមិទ្ធកម្ម** | | | | | | | |
| 1 | ពង្រឹងការលើកទឹកចិត្តផ្អែកហិរញ្ញវត្ថុ ផ្អែកលើសមិទ្ធកម្មរបស់អង្គភាព | ចំនួនអង្គភាពដែលបានទទួលការលើកទឹកចិត្ត | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| 2 | ពង្រឹងការលើកទឹកចិត្តផ្អែកហិរញ្ញវត្ថុ ផ្អែកលើសមិទ្ធកម្មរបស់បុគ្គល | ចំនួនមន្ត្រីរាជការដែលបានទទួលការលើកទឹកចិត្ត | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| 3 | ពង្រឹងការលើកទឹកចិត្តមិនមែនហិរញ្ញវត្ថុដូចជាការផ្តល់នូវតួនាទី គ្រឿងឥស្សរិយយស | ចំនួនមន្ត្រីរាជការដែលបានទទួលការលើកទឹកចិត្ត | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | បណ្ណសរសើរ ការបណ្តុះបណ្តាលក្រៅប្រទេស ឬការតម្លើងកាំប្រាក់ជាដើម | | | | | | |
| 4 | រៀបចំកែសម្រួលប្រព័ន្ធលើកទឹកចិត្តគ្រប់អង្គភាពឱ្យមានប្រសិទ្ធភាព ប្រសិទ្ធផល និងតម្លាភាព | - ប្រព័ន្ធលើកទឹកចិត្តមន្ត្រីរាជការដែលបានរៀបចំកែសម្រួល និងដាក់ឱ្យអនុវត្ត<br>- ភាគរយនៃមន្ត្រីរាជការដែលទទួលបានការលើកទឹកចិត្តដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ និងផ្អែកលើគុណសម្បត្តិ | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| 5 | ជួយឧបត្ថម្ភមន្ត្រីក្នុងពេលរៀបអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួន | - ចំនួនមន្ត្រីរាជការដែលបានទទួលការឧបត្ថម្ភពេលរៀបអាពាហ៍ពិពាហ៍ប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| 6 | ការចូលរួមចំណែកនិងដោះស្រាយការលំបាករបស់មន្ត្រីដូចជាមានពេលជំងឺជាដើម | - ចំនួនមន្ត្រីរាជការដែលបានទទួលការជួយជ្រោមជ្រែង ឬដោះស្រាយការលំបាកប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំ |
| VII. | **ជំរុញកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ** | | | | | | |
| | **ក- គោលដៅយុទ្ធសាស្ត្រទី១៖ ជំរុញកិច្ចសហការជាមួយក្រសួង ស្ថាប័នចំណុះរាជរដ្ឋាភិបាល** | | | | | | |
| 1 | ជំរុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍លទ្ធផលនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា<br>- ចំនួនមន្ត្រីរាជការដែលបានបញ្ជូនទៅសិក្សា | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានធនធានមនុស្ស<br>- នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 2 | ជំរុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយវិទ្យាស្ថានជាតិការទូតនិងទំនាក់- | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍លទ្ធផលនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ទំនងអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | - ចំនួនមន្ត្រីរាជការដែលបានបញ្ជូនទៅសិក្សា | | | | | - នាយកដ្ឋានធនធានមនុស្ស |
| 3 | ជំរុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងព័ត៌មាន | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍លទ្ធផលនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំក្រសួង<br>- អគ្គនាយកដ្ឋានអធិការកិច្ច<br>- អគ្គនាយកដ្ឋានដោះស្រាយបណ្តឹង |
| 4 | ជំរុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយសាលាភូមិន្ទរដ្ឋបាលនៃក្រសួងមុខងារសាធារណៈ | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍លទ្ធផលនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា<br>- ចំនួនមន្ត្រីរាជការដែលបានបញ្ជូនទៅសិក្សា | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំក្រសួង<br>- នាយកដ្ឋានធនធានមនុស្ស |
| 5 | ជំរុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍លទ្ធផលនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា | ✓ | ✓ | ✓ | ✓ | ថ្នាក់ដឹកនាំក្រសួង |
| 6 | ជំរុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយមន្ទីរពេទ្យព្រះកេតុមាលា | - ចំនួនកិច្ចប្រជុំ<br>- ចំនួនរបាយការណ៍លទ្ធផលនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា<br>- ចំនួនអ្នកជំងឺដែលបានបញ្ជូនទៅពិនិត្យព្យាបាល | ✓ | ✓ | ✓ | ✓ | ក្រុមការងារយេនឌ័រនៃក្រសួងអធិការកិច្ច |
| 7 | ជំរុញទំនាក់ទំនងនិងសហការជាមួយក្រសួងស្ថាប័ននានា | ចំនួនក្រសួង ស្ថាប័នដែលបានទំនាក់ទំនងនិងសហការ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| **ខ. គោលដៅយុទ្ធសាស្ត្រទី២៖ ជំរុញកិច្ចសហប្រតិបត្តិការស៊ីជម្រៅជាមួយបណ្តាប្រទេសក្នុងតំបន់និងពិភពលោក** | | | | | | | |
| 1 | បន្តអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម | ចំនួនអនុស្សរណៈនៃការយោគយល់គ្នាឬកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាជាមួយតួអង្គពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំក្រសួង<br>- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 2 | ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយសាធារណរដ្ឋប្រជាមានិតចិន | ចំនួនអនុស្សរណៈនៃការយោគយល់គ្នាឬកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាជាមួយតួអង្គពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំក្រសួង<br>- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| 3 | ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយសាធារណរដ្ឋឥណ្ឌា | ចំនួនអនុស្សរណៈនៃការយោគយល់គ្នាឬកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាជាមួយតួអង្គពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំក្រសួង<br>- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| 4 | បន្តសហប្រតិបត្តិការជាមួយស្ថានទូតមួយចំនួនរួមមាន ព្រះរាជាណាចក្រថៃ សាធារណរដ្ឋឥណ្ឌូនេស៊ី និងសាធារណរដ្ឋហ្វីលីពីន ដើម្បីឈានទៅចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយស្ថាប័នដោះស្រាយបណ្ដឹង | - ចំនួនលើកនៃទំនាក់ទំនង<br>- ចំនួនលើកនៃកិច្ចប្រជុំ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំក្រសួង<br>- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| 5 | បន្តសហការជាមួយស្ថានទូតនៃសាធារណរដ្ឋហុងគ្រី សាធារណរដ្ឋទួរគីយេ ដើម្បីផ្សារភ្ជាប់វិស័យអធិការកិច្ចកម្ពុជាជាមួយបណ្ដាប្រទេសនៅអឺរ៉ុប | - ចំនួនលើកនៃទំនាក់ទំនង<br>- ចំនួនលើកនៃកិច្ចប្រជុំ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំក្រសួង<br>- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| 6 | ទំនាក់ទំនងនិងសហការជាមួយប្រទេសជប៉ុន សាធារណរដ្ឋកូរ៉េ និងសាធារណរដ្ឋសិង្ហបុរី | - ចំនួនលើកនៃទំនាក់ទំនង<br>- ចំនួនលើកនៃកិច្ចប្រជុំ | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំក្រសួង<br>- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| | **គ. គោលដៅយុទ្ធសាស្ត្រទី៣៖ ជំរុញកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ** | | | | | | |
| 1 | ជំរុញកិច្ចសហការជាមួយក្របខ័ណ្ឌភាពជាដៃគូក្នុងការប្រឆាំងអំពើពុករលួយ ASEAN | - ចំនួនកិច្ចប្រជុំ<br>- ចំនួនទស្សនកិច្ច | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំក្រសួង |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | Parties Against Corruption ( ASEAN-PAC ) តាមរយៈការចូលរួមសិក្ខាសាលា និងការចែករំលែកព័ត៌មាន | - ចំនួនសិក្ខាសាលា | | | | | - នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| 2 | ជំរុញកិច្ចសហប្រតិបត្តិការជាមួយវេទិកាដោះស្រាយបណ្ដឹងអាស៊ីអាគ្នេយ៍ South East Asian Ombudsman Forum ( SEAOF ) | - ចំនួនកិច្ចប្រជុំ<br>- ចំនួនទស្សនកិច្ច | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំក្រសួង<br>- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| 3 | បន្តទំនាក់ទំនងនិងសហការជាមួយអង្គការអន្តរជាតិនានាដូចជា UNDP Asia Foundation ជាដើម | - ចំនួនកិច្ចប្រជុំ<br>- ចំនួនទស្សនកិច្ច<br>- ចំនួនលើកនៃទំនាក់ទំនង | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំក្រសួង<br>- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| VIII. | **ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល** | | | | | | |
| | **ក- គោលដៅយុទ្ធសាស្ត្រទី១៖ លើកកម្ពស់ការអភិវឌ្ឍអន្តរាគមន៍ឌីជីថល** | | | | | | |
| | ➢ **វិធានការគន្លឹះទី១៖ កសាងហេដ្ឋារចនាសម្ព័ន្ធរឹង** | | | | | | |
| 1 | រៀបចំហេដ្ឋារចនាសម្ព័ន្ធឌីជីថល តខ្សែបណ្ដាញប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធ Network | - ចំនួនលើកនៃការរៀបចំ<br>- ចំនួនប្រព័ន្ធដែលបានរៀបចំ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 2 | រៀបចំបំពាក់សម្ភារៈបរិក្ខារបច្ចេកវិទ្យាព័ត៌មានវិទ្យារួមមាន ម៉ាស៊ីន Computer, Printer, Scanner, Photocopy | - ចំនួនសម្ភារៈ បរិក្ខារ<br>- ចំនួនរបាយការណ៍នៃការរៀបចំ | ✓ | ✓ | | | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 3 | រៀបចំបំពាក់ឧបករណ៍សន្តិសុខសាយប័រសម្រាប់ការពារមជ្ឈមណ្ឌលទិន្នន័យរួមរបស់ក្រសួង | - ចំនួនលើកនៃការរៀបចំ<br>- ចំនួនសម្ភារៈ បរិក្ខារ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 4 | រៀបចំបំពាក់គ្រឿងសង្ហារិមដើម្បីធានាបានផាសុកភាពសុវត្ថិភាពនិងប្រសិទ្ធភាពនៃដំណើរការការងាររបស់នាយកដ្ឋានបរិវត្តកម្មឌីជីថល | ចំនួនគ្រឿងសង្ហារិមដែលបានបំពាក់ | ✓ | ✓ | | | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 5 | រៀបចំធ្វើឌីជីថលលូបនីយកម្ម រួមទាំងការបង្កើតបញ្ញាសិប្បនិម្មិតនិងបច្ចេកវិទ្យាទាន់សម័យសម្រាប់ការងារគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអធិការកិច្ច | ចំនួនបញ្ញាសិប្បនិម្មិតនិងបច្ចេកវិទ្យាដែលបានបង្កើត | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| | ➢ **វិធានការគន្លឹះទី២៖ កសាងហេដ្ឋារចនាសម្ព័ន្ធទន់** | | | | | | |
| 1 | រៀបចំសហការបង្កើតកម្មវិធីផ្សព្វផ្សាយ ណែនាំនូវរបៀបប្រើប្រាស់ថ្នាល (Mobile App) និងបច្ចេកវិទ្យាព័ត៌មានវិទ្យាដល់មន្ត្រីរាជការក្រោមឱវាទក្រសួង | - ចំនួនកម្មវិធីឬកិច្ចប្រជុំដែលបានផ្សព្វផ្សាយ<br>- ចំនួនអ្នកចូលរួមស្តាប់ការផ្សព្វផ្សាយ | ✓ | | | | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 2 | ច្នៃប្រឌិត និងបង្កើតវិធីសាស្ត្រ នីតិវិធី និងកម្មវិធីសម្រាប់គាំទ្រនិងទ្រទ្រង់ដំណើរការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអធិការកិច្ច | ចំនួនកម្មវិធីដែលបានបង្កើត | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 3 | រៀបចំសហការសម្របសម្រួល និងជំរុញបរិវត្តកម្មឌីជីថលស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលឌីជីថល | ចំនួនក្រសួង ស្ថាប័ន អង្គភាពដែលបានសហការ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| | **ខ- គោលដៅយុទ្ធសាស្ត្រទី២៖ លើកកម្ពស់ការអនុវត្តកម្មវិធីកុំព្យូទ័រនិងឧបករណ៍ឆ្លាតវៃ** | | | | | | |
| | ➢ **វិធានការគន្លឹះទី១៖ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាឌីជីថល** | | | | | | |
| 1 | បន្តកិច្ចសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការរៀបចំថ្នាលសម្រាប់ | ចំនួនលើកនៃកិច្ចសហការ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានបរិវត្តកម្មឌីជីថល |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ផ្ទុកឯកសារ ថ្នាលសម្រាប់ដំណើរការចរន្តឯកសារ ថ្នាលសម្រាប់គ្រប់គ្រងព័ត៌មានមន្ត្រីរាជការ ក្រសួងអធិការកិច្ច | | | | | | - នាយកដ្ឋានរដ្ឋបាល<br>- នាយកដ្ឋានធនធានមនុស្ស |
| 2 | បន្តកិច្ចសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការរៀបចំនៃថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh នៅលើវិញ្ញាបនបត្របញ្ជាក់ការសិក្សាចេញដោយវិទ្យាស្ថានជាតិអធិការកិច្ច | ចំនួនលើកនៃកិច្ចសហការ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានបរិវត្តកម្មឌីជីថល<br>- វិទ្យាស្ថានជាតិអធិការកិច្ច |
| 3 | ស្នើសុំទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ប្រើប្រាស់នូវថ្នាល និងកម្មវិធីរាជរដ្ឋាភិបាលឌីជីថល( Digital Government Products–DGPs ) ចំនួន៤រួមមាន ថ្នាលផ្ទុកឯកសារសាធារណៈ GO.GOV.KH ថ្នាលបង្កើតទម្រង់បែបបទអនឡាញFORM.GOV.KH ថ្នាលបញ្ជូនសារពហុទិសដៅ NOMSA.GOV.KH និងកម្មវិធីបញ្ញាសិប្បនិម្មិតបំប្លែងអត្ថបទទៅជាសំឡេងសារិកា "SIRIKA" សម្រាប់ប្រើប្រាស់ក្នុងក្របខ័ណ្ឌក្រសួងអធិការកិច្ច | ចំនួនលិខិតស្នើសុំដែលបានផ្ញើទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ✓ | | | | - ថ្នាក់ដឹកនាំក្រសួង<br>- នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 4 | បន្តកិច្ចសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីរៀបចំតម្លើងសុសវែរ ( Software )ដែលមានអាជ្ញាបណ្ណត្រឹមត្រូវលើម៉ាស៊ីនកុំព្យូទ័រឬឧបករណ៍ឌីជីថលជូន | - ចំនួនលើកនៃកិច្ចសហការ<br>- ចំនួនសុសវែរ ( Software )ដែលបានតម្លើង | ✓ | ✓ | ✓ | ✓ | - ថ្នាក់ដឹកនាំក្រសួង<br>- នាយកដ្ឋានបរិវត្តកម្មឌីជីថល |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ថ្នាក់ដឹកនាំ និងមន្ត្រីរាជការសម្រាប់ប្រើប្រាស់ក្នុងការងារប្រចាំថ្ងៃដើម្បីធានាសុវត្ថិភាពពីការជ្រៀតជ្រែកលួចបន្លំតាមរយៈការវាយប្រហារសាយប័រ (Cyber Attack) | | | | | | |
| 5 | ធ្វើបច្ចុប្បន្នភាពគេហទំព័រ និងថ្នាល ព្រមទាំងដាក់ឱ្យដំណើរការឡើងវិញ បន្ទាប់ពីធ្វើកំណែរូប(Mobile App) របស់ក្រសួងអធិការកិច្ច ដើម្បីធានាសុវត្ថិភាពឱ្យស្របទៅនឹងការវិវត្តនៃបច្ចេកវិទ្យាឌីជីថលសកល | ចំនួនលើកនៃការធ្វើបច្ចុប្បន្នភាព | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 6 | សហការជាមួយអង្គភាពក្រោមឱវាទក្រសួង ក្នុងការផលិតមាតិកាព័ត៌មានលើថ្នាលសម្រាប់ការងារផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ | - ចំនួនលើកនៃកិច្ចសហការ<br>- ចំនួនមាតិកាព័ត៌មានដែលបានផលិត | ✓ | ✓ | ✓ | ✓ | - អគ្គនាយកដ្ឋានដោះស្រាយបណ្តឹង<br>- នាយកដ្ឋានអប់រំ ផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ<br>- នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 7 | ធ្វើការសិក្សា និងរៀបចំចងក្រងមូលដ្ឋានទិន្នន័យរបស់មន្ត្រីរាជការរួមមាន ការគ្រប់គ្រងវត្តមាន កម្រិតជំនាញ ការពិពណ៌នាមុខតំណែង និងការវាយតម្លៃសមិទ្ធកម្មការងារ | ចំនួនរបាយការណ៍ស្តីពីទិន្នន័យមន្ត្រីរាជការ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានបរិវត្តកម្មឌីជីថល<br>- នាយកដ្ឋានធនធានមនុស្ស |
| 8 | រៀបចំអភិវឌ្ឍន៍កម្មវិធីគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការធ្វើសមាហរណកម្ម និងសន្ទានកម្ម ប្រព័ន្ធព័ត៌មាន ដើម្បីបម្រើដល់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យអធិការកិច្ច | ចំនួនកម្មវិធីគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាដែលបានបង្កើត | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 9 | រៀបចំរចនានូវផ្ទាំងរូបភាពណែនាំពីរបៀបប្រើប្រាស់ថ្នាលនៃប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការក្រសួងអធិការកិច្ចតាមប្រព័ន្ធឌីជីថល | ចំនួនផ្ទាំងរូបភាពណែនាំពីរបៀបប្រើប្រាស់ថ្នាល | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 10 | រៀបចំនិងថែទាំបន្ទប់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យរួម (Data Center) សម្រាប់ប្រើប្រាស់ជាមជ្ឈមណ្ឌលគ្រប់គ្រង និងបែងចែកប្រព័ន្ធព័ត៌មានវិទ្យា សេវាអ៊ិនធឺណិតនិងទិន្នន័យរួម (Database) នៅទីស្ដីការក្រសួងអធិការកិច្ច | ចំនួនលើកនៃការថែទាំ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 11 | រៀបចំតម្លើង និងថែទាំម៉ាស៊ីនមេ (Server) សម្រាប់ផ្ទុកទិន្នន័យនិងចែករំលែកទិន្នន័យទៅកាន់អង្គភាពក្រោមឱវាទក្រសួង | - ចំនួនម៉ាស៊ីនមេ(Server)ដែលបានតម្លើង<br>- ចំនួនលើកនៃការថែទាំ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 12 | រៀបចំបំពាក់ និងថែទាំសម្ភារៈបរិក្ខារអ៊ិនធឺណិតថ្មីបន្ថែមរួមមាន តម្លើងទូ Main Server នៅបន្ទប់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យរួមសម្រាប់ផ្ទុកសម្ភារៈបរិក្ខារមេ (Server, Router, Switch និងខ្សែបណ្តាញមេ) និងតម្លើងទូ Sub Server(ទូ Rack)ចំនួន២ទីតាំងទៀត នៅអាគារB និងអាគារC នៅទីស្ដីការក្រសួងអធិការកិច្ច | - ចំនួនសម្ភារៈបរិក្ខារអ៊ិនធឺណិតដែលបានបំពាក់<br>- ចំនួនលើកនៃការថែទាំ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 13 | រៀបចំបំពាក់ និងថែទាំឧបករណ៍ចែកសេវាអ៊ិនធឺណិត Access Point (WiFi Router) និង | - ចំនួនឧបករណ៍ចែកសេវាអ៊ិនធឺណិតដែលបានបំពាក់ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រអប់ភ្ជាប់អ៊ិនធឺណិត និងបណ្តាញ(Outlet) ក្នុងក្រសួងអធិការកិច្ច | - ចំនួនប្រអប់ភ្ជាប់អ៊ិនធឺណិតនិងបណ្តាញដែលបានបំពាក់<br>- ចំនួនលើកនៃការថែទាំ | | | | | |
| 14 | រៀបចំពង្រឹងពង្រីកថ្នាលសម្រាប់ផ្ទុកនិងផ្លាស់ប្តូរទិន្នន័យដើម្បីបង្កើនសមត្ថភាពគ្រប់គ្រងសម្រាប់ផ្លាស់ប្តូរទិន្នន័យ ប្រព័ន្ធព័ត៌មានរវាងក្រសួងអធិការកិច្ច ជាមួយក្រសួង ស្ថាប័ន និងមន្ទីររាជធានី ខេត្ត | ចំនួនថ្នាលដែលបានបង្កើត | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| ➢ **វិធានការគន្លឹះទី២៖ ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល** | | | | | | | |
| 1 | ការរៀបចំបណ្តុះបណ្តាលអភិវឌ្ឍធនធានមនុស្សលើជំនាញសន្តិសុខបច្ចេកវិទ្យាឌីជីថល | ចំនួនលើកនៃការបណ្តុះបណ្តាល | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានបរិវត្តកម្មឌីជីថល<br>- នាយកដ្ឋានធនធានមនុស្ស |
| 2 | ការរៀបចំ និងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល ដើម្បីធានាសុវត្ថិភាពនិងសន្តិសុខខ្ពស់លើការគ្រប់គ្រងប្រតិបត្តិការនិងការប្រើប្រាស់ប្រព័ន្ធឌីជីថល | ចំនួនហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថលដែលបានរៀបចំ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 3 | ពង្រឹងប្រព័ន្ធគ្រប់គ្រងនិងការពារសន្តិសុខឌីជីថលសម្រាប់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានតាមរយៈការកំណត់នីតិវិធីសុវត្ថិភាពនិងការបំពាក់សម្ភារៈបច្ចេកទេសសម្រាប់តាមដានត្រួតពិនិត្យ និងទប់ស្កាត់ការវាយប្រហារនានាស្របតាមស្តង់ដារសន្តិសុខឌីជីថល | ចំនួនឯកសារនីតិវិធីសុវត្ថិភាពដែលបានកំណត់ | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **គ- គោលដៅយុទ្ធសាស្ត្រទី៣៖ អភិវឌ្ឍនវានុវត្តឌីជីថលក្នុងវិស័យអធិការកិច្ច** | | | | | | |
| 1 | ស្វែងរកកិច្ចសហប្រតិបត្តិការជាមួយបណ្ដាក្រុមហ៊ុនជាតិ និងអន្តរជាតិទាំងក្នុង និងក្រៅប្រទេសក្នុងការស្រាវជ្រាវអភិវឌ្ឍនវានុវត្តន៍បច្ចេកវិទ្យាឌីជីថលសម្រាប់វិស័យអធិការកិច្ច | - ចំនួនក្រុមហ៊ុនដែលបានទាក់ទង<br>- ចំនួនក្រុមហ៊ុនដែលបានសហការ | ✓ | ✓ | ✓ | ✓ | - នាយកដ្ឋានបរិវត្តកម្មឌីជីថល<br>- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| 2 | ជំរុញការកសាងប្រព័ន្ធស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាឌីជីថល តាមរយៈការរៀបចំផែនការមេយន្តការនៃការលើកទឹកចិត្ត និងជំរុញភាពជាដៃគូរវាងគ្រឹះស្ថានស្រាវជ្រាវ គ្រឹះស្ថានឧត្តមសិក្សា និងបណ្ដាក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ដើម្បីលើកកម្ពស់សកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាឌីជីថល | ចំនួនកម្មវិធីស្រាវជ្រាវដែលបានបង្កើត | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| 3 | ជំរុញឱ្យមានការចូលរួមប្រកួតប្រជែងពីសំណាក់សាធារណជនស្ដីពីនវានុវត្តន៍បច្ចេកវិទ្យាឌីជីថល សម្រាប់វិស័យអធិការកិច្ច | - ចំនួនលើកនៃការប្រកួតប្រជែង<br>- ចំនួនអ្នកចូលរួមប្រកួតប្រជែង | ✓ | ✓ | ✓ | ✓ | នាយកដ្ឋានបរិវត្តកម្មឌីជីថល |

# ជំពូកទី៦

# សេចក្តីសន្និដ្ឋាន

វិស័យអធិការកិច្ចបានឆ្លងកាត់ការវិវត្តជាច្រើនសម័យកាល តាំងពីសម័យសង្គមរាស្ត្រនិយម រហូតមកដល់បច្ចុប្បន្ន ដែលមានសមិទ្ធផលជាច្រើនបានឆ្លុះបញ្ចាំងក្នុងការកំណែទម្រង់ និងការពង្រឹងអភិបាលកិច្ចរបស់រាជរដ្ឋាភិបាល ហើយសមិទ្ធផលដ៏ត្រចះត្រចង់ទាំងនេះ បានមកពីការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃវិស័យអធិការកិច្ចគ្រប់ជំនាន់។ ទន្ទឹងនឹងនេះ វិស័យអធិការកិច្ចក៏បាននឹងកំពុងជួបបញ្ហាប្រឈមមួយចំនួនដែលទាមទារឱ្យមានដំណោះស្រាយជាយុទ្ធសាស្ត្រប្រកបដោយភាពប្រកដប្រជា និងមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ ស្របនឹងបេសកកម្មដឹកនាំគ្រប់គ្រងវិស័យអធិការកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងអធិការកិច្ចក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **ឯកឧត្តម សុខ សុកេន រដ្ឋមន្ត្រីក្រសួងអធិការកិច្ច** បានរៀបចំ និងដាក់ចេញយុទ្ធសាស្ត្រ **«៣៤ជ៤»** ដែលបានគិតគូរគ្រប់ជ្រុងជ្រោយ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់។ ក្រសួងអធិការកិច្ច ត្រូវអនុវត្តភារកិច្ចជាច្រើនក្នុងយុទ្ធសាស្ត្រ«៣៤ជ៤»នេះ ដែលទាមទារឱ្យថ្នាក់ដឹកនាំ មន្ត្រីរាជការ និងគ្រប់អង្គភាពជំនាញពាក់ព័ន្ធទាំងអស់ ត្រូវខិតខំបំពេញការងារដោយការយកចិត្តទុកដាក់ និងការទទួលខុសត្រូវខ្ពស់ឱ្យសម្រេចបានលទ្ធផលជាច្រើន និងទទួលបានជោគជ័យខ្ពស់ តាមផែនការសកម្មភាពដែលមានលក្ខណៈប្រទាក់ក្រឡានិងពេញលេញ សំដៅឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាក្នុងវិស័យអធិការកិច្ច។ ជាមួយគ្នានេះផងដែរ ដើម្បីជំរុញការអនុវត្តយុទ្ធសាស្ត្រនេះ ឱ្យទទួលបានជោគជ័យប្រកបដោយប្រសិទ្ធភាពខ្ពស់ ទាមទារឱ្យមានការគាំទ្រពេញលេញពីរាជរដ្ឋាភិបាល និងកិច្ចសហការយ៉ាងជិតស្និទ្ធពីគ្រប់ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធនានា ជាពិសេស ស្របតាមប្រសាសន៍តម្រង់ទិសដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងអធិការកិច្ច កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ ថា «**ការងារអធិការកិច្ច គឺជាកិច្ចការសំខាន់ ដែលបានជួយដល់អភិក្រមចំនួន ៤ គឺ ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល ក្នុងចំណោមអភិក្រមទាំង៥ របស់ សម្តេចតេជោ និងស្នើឱ្យក្រសួង ស្ថាប័នទាំងអស់ កុំចាត់ទុកការងារអធិការកិច្ច គឺជាការចាប់កំហុស ផ្ទុយទៅវិញ គឺជាការតាមដានត្រួតពិនិត្យ និងជួយដល់ការពង្រឹងប្រសិទ្ធភាពការងាររបស់ស្ថាប័ន។ ក្នុងន័យនេះ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធាននៅតាមបណ្តាស្ថាប័ន អង្គភាពនានា និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវផ្តល់កិច្ចសហការល្អជាមួយមន្ត្រីអធិការកិច្ច និងយករបាយការណ៍លទ្ធផលអធិការកិច្ចជាមូលដ្ឋានក្នុងការកែតម្រូវនូវចំណុចខ្វះខាត ឬជាមូលដ្ឋាននៃការលើកសរសើរ**»។

ជារួម ក្រសួងអធិការកិច្ចដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាលលើការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ជាពិសេស ការលើកកម្ពស់អភិបាលកិច្ចនៅតាមក្រសួង ស្ថាប័នគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ ក្រសួងអធិការកិច្ចក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលនាំមុខលើវិស័យអធិការកិច្ច ប្តេជ្ញាអនុវត្តយុទ្ធសាស្ត្រ **«៣៤ជ៤»** ដ៏មានសារៈសំខាន់នេះ ប្រកបដោយភាពសកម្ម បុរេសកម្ម និងអន្តរសកម្ម ដើម្បីពង្រឹងប្រសិទ្ធភាព ភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ និងការទទួលខុសត្រូវរបស់មន្ត្រីសាធារណៈគ្រប់ថ្នាក់ ធានាយុត្តិធម៌និងប្រសិទ្ធភាពក្នុងការដោះស្រាយវិវាទ និងជំរុញការអប់រំផ្សព្វផ្សាយច្បាប់ប្រកបដោយប្រសិទ្ធភាព សំដៅចូលរួមជំរុញការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព បរិយាបន្ន និងចីរភាព។

# ការប្តេជ្ញាចិត្ត

កសាងទំនុកចិត្ត និងតម្លាភាពតាមរយៈ

យុទ្ធសាស្ត្រ ៣៤៥៤

## ចក្ខុវិស័យ

ក្រសួងអធិការកិច្ចជាសេនាធិការរបស់រាជរដ្ឋាភិបាលដែលមានលក្ខណៈស្ថាបនាយ៉ាងសកម្ម ចូលរួមក្នុងការរស់រវើកនៃបរិវត្តកម្មរបស់កម្ពុជា ដោយរួមចំណែកពង្រឹងអភិបាលកិច្ច និងទំនុកចិត្តសាធារណៈ ដើម្បីកសាងសង្គមដែលមានភាពធន់ ភាពប្រកួតប្រជែង និងចីរភាព តាមរយៈការលើកកម្ពស់គុណភាពស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ន សំដៅធានាបាននូវយុត្តិធម៌ តម្លាភាព និងអភិបាលកិច្ចល្អ ជូនប្រជាជន

**៣៤ - ពង្រឹង៤ ៣៤៥៤ ៥៤ - ជំរុញ៤**

### ៣១ ពង្រឹងការងារអធិការកិច្ច

ពង្រឹងការត្រួតពិនិត្យ និងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងស្ថាប័នរដ្ឋាភិបាល

### ៣២ ពង្រឹងការងារដោះស្រាយបណ្តឹង

ធានាការដោះស្រាយបណ្តឹងដោយរលូនប្រកបដោយប្រសិទ្ធភាព និងការការពារសិទ្ធិប្រជាពលរដ្ឋ

### ៣៣ ពង្រឹងការងារតាមដានការអនុវត្តច្បាប់

ធានានូវតម្លាភាព និងការគោរពច្បាប់នៅក្នុងវិស័យសាធារណៈ និងឯកជន

### ៣៤ ពង្រឹងការងារអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ

កម្មវិធីអប់រំប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធស្តីពីអភិបាលកិច្ច និងបញ្ញាច្បាប់

---

**៥១. ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត** — កែលម្អច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីអភិបាលកិច្ចល្អ

**៥២. ជំរុញ និងបង្កើនសមត្ថភាពស្ថាប័ន** — ពង្រឹងស្ថាប័នរដ្ឋាភិបាល និងអង្គភាពអធិការកិច្ច

**៥៣. ជំរុញកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ** — សហការជាមួយភាគីពាក់ព័ន្ធដើម្បីការកែលម្អគោលនយោបាយ និងអភិបាលកិច្ច

**៥៤. ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល** — ទំនើបកម្មប្រតិបត្តិការតាមរយៈបច្ចេកវិទ្យា និងការត្រួតពិនិត្យដែលផ្អែកលើទិន្នន័យ

---

**សុចរិតភាព** | **វិជ្ជាជីវៈ** | **ភាពច្បាស់លាស់** | **គណនេយ្យភាព** | **ភាពជាដៃគូ**


ក្រសួងអធិការកិច្ច
Ministry of Inspection

អគារលេខ ១២៦ ផ្លូវលេខ ៣ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ

#126 St. 3 Sangkat Tonle Bassac
Khan Chamkarmon Phnom Penh

023 221 458
info@inspection.gov.kh


សម្រាប់ទាញយកឯកសារ
Access Documents

បណ្តាញតេលេក្រាមរបស់ក្រសួងអធិការកិច្ច
Ministry of Inspection’s Telegram

បណ្តាញសង្គមឯកឧត្តមរដ្ឋមន្ត្រី
H.E. Minister Sok Soken

WWW.INSPECTION.GOV.KH